**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ចំណាត់ការរបស់ព្រះរាជអាជ្ញាក្នុងរឿងក្តី ព្រហ្មទណ្ឌនៃស្ថាប័នអយ្យការអមសាលាដំបូង

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែ មីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែ ឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **អ៊ីង សុរិន**

**តាំង សុខហេង**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **អ៊ីច សុរិន** និង ខ្ញុំបាទឈ្មោះ **តាំង សុខហេង** ជានិស្សិតបរិញ្ញាបត្រជំនាញនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

**លោកឪពុក** និង **អ្នកម្ដាយ** របស់យើងខ្ញុំដែលលោកទាំងពីរបានផ្ដល់កំណើត និងចិញ្ចឹមថ្នាក់ថ្នមបីបាច់ថែក្សាតាំងតែពីចាប់កំណើតមក រហូតដល់ធំពេញវ័យ ជាពិសេសនោះលោកទាំងពីរថែមទាំងបានទំនុកបម្រុងគ្រប់បែបគ្រប់យ៉ាងទាំងសម្ភារៈប្រើប្រាស់ ទាំងស្មារតី ការអប់រំណែនាំ ប្រៀនប្រដៅយើងខ្ញុំឱ្យធ្វើតែអំពើល្អធ្វើជាមនុស្សដែលសង្គមទទួលស្គាល់ ហើយតែងតែឈរនៅពីក្រោយភាពជោគជ័យរបស់យើងខ្ញុំ ព្រមទាំងផ្ដល់នូវកម្លាំងចិត្តគ្រប់ពេលវេលា។

ឯកឧត្ដម **លុយ ចណ្ណា** ដែលជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យយើងខ្ញុំ បានសិក្សារៀនសូត្រ ទទួលយកនូវចំណេះដឹងថ្មីៗ ដែលយើងខ្ញុំមិនបានទទួលដឹងពីមុនមកនៅក្នុងសាកលវិទ្យាល័យនេះ ព្រមទាំងបង្កឱ្យមានលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ។

លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យណែនាំ របស់យើងខ្ញុំ ដែលតែងតែចំណាយពេលដ៏មានតម្លៃទាំងកម្លាំងកាយ កម្លាំងចិត្ត ក្នុងការចង្អុលបង្ហាញ ពន្យល់ ណែនាំ និងជួយកែលម្អនូវចំណុចខ្វះខាតមួយចំនួន ដែលក្រុមរបស់យើងខ្ញុំបានជួបប្រទះ ព្រមទាំងផ្ដល់ជាឯកសារពាក់ព័ន្ធផ្សេងៗ និងអនុសាសន៍ល្អៗក្នុងការស្រាវជ្រាវមួយនេះ ដែលខ្ញុំអាចនិយាយបានថា កិច្ចការស្រាវជ្រាវមួយនេះមានរូបរាងទៅបាន គឺដោយសារតែមានវត្តមានរបស់លោកគ្រូជួយជ្រោមជ្រែងនៅពីក្រោយ។

**ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ** និង **បុគ្គលិកការិយាល័យសិក្សា** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានជួយសម្រួលដល់ការសិក្សារបស់យើងខ្ញុំ តាំងពីថ្នាក់មូលដ្ឋាន រហូតមកដល់ថ្នាក់បញ្ចប់នៃការសិក្សាបរិញ្ញាបត្រមួយនេះ។

ជាកិច្ចបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធពរជ័យសិរីមង្គលជូនដល់ លោកអ្នកមានគុណទាំងពីរ ឯកឧត្ដម លោកជំទាវ លោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់ ទទួលជោគជ័យគ្រប់ភារកិច្ច សុខភាពល្អ សំណាងល្អ ព្រមទាំងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ សូមអរគុណ!

ភ្នំពេញថ្ងៃទី..........ខែ..........ឆ្នាំ ២០......

ហត្ថលេខា

# អារម្ភកថា

ខ្ញុំបាទឈ្មោះ **អ៊ីម សុរិន** និង ខ្ញុំបាទឈ្មោះ **តាំង សុខហេង** សូមគោរពស្វាគមន៍ទៅដល់រាល់មិត្តអ្នកអានគ្រប់គ្នា ជាពិសេសសិស្ស និស្សិត គ្រប់ជំនាន់ជាទីស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅ ព្រមទាំងលោកគ្រូសាស្ត្រាចារ្យជាទីគោរព។ ក្នុងនាមយើងខ្ញុំជានិស្សិតដែលទទួលបានការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ចេញពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានរៀបចំនូវសារណាក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រមួយនេះ ក្រោមប្រធានបទមួយស្តីពី **ចំណាត់ការរបស់ព្រះរាជអាជ្ញាក្នុងរឿងក្តីព្រហ្មទណ្ឌនៃស្ថាប័នអយ្យការអមសាលាដំបូង** ដែលត្រូវទទួលបានការគាំទ្រ និង យកចិត្តទុកដាក់យ៉ាងពេញទំហឹងក្នុងការចង្អុលបង្ហាញ ទាក់ទងទៅនឹងប្រធានបទសារណាមួយនេះ ពីសំណាក់លោកគ្រូសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យផ្នែកច្បាប់ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំទាំងពីរបានសម្រេចជ្រើសរើសយកប្រធានបទមួយនេះ មកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងវាឡើងឱ្យក្លាយទៅជាអត្ថបទមួយ ដែលមានការទទួលស្គាល់ពីសំណាក់សាស្ត្រាចារ្យនៅក្នុងសាលា ក្នុងគោលបំណងដើម្បីចូលរួមចំណែក ផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយ នូវរាល់ដំណើរការកំណែទម្រង់នានា ដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធយុត្តិធម៌នៅកម្ពុជានាពេលបច្ចុប្បន្ននេះ ជាពិសេសនោះយើងខ្ញុំចងក្រងវាឡើងសម្រាប់បំពេញនូវតម្រូវការដល់ សិស្ស និស្សិតគ្រប់រូប ឱ្យកាន់តែមានភាពងាយស្រួលក្នុងការធ្វើការសិក្សាស្រាវជ្រាវ លើអត្ថបទទាំងឡាយណាដែលពាក់ព័ន្ធទៅលើប្រធានបទមួយនេះ មួយវិញទៀតយើងខ្ញុំទាំងពីរនាក់ ក៏ចង់ពង្រឹងនូវសមត្ថភាពខ្លួនឯង និងចង់សិក្សាឱ្យកាន់តែស៊ីជម្រៅ និងច្បាស់លាស់បន្ថែមទៀតទៅលើខ្លឹមសារ ក៏ដូចជាអត្ថន័យផ្សេងៗ នៃក្រមនីតិវិធីព្រហ្មទណ្ឌមួយនេះ ហើយអ្វីដែលសំខាន់នោះគឺចង់សិក្សាឱ្យកាន់តែច្បាស់ ទៅលើប្រធានបទ ដែលយើងខ្ញុំបានធ្វើការស្រាវជ្រាវនេះតែម្តង។ តែទោះបីជាមានការខិតខំការសិក្សាស្រាវជ្រាវ ត្រួតពិនិត្យ និងការកែតម្រូវយ៉ាងណាក៏ដោយ ក៏ការចងក្រងសារណាមួយនេះ ប្រាកដណាស់ តែងតែមាននូវចំណុចខ្វះខាតទាំងផ្នែកខ្លឹមសារ អត្ថន័យ ពាក្យពេចន៍ ឃ្លោងឃ្លា ក៏ដូចជាកំហុសឆ្គងផ្នែកអក្ខរាវិរុទ្ធជាដើម ដែលកើតមានឡើងដោយអចេតនា ហើយយើងខ្ញុំសង្ឃឹមថា រាល់កំហុសឆ្គងដែលយើងខ្ញុំមាននៅក្នុងកិច្ចការស្រាវជ្រាវមួយនេះនឹងត្រូវទទួលបាននូវការអធ្យាស្រ័យ និងការអភ័យអត់ទោសពីសំណាក់អ្នកអាន ព្រមទាំងអស់លោក លោកស្រី សាស្ត្រាចារ្យ គ្រប់មជ្ឈដ្ឋានជាក់ជាមិនខានឡើយ ហើយយើងខ្ញុំនឹងទទួលរង់ចាំនូវការរិះគន់ និងកែតម្រូវ ក្នុងន័យស្ថាបនាពីសំណាក់អ្នកទាំងអស់គ្នាគ្រប់ពេលវេលាផងដែរ។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរដល់ អស់លោក លោកស្រី អ្នកនាងកញ្ញា សាស្ត្រាចារ្យ និងមិត្តអ្នកអានគ្រប់រូបឱ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន រុងរឿងចុំច្រើន និងជួបតែពុទ្ធពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ សូមអរគុណ!

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១
## សញ្ញាណទូទៅនៃស្ថាប័នអយ្យការអមសាលាដំបូង

**ផ្នែកទី១. សមាសភាពនៃអយ្យការអមសាលាដំបូង** ........ ៧
១.១. ព្រះរាជអាជ្ញា ........ ៧
១.២. ព្រះរាជអាជ្ញារង ........ ៧
១.៣. ក្រឡាបញ្ជី ........ ៨
**ផ្នែកទី២. គោលការណ៍សំខាន់ៗរបស់អយ្យការ** ........ ៨
២.១. គោលការណ៍ឯកភាព ........ ៨
២.២. គោលការណ៍អវិភាគ ........ ៩
២.៣. គោលការណ៍ឯករាជ្យ ........ ៩
២.៤. គោលការណ៍នៃការមិនទទួលខុសត្រូវ ........ ១០
២.៥. គោលការណ៍មិនអាចប្តឹងដិតចិត្ត ........ ១០
**ផ្នែកទី៣. សមត្ថកិច្ច តួនាទី ភារកិច្ច និងអំណាចរបស់ព្រះរាជអាជ្ញា** ........ ១១
៣.១. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា ........ ១១
៣.២. តួនាទីរបស់ព្រះរាជអាជ្ញា ........ ១២
៣.៣. ភារកិច្ចរបស់ព្រះរាជអាជ្ញា ........ ១២
៣.៤. អំណាចរបស់ព្រះរាជអាជ្ញា ........ ១៣

## ជំពូកទី២
## កិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញា

**ផ្នែកទី១. ការបើកការស៊ើបសួរ** ........ ១៥
១.១. លក្ខខណ្ឌនៃការបើកការស៊ើបសួរ ........ ១៥
១.១.១. ការបើកការស៊ើបសួរចំពោះបទឧក្រិដ្ឋ ........ ១៥
១.១.២. ការបើកការស៊ើបសួរចំពោះបទមជ្ឈិម ........ ១៦

១.២. នីតិវិធីនៃការបើកការស៊ើបសួរ ........ ១៦
១.២.១. នីតិវិធីការបើកការស៊ើបសួរតាមរយៈពាក្យបណ្ដឹងដោយផ្ទាល់ ........ ១៦
១.២.២. ការបើកការស៊ើបសួរតាមរយៈសំណុំរឿងបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ...... ១៧
១.៣. ទម្រង់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ........ ១៨
១.៤. អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ........ ១៩
**ផ្នែកទី២. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់** ........ ២០
២.១. លក្ខខណ្ឌនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ២១
២.១.១. លក្ខខណ្ឌនៃបទល្មើស ........ ២១
២.១.២. លក្ខខណ្ឌសារតារបស់ជនល្មើស ........ ២២
២.២. នីតិវិធីនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ២២
២.២.១. ថិរវេលានៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ២៣
២.២.២. របៀបនៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ២៣
២.២.៣. ផលវិបាកនៃការពុំបានគោរពរយៈពេលតាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់... ២៥
២.៣. ទម្រង់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ២៥
២.៤. អានុភាពនៃដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ២៧
**ផ្នែកទី៣. ការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម** ........ ២៨
៣.១. លក្ខខណ្ឌនៃនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ........ ២៨
៣.២. នីតិវិធីនៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ........ ៣០
៣.២.១. នីតិវិធីចាត់ការនៅចំពោះមុខព្រះរាជអាជ្ញា ........ ៣០
៣.២.២. នីតិវិធីចាត់ការនៅចំពោះមុខយុត្តាធិការជំនុំជម្រះ ........ ៣១
៣.៣. អានុភាពនៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ........ ៣២

## ជំពូកទី៣

## ការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា

**ផ្នែកទី១. មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ** ........ ៣៤
១.១. នត្ថិភាពនៃបទល្មើស ........ ៣៥
១.១.១. អវត្តមាននៃបទល្មើស ........ ៣៥

១.១.២. កង្វះធាតុផ្សំនៃបទល្មើស ...................................................................... ៣៥
១.២. មូលហេតុគតិយុត្ត ........................................................................................ ៣៧
១.២.១. ការផុតរលត់នៃបណ្តឹងអាជ្ញា ........................................................................ ៣៧
១.២.២. អភ័យឯកសិទ្ធិ ......................................................................................... ៤០
១.២.៣. អនិយ័តភាពនៃនីតិវិធី ................................................................................ ៤១
១.២.៤. ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ........................................................ ៤២
១.២.៥. មូលហេតុផ្សេងទៀតនៃការរួចផុតនៃបណ្តឹងអាជ្ញា .............................................. ៤៧
១.៣. ការចោទប្រកាន់មិនផ្តល់ប្រយោជន៍ ....................................................................... ៥០
**ផ្នែកទី២. នីតិវិធី ទម្រង់ការ និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ** ........... ៥១
២.១. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ ................................................................ ៥១
២.២. ទម្រង់ការនៃដីកាតម្កល់រឿងទុកឥតចាត់ការ ............................................................ ៥២
២.៣. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ ............................................................... ៥៣
**ផ្នែកទី៣. យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ** ...................................... ៥៣
៣.១. ការសើរើសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា ............................................................. ៥៤
៣.២. បណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ..................................................... ៥៤
៣.៣. អំណាចអធិបញ្ញាដោយឋានានុក្រមនៃអង្គការអយ្យការ .............................................. ៥៦
៣.៣.១. រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ............................................................................... ៥៦
៣.៣.២. អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ................................................................ ៥៦
៣.៣.៣. ព្រះរាជអាជ្ញា ........................................................................................... ៥៧
៣.៣.៤. ព្រះរាជអាជ្ញារង ....................................................................................... ៥៧
៣.៤. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ................................................................. ៥៨
**សេចក្តីសន្និដ្ឋាន** ............................................................................................... ៦០
**អនុសាសន៍** ...................................................................................................... ៦៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

ក្រោយពីភ្លើងសង្គ្រាមត្រូវបានបញ្ចប់ និងទទួលបាននូវសន្តិភាពពេញលេញនាឆ្នាំ ១៩៩៣ មក កម្ពុជាបានស្រុះស្រួលព្រមព្រៀងឯកភាពគ្នា ធ្វើការបង្រួបបង្រួមជាតិឡើងវិញ ក្រោមកិច្ចខិតខំប្រឹងប្រែងដឹកនាំយ៉ាងយកចិត្តទុកប្រកបដោយគតិបណ្ឌិត តាមរយៈគោលនយោបាយឈ្នះៗរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានធ្វើឱ្យប្រទេសកម្ពុជា ទទួលបានសុខសន្តិភាព ស្ថេរភាព ភាពតភាព និងការអភិវឌ្ឍស្ទើគ្រប់វិស័យទាំងអស់។

ទន្ទឹមនឹងពេលដែលប្រទេសកំពុងអភិវឌ្ឍនេះហើយ បានធ្វើឱ្យកម្ពុជាជួបនូវបញ្ហាជាច្រើន ដែលជាកត្តារាំងស្ទះដល់ការរីកចម្រើនរបស់ប្រទេសជាតិ។ ហើយដើម្បីជាការចូលរួមចំណែក ក្នុងការកាត់បន្ថយនូវភាពអវិជ្ជមានទាំងឡាយ គឺត្រូវទាមទារឱ្យមានការចូលរួមយ៉ាងយកចិត្តទុកដាក់ខ្លាំងបំផុត ពីសំណាក់រាជរដ្ឋាភិបាលថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធ និងជាពិសេសការចូលរួមពីប្រជាពលរដ្ឋទាំងអស់ ដែលជាស្នូលក្នុងការជួយជាតិមាតុភូមិ។ ក្នុងនោះដើម្បីឱ្យប្រទេសជាតិមួយមានការអភិវឌ្ឍជឿនលឿន និងខ្លាំងក្លាទៅបាន គឺទាមទារឱ្យមានការបង្កើតនូវវិធានច្បាប់ និងបទដ្ឋានគតិយុត្តនានាដើម្បីធានាឱ្យបាននូវសន្តិសុខ សណ្តាប់ធ្នាប់ យុត្តិធម៌ តម្លាភាព ព្រមទាំងធានាឱ្យបាននូវប្រសិទ្ធិភាពនៃការអនុវត្តច្បាប់នៅក្នុងប្រទេសផងដែរ។ លើសពីនេះទៅទៀតដើម្បីបម្រើ និងការពារផលប្រយោជន៍សង្គម ច្បាប់ទាំងនោះត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវ យុត្តិធម៌ មិនលំអៀង និងឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស ជាពិសេសទៅលើក្រុមមនុស្សដែលងាយរងគ្រោះដូចជា៖ ជនពិការ ស្ត្រីមានផ្ទៃពោះ ចាស់ជរា កូនក្មេង និងប្រជាជនស្លូតត្រង់ផ្សេងៗទៀតជាដើម។ កាលណាបើប្រទេសជាតិមួយគ្មានច្បាប់ គ្មានវិន័យក្នុងការគ្រប់គ្រងសកម្មភាពរបស់ប្រជាពលរដ្ឋខ្លួនឱ្យបានល្អនោះទេ ច្បាស់ណាស់ថាប្រទេសនោះនឹងក្លាយទៅជាប្រទេសដែលគ្មានសណ្តាប់ធ្នាប់ គ្មានរបៀបរៀបរយ បាត់បង់នូវសីលធម៌ និងប្រជាពលរដ្ឋរស់នៅដោយអនាធិបតេយ្យជាក់ជាមិនខានឡើយ ជាលទ្ធផលនឹងធ្វើឱ្យប្រទេសជាតិនោះ សំបូរទៅដោយ ក្មេងទំនើង អំពើហិង្សា ចោរលួច ចោរប្លន់ ឃាតកម្ម និងបទល្មើសផ្សេងៗជាច្រើនទៀតជាក់ជាមិនខាន។ ដូច្នេះហើយវាពិតជាចាំបាច់ ដែលត្រូវតែមានច្បាប់សម្រាប់គ្រប់គ្រងប្រទេស ហើយអ្វីដែលសំខាន់នោះគឺត្រូវតែមានប្រព័ន្ធតុលាការមួយដែលឯករាជ្យ និងយុត្តិធម៌ ក្នុងការអនុវត្តច្បាប់ប្រកបដោយភាពត្រឹមត្រូវ ច្បាស់លាស់ មិនលំអៀង និងគ្មានអំពើពុករលួយ។ ក្នុងនោះយើងឃើញថា ប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា គឺត្រូវបានគេធ្វើឡើងដើម្បីការពារ ឬបង្ការកុំឱ្យមានបទល្មើសកើតឡើងនៅក្នុងប្រទេស និងដើម្បីដោះស្រាយនូវរាល់បញ្ហាដែលពាក់ព័ន្ធទៅនឹងបទល្មើសព្រហ្មទណ្ឌ។ ចំពោះប្រព័ន្ធយុត្តិធម៌នេះសំដៅទៅលើប្រព័ន្ធតុលាការ ដែលវាជា

អំណាចមួយក្នុងចំណោមអំណាចទាំងបី។ យោងតាមមាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញបានចែងថា ប្រព័ន្ធតុលាការ គឺជាស្ថាប័នឯករាជ្យដែលធានា និងលើកស្ទួយ អព្យាក្រឹតភាព និងការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ។ ដូចនេះហើយ ដើម្បីធានាបាននូវអព្យាក្រឹតភាព និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ គេចាំបាច់ត្រូវចង់ក្រងវិធានច្បាប់នេះឡើង ក្នុងគោលបំណងឱ្យមន្ត្រីមានសមត្ថកិច្ចនៅតាមតុលាការ អាចអនុវត្តនូវវិធានច្បាប់ទាំងនោះទៅតាមលំហូនៃនីតិវិធីដែលបានបញ្ញត្តិទុកជាស្រេចនៅក្នុងក្រមព្រហ្មទណ្ឌ និង ក្រមនីតិវិធីព្រហ្មទណ្ឌ សម្រាប់ទុកការពារសិទ្ធិ ក៏ដូចជាផលប្រយោជន៍របស់បុគ្គលនីមួយៗដែលត្រូវបានគេចោទប្រកាន់ ឬជនរងគ្រោះក្នុងរឿងក្តីព្រហ្មទណ្ឌ។ ជាក់ស្តែងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៧ និងត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ ហើយក្រមនីតិវិធីនេះត្រូវបានក្លាយជាអត្ថបទច្បាប់ដ៏មានសារៈសំខាន់ និងជាមធ្យោបាយដ៏ចម្បងក្នុងការបែងចែកពីតួនាទី ភារកិច្ចរបស់បុគ្គលដែលមានសមត្ថកិច្ច នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ហើយជាពិសេសក្រមនីតិវិធីនេះ បានកំណត់ពីនីតិវិធីនៃដំណាក់កាលនីមួយៗដូចជា៖ ដំណាក់កាលនៃការស៊ើបអង្កេត ដំណាក់កាលនៃការចោទប្រកាន់ ដំណាក់កាលនៃការស៊ើបសួរ និង ដំណាក់កាលនៃការជំនុំជម្រះ។ ដោយឡែកដំណាក់កាលនៃការចោទប្រកាន់ គឺជាដំណាក់កាលដ៏សំខាន់ជាងគេ មុននឹងឈានដល់ដំណាក់កាលនៃការស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ដែលត្រូវបានអនុវត្តឡើងដោយស្ថាប័នអយ្យការ។ ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌក្នុងគន្លីទី ២ (ពីរ) បានចែងថា អង្គការអយ្យការ គឺជាស្ថាប័នមួយឯករាជ្យ ដែលដឹកនាំដោយអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រមទាំងមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដែលជាសេនាធិការនៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និង ជួយសម្របសម្រួលរក្សាសណ្តាប់ធ្នាប់សាធារណៈផងដែរ។ អង្គការអយ្យការនេះ គឺជាតំណាងរបស់អង្គការនីតិប្រតិបត្តិ ស្ថិតនៅអមសាលាជម្រះក្តី ដែលមានតួនាទីធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់ និងធានារ៉ាប់រងការអនុវត្ត សេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន ក្នុងនាមតំណាងឱ្យផលប្រយោជន៍សាធារណៈ។ នៅពេលមានបទល្មើសព្រហ្មទណ្ឌកើតឡើង មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញាតាមរយៈពាក្យបណ្តឹងផ្ទាល់របស់ជនរងគ្រោះ និងតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ហើយមានឆន្ទានុសិទ្ធិក្នុងការសម្រេចធ្វើការចោទប្រកាន់ ឬ មិនធ្វើការចោទប្រកាន់ទៅលើបទល្មើសទាំងនោះ ដែលមានព្រះរាជអាជ្ញាជាអ្នកបំពេញតួនាទីក្នុងស្ថាប័នមួយនេះ។

## ២.ចំណោទបញ្ហា

ដោយយល់ឃើញពីសារៈសំខាននៃប្រធានបទនេះ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ និងលើកជាបញ្ហាមួយចំនួនដែលត្រូវបានចោទឡើងពាក់ព័ន្ធនឹងប្រធានបទនេះថា តើស្ថាប័នអយ្យការមានសមាសភាព តួនាទី ភារកិច្ច និង អំណាចអ្វីខ្លះ? ហើយព្រះរាជអាជ្ញាដែលជាតំណាងឱ្យស្ថាប័នអយ្យការមានសិទ្ធិអំណាចក្នុងការចោទប្រកាន់ទៅលើបណ្ដឹងដែលខ្លួនទទួលបាន ដោយស្ដែងតាមនីតិវិធី និងចំណាត់ការអ្វីខ្លះ? តើមានហេតុផល ឬមូលហេតុអ្វីខ្លះដែលបើកសិទ្ធិឱ្យព្រះរាជអាជ្ញាអាចធ្វើការថ្លឹងថ្លែងថា តើគួរធ្វើការចោទប្រកាន់ ឬមិនធ្វើការចោទប្រកាន់នៅក្នុងរឿងក្ដីព្រហ្មទណ្ឌ។

## ៣.គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហានៃការស្រាវជ្រាវខាងលើនេះ យើងខ្ញុំនឹងសរសេរចងក្រងនូវអត្ថបទមួយនេះឡើង ក្នុងគោលបំណងផ្តោតសំខាន់លើការសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅ ទៅលើខ្លឹមសារ និងសារៈសំខាន់នៃនីតិវិធីនីមួយៗ ដែលអនុវត្តដោយស្ថាប័នអយ្យការ និងការបំពេញតួនាទីរបស់ព្រះរាជអាជ្ញា ទៅលើការចោទប្រកាន់របស់ខ្លួនក្នុងរឿងក្ដីព្រហ្មទណ្ឌ ដែលជាអ្នកតំណាងឱ្យប្រយោជន៍សាធារណៈ។ បន្ថែមពីនេះ ចំណាត់ការរបស់ព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ក្នុងរឿងក្ដីព្រហ្មទណ្ឌនេះ នឹងឆ្លុះបញ្ចាំងឱ្យឃើញពីតួនាទី ភារកិច្ចរបស់ព្រះរាជអាជ្ញា ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកស្វែងរកនូវយុត្តិធម៌ទៅដល់ជនរងគ្រោះ ក៏ដូចជាធានាដល់សិទ្ធិរបស់ជនល្មើស ក្នុងការទទួលបាននូវការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ ជាពិសេសនោះគឺជួយបង្ការ និងបង្ក្រាបកុំឱ្យមានបទល្មើសកើតមានឡើងនៅក្នុងសង្គមជាតិផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវសារណាមួយនេះ យើងខ្ញុំបានធ្វើការកំណត់ត្រឹមតែទំហំនៃប្រធានបទ នៅក្នុងព្រំដែនមួយ នៃស្ថាប័នអយ្យការតែប៉ុណ្ណោះ ពោលគឺបកស្រាយតែទៅលើ **ចំណាត់ការរបស់ព្រះរាជអាជ្ញាក្នុងរឿងក្ដីព្រហ្មទណ្ឌ ដែលជាសមត្ថកិច្ចរបស់ស្ថាប័នអយ្យការអមសាលាដំបូង** ដោយមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយ គឺពិតជាមានការលំបាក ព្រោះយើងត្រូវការចំណាយពេលវេលាច្រើន ទាំងកម្លាំងកាយចិត្ត និងថវិកា ជាពិសេសត្រូវការការតស៊ូ ព្យាយាម អត់ធ្មត់ ដើម្បីធ្វើយ៉ាងណាឱ្យការសិក្សាស្រាវជ្រាវមួយនេះទទួលបានជោគជ័យ។ តែទោះបីជាមានការលំបាកយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅតែខិតខំជម្នះឱ្យទាល់តែបាន ព្រោះថាការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ ពិតជាមានសារៈសំខាន់ខ្លាំង

ណាស់សម្រាប់យើងខ្ញុំ ក្នុងការទទួលបាននូវចំណេះដឹងថ្មីៗ និងបទពិសោធន៍ល្អៗជាច្រើនពីបណ្តាលលោកគ្រូសាស្ត្រាចារ្យ សិស្សច្បង មិត្តរួមថ្នាក់ និងអ្នកដែលមានចំណេះដឹង និងបទពិសោធន៍ផ្សេងៗទៀត ហើយជាពិសេសយើងខ្ញុំអាចបន្សល់នូវស្នាដៃទុកសម្រាប់សិស្សនិស្សិត អ្នកសិក្សាស្រាវជ្រាវផ្នែកច្បាប់ សម្រាប់ជាប្រទីបក្នុងការជំនួយស្មារតីបន្ថែមលើចំណេះដឹងដែលមាន ដើម្បីបានសិក្សាស្រាវជ្រាវបន្តទៀត។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ចំពោះវិធីសាស្ត្រ នៃការសិក្សាស្រាវជ្រាវ យើងខ្ញុំបានខិតខំប្រើប្រាស់នូវគ្រប់មធ្យោបាយ និងវិធីសាស្ត្រជាច្រើន ដើម្បីបានជាប្រភពឯកសារក្នុងការយកមកសរសេរសារណានេះឡើង ហើយចំពោះការប្រមូលឯកសារនេះ គឺបានមកតាមរយៈការប្រមូលឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទ ទ្រឹស្តី ក៏ដូចជាមេរៀនដែលបានរៀនកន្លងមក តាមប្រព័ន្ធផ្សព្វផ្សាយនានា និងលិខិតបទដ្ឋានមួយចំនួនដូចជា៖ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ រួមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ព្រមទាំងការសាកសួរសុំយោបល់ពីសំណាក់លោកគ្រូសាស្ត្រាចារ្យដឹកនាំ សិស្សច្បង និងមិត្តរួមថ្នាក់។ ហើយជាពិសេសនោះគឺឯកសារដែលមានលក្ខណៈជាលាយលក្ខណ៍អក្សរ ដែលយើងខ្ញុំព្យាយាមស្វែងរកនូវតាមបណ្ណាល័យ តាមតូបលក់សៀវភៅ និងបណ្ណាគារជាដើម ដើម្បីឱ្យដំណើរការនៃការស្រាវជ្រាវមួយនេះទទួលបានជោគជ័យ។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ក្នុងរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទ **ចំណាត់ការរបស់ព្រះរាជអាជ្ញាក្នុងរឿងក្តីព្រហ្មទណ្ឌ នៃស្ថាប័នអយ្យការអមសាលាដំបូង** និង ដើម្បីងាយស្រួលធ្វើការពន្យល់ទៅដល់មិត្តអ្នកអានឱ្យបានយល់ដឹងកាន់តែច្បាស់ពីស្ថាប័នមួយនេះ យើងខ្ញុំបានសរសេរចង់ក្រងអត្ថបទនេះឡើង ដោយបានធ្វើការបែងចែកជា ០៣ ជំពូកធំៗ ដែលក្នុងនោះរួមមាន៖

- **ជំពូកទី១ សញ្ញាណទូទៅនៃស្ថាប័នអយ្យការអមសាលាដំបូង**
    - សមាសភាពនៃអយ្យការអមសាលាដំបូង
    - គោលការណ៍សំខាន់ៗរបស់អយ្យការ
    - សមត្ថកិច្ច តួនាទី ភារកិច្ច និង អំណាចរបស់ព្រះរាជអាជ្ញា។
- **ជំពូកទី២ កិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញា**
    - ការបើកការស៊ើបសួរ
    - ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់
    - ការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។

- **ជំពូកទី៣ ការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា**
    - មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ
    - នីតិវិធី ទម្រង់ការ និង អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ
    - យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ។

# ជំពូកទី១

# ជំពូកទី១
# សញ្ញាណទូទៅនៃអយ្យការអមសាលាដំបូង

ក្នុងប្រព័ន្ធតុលាការនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបែងចែកជា ៣ (បី) ថ្នាក់រួមមាន៖ សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល ។ ដោយយោងតាមមាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញ អំណាចតុលាការ គឺជាអំណាចមួយដែលឯករាជ្យ ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ ដោយឡែក សាលាដំបូង គឺជាសាលាជម្រះក្តីជាន់ទាប ដែលអមដោយអង្គការអយ្យការមួយហៅថា អយ្យការអមសាលាដំបូង ដែលមាននៅគ្រប់រាជធានី-ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា។ អយ្យការអមសាលាដំបូង គឺជាស្ថាប័នតំណាងឱ្យអង្គការនីតិប្រតិបត្តិ ដែលបង្កើតឡើងដើម្បីការពារសណ្តាប់ធ្នាប់ ផលប្រយោជន៍ទូទៅ និងរក្សារបៀបរៀបរយនៅក្នុងសង្គម។ អយ្យការអមសាលាដំបូងនេះ មានមុខងារធ្វើបណ្តឹងអាជ្ញា និងសុំឱ្យអនុវត្តច្បាប់ នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ព្រមទាំងអនុវត្តមុខងារផ្សេងទៀត តាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។[1] ក្នុងន័យនេះ អង្គការមួយនេះមានមុខងារចំបងក្នុងការធ្វើបណ្តឹងអាជ្ញា ឬជាម្ចាស់នៃបណ្តឹងអាជ្ញា មានន័យថាជាអ្នកធ្វើការចោទប្រកាន់នៅពេលមានអំពើបង្កចលាចលដល់សង្គមណាមួយបានកើតឡើង ដែលអំពើនោះច្បាប់បានបញ្ញត្តិទុកជាមុនថាជាបទល្មើសព្រហ្មទណ្ឌ ហើយស្នើសុំឱ្យយុត្តាធិការស៊ើបសួរ និង យុត្តាធិការជំនុំជម្រះអនុវត្តច្បាប់ថែមទៀតផង។ ដូចនេះ អយ្យការអមសាលាដំបូង គឺជាយុត្តាធិការមួយដ៏សំខាន់ដែលមិនអាចខ្វះបាននៅក្នុងវិស័យព្រហ្មទណ្ឌ ដោយជម្រុញឱ្យរឿងក្តីព្រហ្មទណ្ឌមួយ អាចដំណើរការទៅមុខបាន ដើម្បីឈានទៅដល់ការបង្ក្រាបបទល្មើស ផ្តន្ទាទោសជនល្មើស និងស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើល្មើសនោះផងដែរ។ ប៉ុន្តែមុននឹងឈានដល់ការស្វែងយល់អំពីកិច្ចចោទប្រកាន់ដែលជាតួនាទីចំបងរបស់ស្ថាប័នអយ្យការ យើងគួរគប្បីស្វែងយល់ជាមុនអំពីសញ្ញាណទូទៅនៃស្ថាប័ននេះ ថាតើស្ថាប័ននេះត្រូវបានបំពេញតួនាទីដោយនរណា? ហើយការបំពេញតួនាទីត្រូវប្រកាន់ភ្ជាប់នូវគោលការណ៍អ្វីខ្លះ? តើសមាសភាពនៃស្ថាប័ននេះមានសមត្ថកិច្ច តួនាទី ភារកិច្ច និងអំណាច យ៉ាងដូចម្តេច? ដើម្បីជាប្រទីបក្នុងការស្រាយបភ្លឺនូវសំនួរគតិយុត្តទាំងនេះ ខ្លឹមសារទាំងអស់នឹងត្រូវបានបកស្រាយតាមផ្នែកនីមួយៗដូចខាងក្រោម៖

- **ផ្នែកទី១ សមាសភាពនៃអយ្យការអមសាលាដំបូង**
- **ផ្នែកទី២ គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ**
- **ផ្នែកទី៣ សមត្ថកិច្ច តួនាទី ភារកិច្ច និងអំណាចរបស់ព្រះរាជអាជ្ញា**

[1] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ,លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៣០។

## ផ្នែកទី១ សមាសភាពនៃអយ្យការអមសាលាដំបូង

យោងតាមមាត្រា ២៩ នៃច្បាប់ស្តីពីការរៀបចំតុលាការ ឆ្នាំ២០១៤ បានកំណត់អំពីសមាសភាពអយ្យការអមសាលាដំបូង រួមមាន៖ ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងៗទៀតដែលបម្រើការងារនៅអយ្យការអមសាលាដំបូង។

### ១.១. ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា គឺជាមន្ត្រីដែលស្ថិតនៅក្នុងស្ថាប័នអយ្យការអមសាលាដំបូង ជាអ្នកទទួលបន្ទុកស្វែងរកបទល្មើសព្រហ្មទណ្ឌ ធ្វើការចោទប្រកាន់ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ក្នុងនាមជាអ្នកតំណាងឱ្យផលប្រយោជន៍សង្គម។ ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។[2] មានន័យថា ព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងស៊ើបអង្កេត ព្រមទាំងធ្វើការណែនាំណាមួយ ដែលមានប្រយោជន៍ដល់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ហើយអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំឱ្យមានអ្នកជំនួស។ បន្ថែមពីនេះទៅទៀត ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌ និងអាចចូលរួមស្តាប់ចម្លើយ ត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន។[3] ប៉ុន្តែការអនុវត្តដីការសម្រេចចាត់ឱ្យស៊ើបសួរជំនួសមន្ត្រីនរគបាលយុត្តិធម៌ ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។[4]

### ១.២ ព្រះរាជអាជ្ញារង

អង្គការអយ្យការអមសាលាដំបូង ត្រូវបានដឹកនាំដោយព្រះរាជអាជ្ញាមួយរូប និងអមដោយព្រះរាជអាជ្ញារងមួយចំនួនតាមការចាំបាច់។ ព្រះរាជអាជ្ញារង គឺជាអ្នកដែលចូលរួមអនុវត្តមុខងារ និងទទួលខុសត្រូវរួមក្រោមការដឹកនាំរបស់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញារងអាចប្រើប្រាស់អំណាចទាំងអស់ ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ ព្រមទាំងធ្វើការចោទប្រកាន់ចំពោះបទល្មើស ដែលបានកើតមានឡើងក្នុងគោលដៅផ្តន្ទាទោសជនល្មើសតាមផ្លូវច្បាប់។[5] ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន ព្រះរាជអាជ្ញាត្រូវចាត់តាំង ព្រះរាជអាជ្ញារងណាម្នាក់ដើម្បីជំនួសបាន ហើយនៅពេលដែលព្រះរាជអាជ្ញាស្ថិតនៅក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងស្ថានភាពទំនេរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ ឱ្យធ្វើជាព្រះរាជអាជ្ញាស្តីទីជំនួស

[2] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, កថាខណ្ឌទី១ មាត្រា ៣៧។
[3] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, កថាខណ្ឌទី៤ មាត្រា ៣៧។
[4] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, កថាខណ្ឌទី៣ មាត្រា ៥៨។
[5] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៣៨។

ដើម្បីធានាដំណើរការ របស់អយ្យការអមសាលាដំបូងរហូតមានការតែងតាំងព្រះរាជអាជ្ញាជាផ្លូវការ។[6]

**១.៣. ក្រឡាបញ្ជី**

ក្រឡាបញ្ជី ជាមន្ត្រីក្របខណ្ឌនៃក្រសួងយុត្តិធម៌ ដែលមានតួនាទីជាជំនួយរបស់ព្រះរាជអាជ្ញា និងចៅក្រមនៅគ្រប់ដំណាក់កាល។ នៅក្នុងដំណាក់កាលព្រះរាជអាជ្ញា ក្រឡាបញ្ជីត្រូវបានស្ថិតនៅក្រោមការដឹកនាំ និងការបង្គាប់បញ្ជារបស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងដែលខ្លួនស្ថិតនៅអមជានិច្ចសម្រាប់ផ្នែកយុត្តាធិការ ហើយបំពេញតួនាទីជាជំនួយទាំងផ្នែកកិច្ចការរដ្ឋបាល និងការធ្វើចំណាត់ការលើសំណុំរឿងដូចជា៖ ធ្វើការកត់ត្រារាល់ព័ត៌មានតាមរយៈការសាក់សួរ ឬស្តាប់ចម្លើយរបស់ជនជាប់សង្ស័យ ឬជនល្មើស ឬសាក្សី ការធ្វើកំណត់ហេតុ ការធ្វើសេចក្តីព្រាងដីកា ឬសំណុំលិខិតផ្សេងៗសម្រាប់ព្រះរាជអាជ្ញា ការរក្សាទុកសំណុំរឿង ការចុះលេខសំណុំឯកសារ និងការស្រាវជ្រាវរកឯកសារផ្សេងៗ។[7] ប៉ុន្តែ ក្រឡាបញ្ជី មិនអាចបំពេញកិច្ចការ ឬធ្វើការសម្រេច និងសន្និដ្ឋានណាមួយដែលជាសមត្ថកិច្ចរបស់ព្រះរាជអាជ្ញា និងព្រះរាជរងបានឡើយ។

## ផ្នែកទី២ គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ

ដើម្បីធានាបាននូវយុត្តិធម៌ តម្លាភាព អង្គការអយ្យការត្រូវបានបង្កើតឡើង ដោយគោរពនូវគោលការណ៍សំខាន់ៗមួយចំនួន ក្នុងគោលបំណងដើម្បីធានាបាននូវការអនុវត្តមុខងារ របស់ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងនៅក្នុងតុលាការនៃសាលាដំបូង ឱ្យមានឆន្ទៈក្នុងការចោទប្រកាន់ ប្រកបទៅដោយភាពត្រឹមត្រូវ មិនលំអៀង និងមិនមានការប្រកាន់បក្សពួកនៅក្នុងការចោទប្រកាន់ ដែលគោលការណ៍សំខាន់ៗទាំងនោះរួមមាន៖ គោលការណ៍ឯកភាព គោលការណ៍អវិភាគ គោលការណ៍ឯករាជ្យ គោលការណ៍នៃការមិនទទួលខុសត្រូវ និងគោលការណ៍មិនអាចប្តឹងជិតចិត្ត។

**១.២.គោលការណ៍ឯកភាព**

គោលការណ៍ឯកភាព គឺជាគោលការណ៍មួយដែលតម្រូវឱ្យព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតនៅក្រោមការដឹកនាំ និង ការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន។ ក្នុងន័យនេះ តំណាងអយ្យការត្រូវអនុវត្តមុខងាររបស់ខ្លួនក្នុងនាមខ្លួនឯងផ្ទាល់ និងតាមបង្គាប់របស់អ្នកដែលមានឋានានុក្រមខ្ពស់ជាង។ ហើយចំពោះឋានានុក្រមនៃអង្គការអយ្យការទាំងនោះត្រូវបានកំណត់ដូចជា៖[8]

[6] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ,លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤,មាត្រា៣០។

[7] សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃក្រឡាបញ្ជី នៃព្រះរាជាណាចក្រកម្ពុជា មាត្រា១៣។

[8] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា,លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤,កថាខណ្ឌទី១ មាត្រា៧៥។

**- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌៖** គឺជានាយឋានានុក្រម ដែលខ្ពស់ជាងគេនៃអង្គការអយ្យការ។ ហើយស្ថាប័នមួយនេះមានសិទ្ធិអំណាចគ្រប់គ្រាន់ ក្នុងការធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ ទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់។ រីឯអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ជាសេនាធិការឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកិច្ចការទាំងនេះ។

**- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍៖** គឺជានាយឋានានុក្រម នៃមហាអយ្យការអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវធ្វើការក្រោមការដឹកនាំ និងទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ខ្លួន។

**- ព្រះរាជអាជ្ញាអមសាលាដំបូង៖** គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញារងទាំងអស់ នៃអយ្យការអមសាលាដំបូងត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ខ្លួន។

### ២.២. គោលការណ៍អវិភាគ

គោលការណ៍អវិភាគ គឺសំដៅដល់ការកំណត់ឱ្យអង្គការអយ្យការ ក្លាយជាអង្គអវិភាគមួយ មានន័យថា ព្រះរាជអាជ្ញាមានកាតព្វកិច្ចរួមក្នុងមុខងារដូចគ្នា និង អាចជំនួសគ្នាទៅវិញទៅមកបាន ក្នុងស្ថាប័នអយ្យការរបស់ខ្លួន ព្រោះសកម្មភាពនៃការបំពេញមុខងារនោះ ធ្វើឡើងក្នុងក្របខណ្ឌនៃអយ្យការ ដែលខ្លួនកំពុងតែឈរជើង។ តាមគោលការណ៍នេះ តំណាងអយ្យការច្រើនរូប អាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំងរបស់នាយឋានានុក្រម។[9] នៅក្នុងករណីដែលព្រះរាជអាជ្ញាស្ថិតនៅក្នុងស្ថានភាពមិនអាចបំពេញការងាររបស់ខ្លួនបាន ឬក្នុងករណីតំណែងព្រះរាជអាជ្ញាស្ថិតក្នុងភាពទំនេរ នោះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ ឱ្យធ្វើជាព្រះរាជអាជ្ញាស្ដីទីជំនួសបាន ដើម្បីធានានូវដំណើរការរបស់អយ្យការអមសាលាដំបូង រហូតដល់មានការតែងតាំងព្រះរាជអាជ្ញាជាផ្លូវការ។

### ២.៣. គោលការណ៍ឯករាជ្យ

អង្គការអយ្យការ គឺជាអង្គឯករាជ្យដែលមិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្ដីដែលខ្លួននៅអមនោះឡើយ។ ព្រះរាជអាជ្ញាមានសេរីភាព ក្នុងការនិយាយបានដោយសេរីទៅលើអង្គហេតុនៃការសាកសួរដេញដោល ដើម្បីរកភស្តុតាងមកធ្វើការដាក់បន្ទុកក្នុងការចោទប្រកាន់លើជនជាប់ចោទនៅពេលសវនាការ។ ក្នុងនោះសាលាជម្រះក្ដីទាំងឡាយ គ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញានោះទេ ទោះបីជាក្នុងករណី

[9] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា,លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, កថាខណ្ឌទី២ មាត្រា៧៥។

ដែលព្រះរាជអាជ្ញាមានកំហុសឆ្គងក្នុងការបំពេញមុខងារយ៉ាងណាក៏ដោយ ក៏សាលាជម្រះក្តីមិនត្រូវចុះសេចក្តីសម្រេចរបស់ខ្លួន យកការស្តីបន្ទោសអ្វី ចំពោះព្រះរាជអាជ្ញាឡើយ។ ប៉ុន្តែសាលាជម្រះក្តីអាចលើកសំណើទៅនាយឋានានុក្រមរបស់ព្រះរាជអាជ្ញា អំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញាបាន។[10]

### ២.៤. គោលការណ៍នៃការមិនទទួលខុសត្រូវ

ព្រះរាជអាជ្ញាក្នុងនាមជាអ្នកតំណាងឱ្យរដ្ឋ អាចធ្វើការចោទប្រកាន់ចំពោះអង្គហេតុទាំងឡាយណាដែលខ្លួនយល់ឃើញថាជាបទល្មើសព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញាមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីណាមួយចំពោះការសម្រេច ដែលបានធ្វើក្នុងក្របខណ្ឌសមត្ថកិច្ច និងមុខងាររបស់ខ្លួនក្នុងឋានៈជាព្រះរាជអាជ្ញាឡើយ។ ក្នុងករណីខ្លះ អង្គហេតុដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់នោះ អាចនឹងត្រូវបានច្រានចោលដោយចៅក្រមស៊ើបសួរ ឬចៅក្រមជំនុំជម្រះ ប្រសិនបើអង្គហេតុនោះ មិនមែនជាបទល្មើសព្រហ្មទណ្ឌ ឬមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីកំណត់ធាតុផ្សំនៃបទល្មើសសម្រាប់ដាក់បន្ទុក។ ហេតុដូចនេះ ព្រះរាជអាជ្ញាមិនអាចត្រូវទទួលខុសត្រូវរាល់ការខូចខាតទាំងឡាយដែលកើតចេញពីការសម្រេចចិត្តរបស់ខ្លួនណាមួយឡើយ ជាពិសេសជនត្រូវចោទ ឬជនជាប់ចោទនៅក្នុងសំណុំរឿងចោទប្រកានរបស់ខ្លួនឡើយ។ ប៉ុន្តែគោលការណ៍នៃការមិនទទួលខុសត្រូវ មិនអាចនាំឱ្យព្រះរាជអាជ្ញារួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានទេ ក្នុងករណីព្រះរាជអាជ្ញាបានប្រើប្រាស់ការសម្រេចរបស់ខ្លួនដោយការរំលោភបំពានធ្ងន់ធ្ងរក្នុងចេតនាទុច្ចរិត លើសមត្ថកិច្ច និងមុខងារដែលច្បាប់បានប្រគល់ឱ្យ។

### ២.៥. គោលការណ៍មិនអាចប្តឹងជិតចិត្ត

ក្នុងរឿងព្រហ្មទណ្ឌ អង្គការអយ្យការដែលមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដែលជាតំណាងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត មិនអាចត្រូវបានភាគីណាមួយអាចប្តឹងជិតចិត្តបានទេ បើទោះបីជាព្រះរាជអាជ្ញាមានការជាប់ពាក់ព័ន្ធនឹងសាច់ញាតិ ឬមានផលប្រយោជន៍ក្នុងបណ្តឹងក៏ដោយ ក៏ភាគីណាមួយមិនអាចប្តឹងជិតចិត្តបានដែរ ដោយហេតុថា ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ក្នុងនាមជាអ្នកតំណាងឱ្យរដ្ឋ តំណាងឱ្យផលប្រយោជន៍ទូទៅរបស់សង្គម មិនមែនតំណាងឱ្យខ្លួនឯងនោះទេ។ ហើយការចោទប្រកាន់នេះទៀតសោតក៏មិនមែនមានន័យថា បុគ្គលដែលជាជនត្រូវចោទ ឬជនជាប់ចោទនឹងត្រូវរងការផ្តន្ទាទោសដូចទៅនឹងការចោទប្រកាន់របស់ព្រះរាជអាជ្ញាឡើយ។ ដូចនេះព្រះរាជអាជ្ញាមិនអាចក្លាយជាកម្មវត្ថុ នៃការធ្វើបណ្តឹងជិតចិត្តបានទេក្រៅពីគោលការណ៍ទាំងឡាយខាងលើ ព្រះរាជអាជ្ញាទាំងអស់ត្រូវអនុវត្តមុខងារ និងតួនាទីរបស់ខ្លួនដោយឈរ

[10] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា,លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, កថាខណ្ឌទី៣ មាត្រា៧៥។

លើគោលការណ៍គោរពច្បាប់ ដោយមិនទទួលការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោល ពីភាគីណាមួយក្នុងរឿងក្តី ឬពីបុគ្គលណាមួយឡើយ។[11]

## ផ្នែកទី៣ សមត្ថកិច្ច តួនាទី ភារកិច្ច និងអំណាចរបស់ព្រះរាជអាជ្ញា

នៅតាមសាលាដំបូងនីមួយៗត្រូវតែមានអង្គការអយ្យការនៅអមជានិច្ច ដែលអង្គការអយ្យការនេះដែរត្រូវបានដឹកនាំដោយព្រះរាជអាជ្ញាមួយរូប និងព្រះរាជអាជ្ញារងជាច្រើនរូបតាមការចាំបាច់ ក្នុងគោលបំណងដើម្បីធានាបាននូវនិរន្តរភាព ភាពយុត្តិធម៌ តម្លាភាព និងការប្រព្រឹត្តទៅនៃអយ្យការឱ្យមានភាពប្រសើរឡើង។ ជាពិសេសក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់អំពីដែនសមត្ថកិច្ចរបស់ព្រះរាជអាជ្ញាយ៉ាងច្បាស់លាស់ រួមមានសមត្ថកិច្ច តួនាទី ភារកិច្ច និង អំណាចរបស់ព្រះរាជអាជ្ញា ដើម្បីជៀសវាងនូវរាល់ការកើតឡើងនូវវិវាទផ្សេងៗនៅក្នុងដំណាក់កាលអយ្យការអមសាលាដំបូង។

### ៣.១. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា

ក្នុងករណីដែលមានបទល្មើសមួយកើតឡើង ច្បាប់បានផ្តល់សិទ្ធិឱ្យព្រះរាជអាជ្ញាអាចធ្វើការស្រាវជ្រាវទៅលើបទល្មើសណាមួយ ដែលអាចធ្វើឡើងជាច្រើនទីកន្លែងតាមការកំណត់ ហើយរាល់កន្លែងដែលពាក់ព័ន្ធទៅនឹងបទល្មើសទាំងនោះរួមមាន ទីតាំងប្រព្រឹត្តបទល្មើស ទីលំនៅរបស់ជនសង្ស័យរស់នៅ និងទីកន្លែងចាប់ខ្លួនជនសង្ស័យ។ ហេតុដូច្នេះហើយ ដើម្បីមានភាពងាយស្រួល ក្នុងដំណើរការនីតិវិធីរបស់ព្រះរាជអាជ្ញា លើការស្រាវជ្រាវបទល្មើសណាមួយ ទើបក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ អំពីសមត្ថកិច្ចរបស់ព្រះរាជអាជ្ញា ដោយមានការបែងចែកដែនដីដូចជា៖[12]

- ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើស។

ទីកន្លែងទាំងបីនេះ ព្រះរាជអាជ្ញានៅទីកន្លែងនីមួយៗសុទ្ធតែមានសមត្ថកិច្ចចំណាត់ការលើរឿងក្តីទាំងអស់។ ក្នុងករណីដែលមានវិវាទសមត្ថកិច្ចដែនដីនោះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជាអ្នកមានសមត្ថកិច្ចក្នុងការធ្វើសេចក្តីសម្រេចថា តើព្រះរាជអាជ្ញារូបណាដែលមានសមត្ថកិច្ចដែនដី ក្នុងចំណាត់ការនៃសំណុំរឿងក្តីព្រហ្មទណ្ឌនោះ ដោយមានម្ចាស់បណ្តឹងតែមួយ ប្តឹងមកព្រះរាជអាជ្ញា មានសមត្ថកិច្ចដែនដីរៀងៗខ្លួន។[13]

[11] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា,លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៧៧។

[12] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៣៩។

[13] ផៀង សំណាង,នីតិវិធីព្រហ្មទណ្ឌ,(ភ្នំពេញ,២០១៩),ទំព័រ ៧៣។

### ៣.២. តួនាទីរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាបានដើរតួនាទីយ៉ាងសកម្មក្នុងដំណើរការ នីតិវិធីព្រហ្មទណ្ឌ រួមទាំងស្ថាប័នអយ្យការដែលច្បាប់បានអនុញ្ញាត ឬស្របតាមការអនុវត្តក្នុងស្រុក ក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ពិនិត្យមើលនីត្យានុកូលភាពក្នុងការស៊ើបអង្កេតនានា ពិនិត្យមើលការអនុវត្តសេចក្តីសម្រេចរបស់តុលាការ និងការបំពេញតួនាទីផ្សេងៗទៀតដោយតំណាងឱ្យផលប្រយោជន៍សាធារណៈ។ បន្ថែមពីនេះ ព្រះរាជអាជ្ញាត្រូវបំពេញតួនាទីរបស់ខ្លួនឱ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់ និងឱ្យបានឆាប់រហ័ស ស្របតាមច្បាប់កំណត់ ហើយត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស និងលើកកម្ពស់សិទ្ធិមនុស្ស ដែលជាការរួមចំណែកមួយក្នុងការធានាដល់កិច្ចដំណើរការនៃប្រព័ន្ធយុត្តិធម៌ឱ្យបានត្រឹមត្រូវ និងមានភាពរលូន។[14]

### ៣.៣. ភារកិច្ចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឱ្យ និង គោរពឱ្យបានម៉ឺងម៉ាត់នូវក្រមសីលធម៌របស់ខ្លួន។ ព្រះរាជអាជ្ញាដែលកំពុងបំពេញមុខងាររបស់ខ្លួននៅតាមអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ត្រូវសុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មុននឹងផ្សាយ ឬសុំឱ្យផ្សាយតាមគ្រប់មធ្យោបាយទាំងអស់នូវអត្ថបទ ឬការសរសេរសំណៅព្រមទាំងមតិផ្សេងៗ ដែលអាចប៉ះពាល់ដល់កិត្យានុភាពនៃស្ថាប័នអយ្យការ ឬស្ថាប័នតុលាការ។[15] ក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាត្រូវ៖[16]

- អនុវត្តមុខនាទីរបស់ខ្លួនដោយមិនលំអៀង និងជៀសវាងរាល់ការរើសអើងភេទ វប្បធម៌ ជាតិសាសន៍ សាសនា ឋានៈសង្គម នយោបាយ ឬការរើសអើងណាមួយផ្សេងទៀត ។
- ការពារផលប្រយោជន៍សាធារណៈ យកចិត្តទុកដាក់ចំពោះជនសង្ស័យ និងជនរងគ្រោះដោយមិនលំអៀង និងត្រូវប្រុងប្រយ័ត្នគ្រប់ស្ថានភាពដែលពាក់ព័ន្ធទាំងអស់ ទោះជាស្ថានភាពនោះមានប្រយោជន៍ ឬឥតមានប្រយោជន៍ដល់ជនសង្ស័យក៏ដោយ ។
- រក្សារឿងក្តីជាការសម្ងាត់ លើកលែងតែត្រូវបំពេញភារកិច្ច ឬបើពុំដូច្នោះទេ គឺជាតម្រូវការរបស់តុលាការដើម្បីបញ្ជាក់ពីភាពយុត្តិធម៌ ។

---

[14] គោលការណ៍ស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី, ២៧ សីហា ដល់ ០៧ កញ្ញា ១៩៩០។

[15] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា,លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, កថាខណ្ឌទី១ មាត្រា៩៦។

[16] គោលការណ៍ស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី, ២៧ សីហា ដល់ ០៧ កញ្ញា ១៩៩០។

- ពិនិត្យមើលពីទិដ្ឋភាពទូទៅ និងក្តីបារម្ភរបស់ជនរងគ្រោះ នៅពេលដែលមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគេ និងបញ្ជាក់ប្រាប់ពីសិទ្ធិរបស់ជនរងគ្រោះដល់ជនរងគ្រោះ ដើម្បីឱ្យស្របតាមសេចក្តីប្រកាសស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋាន របស់ជនរងគ្រោះក្នុងរឿងព្រហ្មទណ្ឌ និង ការរំលោភអំណាច។

**៣.៤.អំណាចរបស់ព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញាមានអំណាចលើចៅក្រមអយ្យការទាំងអស់ ដែលមានក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ព្រះរាជអាជ្ញាបែងចែកព្រះរាជអាជ្ញារងអមសាលាដំបូង នៅក្នុងក្រុមការងារផ្សេងៗនៃអង្គការអយ្យការ និងនៅក្នុងអង្គជំនុំជម្រះ។ ព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាអោយចៅក្រមអយ្យការចោទប្រកាន់ ឬចាត់ឱ្យធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ។[17] ព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត-រាជធានីមានសិទ្ធិអំណាចដូចខាងក្រោម៖[18]

- ដឹកនាំ និង សម្របសម្រួលសកម្មភាពរបស់មន្ត្រី និង ភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។
- ប្រើប្រាស់អំណាចទាំងអស់ដែលក្រមនីតិវិធីព្រហ្មទណ្ឌទទួលស្គាល់ឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ស៊ើបអង្កេត។
- អាចចុះទៅកាន់កន្លែងស៊ើបអង្កេត និង ធ្វើគ្រប់ការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌។
- អាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញា អាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យវិធានការឃាត់ខ្លួន ជាពិសេស គឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន។

[17] ច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការ និងអយ្យការ,មាត្រា៦៦។

[18] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៣៧។

# ជំពូកទី២

# ជំពូកទី២
# កិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញា

នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ដំណាក់កាលចោទប្រកាន់ គឺជាដំណាក់កាលមួយដែលអនុវត្ត ដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា គឺជាម្ចាស់បណ្តឹងអាជ្ញានៅក្នុងការធ្វើបណ្តឹង និងចោទប្រកាន់ជនល្មើស។ បណ្តឹងអាជ្ញានេះអនុវត្តលើគ្រប់បុគ្គលទាំងអស់ ទាំងរូបវន្តបុគ្គល និងនីតិបុគ្គលដោយឥតប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គមធនធាន ឬស្ថាន ភាពឯទៀតឡើយ។[19] មួយវិញទៀតការចោទប្រកាន់ត្រូវបានធ្វើឡើង បន្ទាប់ពីព្រះរាជអាជ្ញាទទួលបាននូវពាក្យ ប្តឹង និងពាក្យបរិហាដែលទាក់ទង់ទៅនឹងរឿងបទល្មើសព្រហ្មទណ្ឌណាមួយបានកើតឡើង ហើយត្រូវបានទទួល ដោយផ្ទាល់ពីសំណាក់ជនរងគ្រោះ ព្រមទាំងបុគ្គលដទៃផ្សេងទៀតក្រៅពីជនរងគ្រោះ ឬដោយមន្រ្តីនគរបាល យុត្តិធម៌ដែលបញ្ជូនមក។[20] យោងតាមស្មារតីនៃមាត្រា ៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងជាកាតព្វកិច្ច សម្រាប់អាជ្ញាធរសាធារណៈ និងមន្រ្តីគ្រប់រូបនៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ខណៈខ្លួនបានដឹងពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយបានកើតឡើង ត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ឬមន្រ្តីនគរបាលយុត្តិធម៌ដែលនៅជិត និងកន្លែងកើតហេតុ ។ ជាគោលការណ៍ ក្រោយពេលទទួលបាននូវព័ត៌មានទាក់ទងទៅនឹងបទល្មើសព្រហ្មទណ្ឌ ណាមួយនោះ នៅមុនពេលធ្វើចំណាត់ការនៅលើសំណុំរឿងដែលទទួលបាន ព្រះរាជអាជ្ញាបើកនូវការស៊ើប អង្កេតបឋម ឬបង្គាប់ឱ្យមន្រ្តីនគរបាលយុត្តិធម៌ ធ្វើការស្រាវជ្រាវបន្ថែម ដែលសំដៅដល់ការប្រមូលនូវព័ត៌មានបំភ្លឺ បន្ថែមទៀត ដើម្បីអាចធ្វើជាមូលដ្ឋានដ៏សំខាន់មួយ សម្រាប់ធ្វើការវាយតម្លៃ ព្រមទាំងថ្លឹងថ្លែង ដោយកំណត់ ចំណាំនៅលើសំណុំរឿងនោះឱ្យបានត្រឹមត្រូវ និងច្បាស់លាស់មុននឹងព្រះរាជអាជ្ញាធ្វើការចោទប្រកាន់។ ក្នុងនោះ ព្រះរាជអាជ្ញា ដែលតាំងខ្លួនជាម្ចាស់បណ្តឹងអាជ្ញា តែងតែប្រកាន់ខ្ជាប់នូវតួនាទីរបស់ខ្លួន ក្នុងការធានាសណ្តាប់ ធ្នាប់សាធារណៈ និងការពារផលប្រយោជន៍ទូទៅ ដូចនេះព្រះរាជអាជ្ញាមិនអាចបដិសេធសំណុំរឿងណាមួយ ដោយមិនធ្វើការចោទប្រកាន់នោះទេ បើសំណុំរឿងនោះ ត្រូវបានពិនិត្យឃើញថាមានអត្ថិភាពនៃបទល្មើស និង ជនល្មើសមានពិរុទ្ធភាព ហើយមានស្ថានភាពចាំបាច់ដើម្បីសម្រេចធ្វើការចោទប្រកាន់។

តើអ្វីទៅជាការចោទប្រកាន់របស់ព្រះរាជអាជ្ញា? ការចោទប្រកាន់របស់ព្រះរាជអាជ្ញា គឺជាចំណាត់ការ មួយដែលមានអានុភាព ផ្ទេរសមត្ថកិច្ចពីអយ្យការ ទៅយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ ដែលជាការ បញ្ជូនជនល្មើសមួយ ឬច្រើននាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ ឬចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌដើម្បី

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៣។

[20] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤០។

ធ្វើការផ្តន្ទាទោសតាមប្បញ្ញត្តិច្បាប់។ ដោយយោងទៅតាមមាត្រា ៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ការចោទប្រកាន់នេះអាចធ្វើឡើងដោយស្តែងតាមនីតិវិធី៣ (បី)យ៉ាងគឺៈ

- **ផ្នែកទី១ ការបើកការស៊ើបសួរ** (RI)
- **ផ្នែកទី២ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់** (CD)
- **ផ្នែកទី៣ ការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម** (CI)

## ផ្នែកទី១. ការបើកការស៊ើបសួរ (RI)

ការបើកការស៊ើបសួរត្រូវធ្វើឡើងដោយមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាលិខិតចោទប្រកាន់របស់តំណាងអយ្យការ ចំពោះបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព ដើម្បីស្នើសុំឱ្យយុត្តាធិការស៊ើបសួរ ធ្វើការស៊ើបអង្កេតលើអង្គហេតុ ដើម្បីបានបង្ហាញពីរឿងហេតុ ដែលបានកើតឡើងនៅក្នុងបទល្មើស។

### ១.១. លក្ខខណ្ឌដែលនាំឱ្យមានការបើកការស៊ើបសួរ

ជាទូទៅមិនមែនគ្រប់បទល្មើសទាំងអស់សុទ្ធតែត្រូវធ្វើការស៊ើបសួរនោះឡើយ ហើយក៏មិនមែនមានន័យថាគ្រប់បទល្មើសទាំងអស់នោះ ព្រះរាជអាជ្ញាបើកការស៊ើបសួរនោះដែរ នៅក្នុងការសម្រេចពីបញ្ហានេះ គឺព្រះរាជអាជ្ញាត្រូវតែគោរពតាមលក្ខខណ្ឌដែលច្បាប់បានបញ្ញត្តិទុក។ ជាក់ស្តែងដោយយោងតាមមាត្រា ១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានបញ្ញត្តិអំពីប្រភេទនៃបទល្មើស ដែលអាចធ្វើការស៊ើបសួរបានមាន ២ (ពីរ) ប្រភេទ គឺបទឧក្រិដ្ឋ និងបទមជ្ឈិម។

#### ១.១.១. ការបើកការស៊ើបសួរចំពោះបទឧក្រិដ្ឋ

ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់ផ្សេងក្រៅតែពីបើកការស៊ើបសួរនោះឡើយ ដែលវាមានលក្ខណៈដាច់ខាតត្រូវតែគោរព។[21] ចំពោះការស៊ើបសួរនេះដែរ ត្រូវបានធ្វើឡើងតាមតាមរយៈដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ដែលដីកាមួយនេះត្រូវប្តឹងទៅចៅក្រមស៊ើបសួរ ហើយការស៊ើបសួរនេះអាចធ្វើឡើងប្រឆាំងទៅលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានការចង្អុលប្រាប់ឈ្មោះ ឬធ្វើឡើងដើម្បីប្រឆាំងទៅលើអញ្ញាតជន។[22] គ្រប់បទឧក្រិដ្ឋទាំងអស់ មិនត្រូវជំនុំជម្រះដោយពុំបានឆ្លងកាត់ដំណាក់កាលនៃការបើកការស៊ើបសួរនោះឡើយ ដោយហេតុថារាល់បទឧក្រិដ្ឋទាំងអស់ វាជាប្រភេទបទល្មើសមួយដែលមានលក្ខណៈធ្ងន់ធ្ងរ ដែលអប្បបរមានៃទោសរបស់វាគឺ ទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ (ប្រាំ)ឆ្នាំ និងទោស

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១២២។
[22] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៤។

ដាក់ពន្ធនាគារក្រោម ឬស្មើ ៣០ (សាមសិប) ឆ្នាំ និង ទោសដាក់ពន្ធនាគារអស់មួយជីវិត។[23]

### ១.១.២. ការបើកការស៊ើបសួរចំពោះបទមជ្ឈិម

ច្បាប់បានកំណត់ថានៅក្នុងបទល្មើសមជ្ឈិម ព្រះរាជអាជ្ញាអាចប្រើនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ នីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ហើយព្រះរាជអាជ្ញាក៏អាចប្រើនីតិវិធីបើកការស៊ើបសួរក៏បាន មិនបើកការស៊ើបសួរក៏បាន ពីព្រោះយើងដឹងហើយថាបទល្មើសមជ្ឈិមខ្លះវាមិនមានលក្ខណៈស្មុកស្មាញនោះទេ មានន័យថា នៅពេលមានបទល្មើសកើតឡើង តុលាការអាចប្រមូលភស្តុតាង ដែលអាចបញ្ជាក់ពីអត្ថិភាពនៃបទល្មើសភ្លាមៗ។[24] ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ត្រូវតែធ្វើការស៊ើបសួរផងដែរ កាលណាបទមជ្ឈិមនោះមិនបានបង្ហាញភស្តុតាងពីពិរុទ្ធភាពឱ្យបានគ្រប់គ្រាន់ ដែលត្រូវធ្វើការស៊ើបសួរ ដើម្បីរកឱ្យឃើញពីអត្ថិភាពនៃបទល្មើសនោះ។[25] ដោយយោងតាមមាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌ បានបញ្ញត្តិថាបទមជ្ឈិម គឺជាទោសដាក់ពន្ធនាគារដែលកម្រិតអតិបរមានៃទោសមានរយៈពេលលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬស្មើ នឹង ៥ (ប្រាំ) ឆ្នាំ ។

## ១.២. នីតិវិធីនៃការបើកការស៊ើបសួរ

នៅក្នុងដំណាក់កាលអយ្យការ នីតិវិធីនៃការបើកការស៊ើបសួរត្រូវបានបែងចែកជា ២ (ពីរ) ដំណាក់កាល គឺ ការបើកការស៊ើបសួរតាមរយៈពាក្យបណ្ដឹងបញ្ជូនមកដោយផ្ទាល់ និងការបើកការស៊ើបសួរតាមរយៈសំណុំរឿងបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌។ ហេតុដូចនេះ មុននឹងសម្រេចបើកការស៊ើបសួរ ព្រះរាជអាជ្ញាត្រូវតែធ្វើការវាយតម្លៃ និងវិនិច្ឆ័យទៅលើសំណុំរឿងនីមួយៗ ដែលបានបញ្ជូនមកឱ្យបានច្បាស់លាស់ជាមុនសិន។

### ១.២.១.ការបើកការស៊ើបសួរតាមរយៈពាក្យបណ្ដឹងបញ្ជូនមកដោយផ្ទាល់

ដើមបណ្ដឹងអាចធ្វើការដាក់ពាក្យបណ្ដឹងដោយផ្ទាល់ ដើម្បីឱ្យព្រះរាជអាជ្ញា ធ្វើចំណាត់ការចំពោះពាក្យបណ្ដឹងនោះ។ បន្ទាប់ពីព្រះរាជអាជ្ញាទទួលបានពាក្យបណ្ដឹងដោយផ្ទាល់ ព្រះរាជអាជ្ញានឹងធ្វើការថ្លឹងថ្លែងសម្រាប់ធ្វើការចោទប្រកាន់តាមនីតិវិធីណាមួយ ប្រសិនបើអង្គហេតុនោះជាបទល្មើស។ ដោយនីតិវិធីនៃការថ្លឹងថ្លែង និងស្រាវជ្រាវត្រូវធ្វើឡើងតាមរយៈការសុំទៅមន្ត្រីនគរបាលយុត្តិធម៌ឱ្យធ្វើការស៊ើបអង្កេតបឋម ឬការកោះហៅដើមបណ្ដឹង ជនសង្ស័យ សាក្សី ដើម្បីសាកសួរ និងស្ដាប់ចម្លើយដោយផ្ទាល់។ បន្ទាប់ពីការស៊ើបអង្កេត និងស្រាវជ្រាវបានបញ្ចប់ ប្រសិនបើអង្គហេតុនោះជាបទល្មើស ហើយបានបំពេញលក្ខខណ្ឌនៃការបើកការស៊ើបសួរដូចបានបកស្រាយខាងលើ ព្រះរាជអាជ្ញានឹងសម្រេចធ្វើការបើកការស៊ើបសួរតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

[23] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៤៦ ។

[24] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៥។

[25] កែវ សុភ័ណ្ឌ,ជម្រើសនៃការចោទប្រកាន់របស់តំណាងអយ្យការ,២០២០៖០៦។

### ១.២.២.ការបើកការស៊ើបសួរតាមរយៈសំណុំរឿងបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌

ការបើកការស៊ើបសួរក៏ធ្វើទៅបានផងដែរ ក្រោយពីបានទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ ដែលមន្ត្រីនគរបាលយុត្តិធម៌បានទទួលបានពាក្យបណ្តឹងពីជនរងគ្រោះ ឬអ្នកតំណាងរបស់ជនរងគ្រោះ ទាមទារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌នឹងធ្វើការបើកការស៊ើបអង្កេតបឋម ចំពោះរាល់បណ្តឹងដែលមន្ត្រីនគរបាលយុត្តិធម៌ទទួលបាន ឬនៅពេលដែលមានបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុណាមួយ រួចបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ជាពិសេសនោះ នៅពេលមានបទល្មើសជាក់ស្តែងកើតឡើង មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិក្នុងការចាប់ខ្លួន ឬឃាត់ខ្លួនទៅលើជនសង្ស័យ និងបញ្ជូនខ្លួនជនសង្ស័យទៅចំពោះមុខព្រះរាជអាជ្ញា។ ចំពោះនីតិវិធីនៃការអនុវត្តលើចំណាត់ការនៃរឿងក្តី ដែលត្រូវបានបញ្ជូនមកមន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើឡើងក្រោមរូបភាពដូចខាងក្រោម៖

**ក. ករណីសំណុំរឿងគ្មានវត្តមានជនសង្ស័យ (ជនសង្ស័យនៅក្រៅឃុំ)**

សំណុំរឿងគ្មានវត្តមានជនសង្ស័យ គឺជាសំណុំរឿងដែលបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ដោយជនសង្ស័យនោះមិនទាន់ត្រូវបានឃាត់ខ្លួននៅឡើយទេ ហើយក៏មិនទាន់បញ្ជូនសំណុំរឿនោះមកព្រះរាជអាជ្ញាដែរ។ នៅពេលដែលព្រះរាជអាជ្ញាទទួលបានសំណុំរឿងហើយ នោះព្រះរាជអាជ្ញានឹងធ្វើការថ្លឹងថ្លែងអង្គហេតុ ដោយពិនិត្យមើលភស្តុតាងដែលមានក្នុងសំណុំរឿង របាយការណ៍សង្ខេបរបស់មន្ត្រីនគរបាលយុត្តិធម៌ និងធ្វើការកោះហៅដើមបណ្តឹង ជនសង្ស័យ និងសាក្សី ដើម្បីសួរនាំ និងស្តាប់ចម្លើយ។ បន្ទាប់មកប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាអង្គហេតុខាងលើ គឺជាបទល្មើស ហើយក៏បានបំពេញតាមលក្ខខណ្ឌដែលតម្រូវឱ្យព្រះរាជអាជ្ញាបើកការស៊ើបសួរនោះ ព្រះរាជអាជ្ញានឹងចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដោយកំណត់ឈ្មោះជនត្រូវចោទម្នាក់ ឬច្រើននាក់ ឬអញ្ញាតជន ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

**ខ. ករណីសំណុំរឿងមានវត្តមានជនសង្ស័យ (ជនសង្ស័យជាប់ឃុំខ្លួន)**

សំណុំរឿងមានវត្តមានជនសង្ស័យ សំដៅដល់សំណុំរឿងដែលជនសង្ស័យត្រូវបានចាប់ខ្លួន និងឃាត់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌ ហើយនិងត្រូវនាំមកបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា បន្ទាប់ពីផុតរយៈពេលឃាត់ខ្លួនបណ្តោះអាសន្នរបស់មន្ត្រីនគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញានឹងធ្វើការពិនិត្យទៅលើតែអង្គហេតុ និង ភស្តុតាងដែលជារបាយការណ៍សំយោគនៃសំណុំរឿង ដែលមន្ត្រីនគរបាលយុត្តិធម៌បានធ្វើការសន្និដ្ឋានក្រោយពីបានស្តាប់ចម្លើយជនត្រូវចោទ។ ប្រសិនបើព្រះរាជអាជ្ញាពិនិត្យទៅលើសំណុំរឿងរួចហើយ យល់ឃើញថាជាបទល្មើសនោះ ហើយក៏បានបំពេញតាមលក្ខខណ្ឌក្នុងការបើកការស៊ើបសួរទៀត នោះព្រះរាជអាជ្ញានឹង

ចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយព្រះរាជអាជ្ញាក៏អាចសន្និដ្ឋានសុំឱ្យចៅក្រមស៊ើបសួរសម្រេចដាក់ជនត្រូវចោទ ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬសន្និដ្ឋានសុំឱ្យដាក់ជនត្រូវចោទស្ថិតក្រោមការឃុំខ្លួនបណ្ដោះអាសន្នផងដែរ។

### ១.៣. ទម្រង់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ចំពោះនីតិវិធីនៃការបើកការស៊ើបសួរ ត្រូវតែមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទើបកិច្ចនៃការស៊ើបសួរនេះអាចដំណើរការទៅបាន ហើយដីកានេះត្រូវធ្វើឡើងតាមទម្រង់ការមួយជាក់លាក់ ដើម្បីឱ្យនីតិវិធីនេះមានអានុភាពស្របតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

យោងតាមមាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានបញ្ញត្តិអំពីទម្រង់ការនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដូចតទៅ៖

- **សេចក្ដីសង្ខេបអង្គហេតុ៖** ចំណុចនេះមានសារៈសំខាន់ណាស់ ពីព្រោះបើគ្មានអង្គហេតុណាមួយទេនោះ ចៅក្រមស៊ើបសួរនឹងមិនដឹងថា កិច្ចស៊ើបសួរនឹងត្រូវស្វែងទៅលើអង្គហេតុណាមួយទេ ព្រោះកិច្ចស៊ើបសួរអាចបើកបានតែទៅលើអង្គហេតុណា ដែលព្រះរាជអាជ្ញាចោទប្រកាន់មកតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត បើគ្មានអង្គហេតុ ក៏គ្មានកិច្ចចោទប្រកាន់ណាមួយកើតមានដែរ។

- **ការកំណត់ឈ្មោះបទល្មើស៖** ការកំណត់ឈ្មោះបទល្មើសវាមានសារៈប្រយោជន៍សម្រាប់ជំហានដំបូងនៃកិច្ចស៊ើបសួរ ព្រោះចៅក្រមស៊ើបសួរនឹងមិនអាច ឬមិនទាន់អាចកំណត់ថាអង្គហេតុជាបទល្មើសអ្វីលុះបិទកិច្ចស៊ើបសួរសិនទើបមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការសម្រេចថា អង្គហេតុនេះជាបទល្មើសអ្វីនោះ។ ដូចនេះពិតជាមានភាពលំបាកប្រសិនបើមិនមានការកំណត់ឈ្មោះបទល្មើសណាមួយសម្រាប់បើកកិច្ចស៊ើបសួរ ទោះជាមានការកំណត់ពីឯករាជ្យភាពរបស់ចៅក្រមស៊ើបសួរ លើការកំណត់បទល្មើសណាមួយជាមុនក៏ដោយនេះគ្រាន់តែគិតទៅលើស្មារតីនៃផលប្រយោជន៍តែប៉ុណ្ណោះ ប៉ុន្តែកត្តាចម្បងនេះ បើព្រះរាជអាជ្ញាសម្រេចចោទប្រកាន់ខាងបទព្រហ្មទណ្ឌ តែមិនឃើញមានសរសេរថាចោទពីបទណាមួយនោះទេ ដូច្នេះត្រូវចាត់ទុកថាគ្មានការចោទប្រកាន់ ពីបទព្រហ្មទណ្ឌណាមួយឡើយ។

- **ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស៖** ការកំណត់នេះ គឺជាកត្តាមូលហេតុដែលព្រះរាជអាជ្ញាអះអាងពីឈ្មោះបទល្មើស តែបើមិនសរសេរចូលក្នុងដីកា មានន័យថាគ្មានមូលដ្ឋាននៃការអះអាងលើការចោទប្រកាន់ទេ។ នេះគ្រាន់ជាការកំណត់ពីភាពច្បាស់លាស់នៅកិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញាប៉ុណ្ណោះ។

**- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរប្រសិនបើអាចកំណត់បាន៖** ចំណុចនេះបើបុគ្គលជាជនល្មើសត្រូវបានស្គាល់អត្តសញ្ញាណ គឺត្រូវតែមានកំណត់ឈ្មោះរបស់ជនល្មើសនោះ ក៏ប៉ុន្តែទោះជាមិនមានក៏មិនអីដែរ ព្រោះកិច្ចស៊ើបសួរអាចបើកប្រឆាំងគ្រប់បុគ្គល ដែលមានតម្រុយពិរុទ្ធភាពពាក់ព័ន្ធជាមួយអង្គហេតុ ទោះជាមិនមានកំណត់ឈ្មោះរបស់ជនល្មើសក៏ដោយ។

ដីកានេះចាំបាច់ត្រូវតែមានការចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា។ នេះជាទម្រង់រដ្ឋបាលដែលត្រូវតែមាន តែបើគ្មានហត្ថលេខា មានន័យថាមិនមានការទទួលស្គាល់ណាមួយរបស់ព្រះរាជអាជ្ញានោះទេ ដែលជាហេតុធ្វើឱ្យដីកានេះមិនមានអានុភាព ឬដីកាមិនទាន់មានការសម្រេចរបស់ព្រះរាជអាជ្ញានៅឡើយ ដូច្នេះគ្មានកិច្ចចោទប្រកាន់ណាមួយកើតមានទេ។ ដោយយោងតាមសារៈសំខាន់នៃទម្រង់ការដែលមិនអាចខ្វះបាន ទោះជាស្មារតីនៃផលប្រយោជន៍ ឬជាស្មារតីនៃច្បាប់ក៏ដោយ ទម្រង់នេះត្រូវបានកំណត់ជាលក្ខណៈដាច់ខាតដែលត្រូវតែគោរព បើមិនដូច្នេះទេដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ។

### ១.៤. អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ក្រោយពីព្រះរាជអាជ្ញាសម្រេចចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើសសួរទៅចៅក្រមស៊ើបសួររួចហើយ នាំឱ្យដីកានេះបានបង្កើតឱ្យមានអានុភាពមួយចំនួនដូចជា៖ ការផ្តាច់រយៈពេលនៃអាជ្ញាយុកាលនៃបទល្មើស និងការកំណត់អំពីវិសាលភាពនៃការស៊ើបសួរ។

**- ការផ្តាច់រយៈពេលនៃអាជ្ញាយុកាលនៃបទល្មើស៖** ជាគោលការណ៍ចិរវេលានៃបទល្មើសព្រហ្មទណ្ឌត្រូវបានចាប់ផ្តើមគិតពីពេលមានការប្រព្រឹត្តបទល្មើសកើតឡើង ប៉ុន្តែចិរវេលានៃបទល្មើសនេះ ក៏រលត់ទៅវិញដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ ។[26] ក្នុងន័យនេះគ្រប់កិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញា មិនថាតាមរយៈការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ការបញ្ជូនទៅជំនុំជម្រះភ្លាម និងការបើកការស៊ើបសួរ ដែលវាជាសញ្ញាណនៃការចោទប្រកាន់មួយ ដែលនាំឱ្យមានការផ្តាច់អាជ្ញាយុកាលនៃបទល្មើស។ ចំណែកឯគ្រប់កិច្ចនៃការស៊ើបសួរ សំដៅដល់កិច្ចដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ដែលកិច្ចនេះក៏មានអានុភាពផ្តាច់អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាផងដែរ។

**- ការកំណត់វិសាលភាពនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ៖** មានន័យថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មានអានុភាពកំណត់អំពីវិសាលភាពនៃកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ ហើយការស៊ើបសួរត្រូវបើកតាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ដូចនេះចៅក្រមស៊ើបសួរមិន

[26] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១១។

អាចបើកការស៊ើបសួរ ឬបំពេញកិច្ចស៊ើបសួរណាមួយបានដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាបាននោះទេ មានន័យថា ប្រសិនបើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នោះក៏គ្មានចៅក្រមស៊ើបសួរផងដែរ។[27] ចំពោះការស៊ើបសួរ គឺចៅក្រមស៊ើបសួរមានសមត្ថកិច្ចស្រាវជ្រាវបានតែចំពោះអង្គហេតុដែលចង្អុលបង្ហាញ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ។ ម៉្យាងវិញទៀត នៅក្នុងករណីដែលចៅក្រមស៊ើបសួររកឃើញតម្រុយ ឬលេចឡើងនៅអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីអង្គហេតុនោះទៅព្រះរាជអាជ្ញា។ ចំពោះអង្គហេតុថ្មី ព្រះរាជអាជ្ញាអាចចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទៅចៅក្រមស៊ើបសួរ ដើម្បីធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះ ប៉ុន្តែប្រសិនបើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញានោះទេ ចៅក្រមស៊ើបសួរមិនអាចធ្វើការស៊ើបសួរទៅលើអង្គហេតុថ្មីបានឡើយ។ ផ្ទុយទៅវិញប្រសិនបើអង្គហេតុថ្មីនោះជាស្ថានទម្ងន់ទោសទៅលើអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង នោះចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញាទេ។[28]

**ផ្នែកទី២. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់** (CD)

ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីនៃការសម្រេចធ្វើការចោទប្រកាន់ដោយព្រះរាជអាជ្ញា ដើម្បីធានាប្រសិទ្ធភាពនៃស្ថាប័នអយ្យការដោយពន្លឿនការដោះស្រាយសំណុំរឿងឱ្យបានឆាប់រហ័ស និងជៀសវាងការកកស្ទះសំណុំរឿង។ ជនល្មើសត្រូវបានចោទប្រកាន់នៅចំពោះមុខតុលាការជំនុំជម្រះឱ្យបានឆាប់រហ័ស និងទទួលបានការជម្រះនៅក្នុងពេលសមស្រប។ ម្យ៉ាងវិញទៀតការបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះ ជានីតិវិធីមួយដែលអាចយកមកអនុវត្តបាន ចំពោះបទមជ្ឈិមតូចតាច និងគ្រប់បទលហុទាំងអស់ ហើយសំណុំរឿងនេះមានលក្ខណៈគ្រប់គ្រាន់អាចធ្វើការជំនុំជម្រះបាន ទោះជនជាប់ចោទនោះជានីតិជន ឬអនីតិជនក៏ដោយ ក៏នីតិវិធីនេះអាចប្រព្រឹត្តទៅបានផងដែរ។ បន្ថែមពីនេះការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវធ្វើតាមដីកាកោះហៅទៅជំនុំជម្រះផ្ទាល់ ដែលដីកានេះគឺបញ្ជាឱ្យជនជាប់ចោទចូលបង្ហាញខ្លួននៅចំពោះមុខតុលាការជាន់ដំបូង។[29]ក្នុងនោះដើម្បីឱ្យនីតិវិធីនេះអាចប្រព្រឹត្តទៅបាន គឺទាមទាឱ្យគោរពនូវលក្ខខណ្ឌមួយចំនួន ហើយត្រូវអនុវត្តឱ្យស្របទៅតាមនីតិវិធីមួយជាក់លាក់ ដែលនីតិវិធីនេះត្រូវតែធ្វើឡើងតាមទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដើម្បីឱ្យនីតិវិធីនេះមានអានុភាពទៅដល់ចំណាត់ការយុត្តាធិការជំនុំជម្រះផងដែរ។

[27] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១២៥។

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១២៥។

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៦។

## ២.១. លក្ខខណ្ឌនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់

រាល់នីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវមានលក្ខខណ្ឌជាក់លាក់ ដើម្បីធ្វើការចោទប្រកាន់បាន ប៉ុន្តែដោយផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានកំណត់លក្ខខណ្ឌច្បាស់លាស់នោះទេ គ្រាន់តែបញ្ជាក់ពីចំណុចមួយចំនួនដែលអាចឱ្យព្រះរាជអាជ្ញាប្រើប្រាស់នៅក្នុងនីតិវិធីបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ដែលក្នុងនោះរួមមានលក្ខខណ្ឌចំពោះបទល្មើស និងលក្ខខណ្ឌសាវតារបស់ជនល្មើស។

### ២.១.១. លក្ខខណ្ឌនៃបទល្មើស

ជាទូទៅបទល្មើសដែលបានកើតឡើងហើយច្បាប់ទទួលស្គាល់ថាជាបទល្មើស លុះត្រាតែមានចែងនៅក្នុងច្បាប់យ៉ាងជាក់ច្បាស់ថាជាបទល្មើស និងច្បាប់បានកំណតថាវាជាអំពើល្មើស។ អំពើមួយដែលអាចចាត់ទុកថាជាបទល្មើស ត្រូវតែមានធាតុផ្សំគ្រប់គ្រាន់ ដែលនាំឱ្យបទល្មើសនោះកំណត់ចំណាត់ថ្នាក់តាមប្រភេទនៃទម្ងន់ទោសចំពោះរូបភាពនៃអំពើដែលបានប្រព្រឹត្ត។

ជាគោលគំនិតការអនុវត្តនីតិវីធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ អាចធ្វើបានចំពោះតែបទមជ្ឈិម និងបទលហុតែប៉ុណ្ណោះ ដោយសារតែបទល្មើសប្រភេទនេះមានលក្ខណៈស្រាល មិនសូវស្មុគស្មាញ និងមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែលអាចជំនុំជម្រះបាន ដែលវាជាកត្តាមួយ ជួយជម្រុញដល់ការពន្លឿននៃនីតិវិធីតុលាការឱ្យបានឆាប់រហ័ស មិនអូសបន្លាយពេលវេលា និងផ្តល់សេវាយុត្តិធម៌បានល្អប្រសើរ។

**ក. បទមជ្ឈិម**

បទមជ្ឈិម សំដៅដល់បទល្មើសទាំងឡាយណា ដែលមានអតិបរមានៃទោសដាក់ព័ន្ធនាគារដែលត្រូវរងនោះមានរយៈពេលលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោមឬស្មើ ៥ (ប្រាំ) ឆ្នាំ។[30] ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់ដោយប្រើដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់បាន ក្នុងករណីដែលបទល្មើសដែលជាបទមជ្ឈិមនោះមាន លក្ខណៈមិនស្មុគស្មាញ លើសពីនេះទោះជាបទមជ្ឈិមជាក់ស្តែង ឬមិនជាក់ស្តែង ក៏ព្រះរាជអាជ្ញានៅតែអាចចោទប្រកាន់តាមនីតិវិធីនេះបានដែរ។[31] ផ្ទុយទៅវិញ បទមជ្ឈិមអាចជាកម្មវត្ថុនៃការចោទប្រកាន់តាមទម្រង់ជាការបើកការស៊ើបសួរ និងជាការបង្ហាញខ្លួនភ្លាមផងដែរ ព្រោះមានស្ថានភាពនៃបទមជ្ឈិមមួយចំនួនត្រូវបានទទួលឱ្យមានការចោទប្រកាន់តាមនីតិវិធីផ្សេងទៀតបាន ក្នុងនោះយើងឃើញថា ស្ថានភាពនៃបទមជ្ឈិមខ្លះអាចមានករណីមួយចំនួនដែលមានលក្ខណៈស្មុគស្មាញ ឬ ស្ថានភាពដោយឡែកផ្សេងទៀតតម្រូវទាមទារឱ្យមានការបើកការស៊ើបអង្កេតកាលណាមិនទាន់មានភស្តុតាងគ្រប់គ្រាន់ ឬបទល្មើសដែលមិនស្គាល់អត្តសញ្ញាណជនល្មើសជាដើម។

[30] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៤៧ ។

[31] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៥ កថាខណ្ឌទី២។

**ខ. បទលហុ**

បទលហុ គឺសំដៅលើអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលក្រោម ឬ ស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។[32]នៅពេលជនរងគ្រោះដើមបណ្ដឹងរដ្ឋប្បវេណី ឬបុគ្គលផ្សេងទៀតដែលបានដាក់ពាក្យបណ្ដឹង ក្រោយពេលពិនិត្យឃើញថាសំណុំរឿងជាបទលហុ ព្រះរាជអាជ្ញាអាចធ្វើការកោះហៅជនជាប់ចោទឱ្យចូលខ្លួននៅចំពោះមុខតុលាការ ដោយប្រើដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់។[33] ម្យ៉ាងវិញទៀត ដោយសារតែបទលហុ ជាប្រភេទបទល្មើសតូចតាច ប្រសិនបើព្រះរាជអាជ្ញាសម្រេចប្រើនីតិវិធីបើការស៊ើបសួរ ឬការបង្ហាញខ្លួនភ្លាម អាចនាំឱ្យប៉ះពាល់ ឬទទួលរងការបំពានដល់សិទ្ធិសេរីភាពយ៉ាងធ្ងន់ធ្ងររបស់ជនជាប់ចោទ ដោយហេតុថានីតិវិធីនៃការបើកការស៊ើបសួរ ឬការបង្ហាញខ្លួនភ្លាមអនុញ្ញាតឱ្យមានការឃុំខ្លួនជនជាប់ចោទទុករហូតដល់បង្ហាញខ្លួននៅចំពោះមុខតុលាការជំនុំជម្រះ។

**២.១.២. លក្ខខណ្ឌសាវតារបស់ជនល្មើស**

បន្ទាប់ពីព្រះរាជអាជ្ញាកំណត់បានប្រភេទនៃបទល្មើសហើយ គឺទាមទារនូវលក្ខខណ្ឌចាំបាច់មួយចំនួនទៀតក្នុងការស្វែងរកសាវតារបស់ជនល្មើស ព្រោះជាស្មារតីក្នុងការធ្វើបណ្ដឹងអាជ្ញា មិនត្រឹមតែមានគោលបំណងស្វែងរកអត្ថិភាពនៃបទល្មើសទេ អ្វីដែលសំខាន់នោះគឺចង់ឱ្យមានការផ្ដន្ទាទោសចំពោះជនល្មើសទៀតផង។ ការចោទប្រកាន់តាមទម្រង់ជាដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដែលមិនស្គាល់ជនល្មើស គឺមិនអាចប្រព្រឹត្តទៅបានទេ។ ម្យ៉ាងវិញទៀត ក្រមនីតិវិធីបានទទួលស្គាល់វិសាលភាពនៃបណ្ដឹងចំពោះជនជាប់ចោទ គឺមានន័យថាតុលាការនឹងជំនុំជម្រះតែជនណា ដែលមានក្នុងពាក្យដែលប្ដឹងមកខ្លួនប៉ុណ្ណោះ។[34]

ដូចនេះការស្គាល់អត្តសញ្ញាណជនល្មើសជាលក្ខខណ្ឌមួយចាំបាច់ត្រូវតែមានដែលមិនអាចខ្វះបាន។

**២.២. នីតិវិធីនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីមួយដែលមិនឆ្លងកាត់ដំណាក់កាលនៃការស៊ើបសួរទេ មានន័យថា នៅពេលដែលព្រះរាជអាជ្ញាទទួលពាក្យបណ្ដឹងហើយ លក្ខខណ្ឌនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវបានបំពេញ ព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ភ្លាម ហើយត្រូវបញ្ជូនសំណុំរឿងនោះទៅយុត្តាធិការជំនុំជម្រះតាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ និង ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់សម្រាប់កោះហៅជនជាប់ចោទឱ្យចូលសវនាការដើម្បីធ្វើការជំនុំជម្រះ។ ដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាលិខិតដែលព្រះរាជអាជ្ញាអាចបញ្ជូនសំណុំរឿង និងជនជាប់ចោទទៅតុលាការជំនុំជម្រះ។ ចំណែកឯ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺ

[32] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៤៨ ។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៩។

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៣៤៩។

ជាលិខិតចោទប្រកាន់មួយរបស់ព្រះរាជអាជ្ញា ដែលប្រើចំពោះបទមជ្ឈិម ឬ បទលហុ និងមានអានុភាពបញ្ជាជនជាប់ចោទឱ្យចូលបង្ហាញខ្លួននៅចំពោះមុខតុលាការជាន់ដំបូង។[35]

### ២.២.១. ថិរវេលានៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

នៅពេលដែលតុលាការបានទទួលបណ្តឹងដោយការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ប្រធានតុលាការត្រូវតែគិតគូរតាមរយៈពេលដែលមានចែងក្នុងបញ្ញត្តិច្បាប់ ដើម្បីធានាថាជនជាប់ចោទមានរយៈពេលសមរម្យក្នុងការរៀបចំខ្លួនត្រៀមឡើងសវនាការនេះ សម្រាប់ស្ថានភាពខុសគ្នាៗចំពោះទីតាំងដែលជនជាប់ចោទឈរជើងនៅ។[36] ដូចនេះក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ពីរយៈពេលដែលត្រូវគោរព រវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ឱ្យដល់ជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅ៖[37]

-១៥ ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការតុលាការជាន់ដំបូង។

-២០ ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ។

-២ ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា។

-៣ ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត។

ថិរវេលាខាងលើនេះត្រូវតែគោរព បើពុំដូច្នោះទេនឹងនាំឱ្យមានមោឃភាពនៃនីតិវិធី នៃការកោះហៅលើកលែងតែជនជាប់ចោទយល់ព្រមចូលមកបង្ហាញខ្លួនដោយស្ម័គ្រចិត្ត។

### ២.២.២. របៀបនៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ការប្រគល់ដីកាកោះ និងចុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយព្រះរាជអាជ្ញា អាចត្រូវប្រគល់ឱ្យជនជាប់ចោទដោយផ្ទាល់ដៃរបស់ព្រះរាជអាជ្ញា។[38] នៅដើមដីកាដែលមានការចុះការបរិច្ឆេទ ទីកន្លែងកំណើត នៅលំនៅដ្ឋានរបស់ជនជាប់ចោទ ត្រូវមានការចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា។[39] បន្ថែមពីនេះ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ និងទីកន្លែងប្រគល់ដីកានៅលើដើមដីកា ហើយជនជាប់ចោទត្រូវចុះហត្ថលេខានៅដើមដីកានេះ។[40] ម្យ៉ាងវិញទៀតក្រៅពីព្រះរាជអាជ្ញា ដីកានេះក៏អាចត្រូវបានប្រគល់

---

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៦។

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា២៩២។

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៥៧។

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៥៨។

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៥៦។

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៥៨,កថាខណ្ឌទី២។

ដោយបុគ្គលផ្សេងទៀតផងដែរ ដែលបុគ្គលទាំងនោះរួមមាន៖ អាជ្ញាសាលា ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទល្មើសផ្សេងទៀត តាមរយៈអង្គភាពនគបាល ឬកងរាជអាវុធហត្ថ។ យ៉ាងណាមិញ ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធនាគារ មន្ត្រីនគបាលជាតិ ឬអាវុធហត្ថ ដែលព្រះរាជអាជ្ញាសុំឱ្យប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវតែគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា។[41]ក្នុងនោះយើងឃើញថា អាជ្ញាសាលាមិនត្រឹមតែអាចប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បាននោះទេ ក៏ប៉ុន្តែអាជ្ញាសាលាក៏អាចប្រគល់ចុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បានផងដែរ ដោយប្រើគ្រប់មធ្យោបាយដើម្បីប្រគល់ដីកានេះ ឱ្យដល់ជនជាប់ចោទដោយផ្ទាល់ដៃ ឬដល់មេឃុំ ឬចៅសង្កាត់។[42] ក្នុងករណីដែលអាជ្ញាសាលាបានជួបប្រទះជនជាប់ចោទនៅក្នុងផ្ទះ ឬនៅកន្លែងដទៃទៀត អាជ្ញាសាលាត្រូវប្រគល់ចុងដីកាកោះដល់សាមីខ្លួន ដោយចារលើសេចក្តីដើមដីកាថា បានប្រគល់ចុងដីកាដល់ជនជាប់ចោទដោយផ្ទាល់ដៃ និងត្រូវចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់ ព្រមទាំងចុះហត្ថលេខាដោយជនជាប់ចោទលើដើមដីកា ហើយដើមដីកាត្រូវបញ្ជូនវិលត្រឡប់ទៅកាន់ព្រះរាជអាជ្ញាវិញភ្លាម។[43]

លើសពីនេះទៅទៀត ប្រសិនបើជនជាប់ចោទអវត្តមានពីលំនៅឋានរបស់ខ្លួន អាជ្ញាសាលាត្រូវប្រគល់ចុងដីកាឱ្យដល់បុគ្គលទាំងឡាយណា ជានីតិជនដែលមានវត្តមាននៅលំនៅឋាននោះ ដោយឱ្យចុះសេចក្តីលើដើមដីកាថា ចុងដីកាត្រូវប្រគល់ឱ្យបុគ្គលដែលមានវត្តមាននៅលំនៅឋាន ហើយក៏ត្រូវចុះនិទ្ទេសស្តីពីអត្តសញ្ញាណនៃបុគ្គលនោះ និងកាលបរិច្ឆេទនៃការប្រគល់ដីកា ព្រមទាំងចុះហត្ថលេខារបស់បុគ្គលដែលទទួលដីកាដោយសន្យាថា និងប្រគល់ដីកានេះក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយដើមដីកាក៏ត្រូវបង្វិលជូនព្រះរាជអាជ្ញាវិញភ្លាមផងដែរ។[44] បន្ថែមពីនេះ អាជ្ញាសាលា អាចប្រគល់ចុងដីកា ឱ្យដល់មេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង នៅក្នុងករណីដូចតទៅ៖[45]

- ជនជាប់ចោទមិនព្រមទទួលដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទ
- គ្មានបុគ្គលណាម្នាក់ ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទ យល់ព្រមទទួលដីកាទេ។

---

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៦៣។

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៥៩។

[43] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៦០។

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៦១។

[45] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៦២។

នៅពេលដែលអាជ្ញាសាលា ប្រគល់ចុងដីកា ឱ្យដល់មេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង ត្រូវចុះនិទ្ទេសនៅលើដើមដីកា អំពីអត្តសញ្ញាណ និងឋានៈរបស់បុគ្គល ដែលបានទទួលចុងដីកា ព្រមទាំងការបរិច្ឆេទនៃការប្រគល់ដីកា ហើយបុគ្គលដែលទទួលចុងដីកា ត្រូវចុះហត្ថលេខារបស់ខ្លួននៅដើមដីកា និងដើមដីកាត្រូវបង្វិលត្រឡប់ជូនព្រះរាជអាជ្ញាវិញភ្លាម ព្រមទាំងសន្យាថានឹងប្រគល់ដីកានោះក្នុងរយៈពេលដ៏ខ្លីបំផុតឱ្យដល់ជនជាប់ចោទ។ ក្នុងករណីប្រសិនបើជនជាប់ចោទគ្មានលំនៅឋាន ឬទីសំណាក់ ឬក៏រស់នៅក្រៅដែនដីជាតិ ព្រះរាជអាជ្ញា ក៏អាចធ្វើការចោទប្រកាន់លើជនជាប់ចោទនេះ តាមផ្លូវដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បានផងដែរ ហើយកាលបរិច្ឆេទនៃការធ្វើដីកា ត្រូវចាត់ទុកថាជាកាលបរិច្ឆេទនៃការប្រគល់ដីកា។[46]

### ២.២.៣.ផលវិបាកនៃការមិនគោរពរយៈពេលតាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ក្នុងករណីប្រសិនបើការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និង ការបង្គាប់ឱ្យចូលបង្ហាញខ្លួន ពុំបានគោរពតាមរយៈពេលដែលច្បាប់បានកំណត់ទេនោះ វានឹងនាំឱ្យមានផលវិបាក ហើយតុលាការត្រូវមានចំណាត់ការតាមករណីដូចខាងក្រោម៖[47]

- ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួន តុលាការពិនិត្យមោឃភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬដីកាកោះហៅឱ្យចូលបង្ហាញខ្លួន។ តុលាការបង្គាប់ឱ្យចេញដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ជាថ្មីម្តងទៀត លើកលែងតែបណ្តឹងអាជ្ញាត្រូវផុតរលត់។

- ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការ តុលាការអាចពិនិត្យមើលសំណុំរឿង ប្រសិនបើជនជាប់ចោទយល់ព្រមយ៉ាងជាក់លាក់ឱ្យជំនុំជម្រះភ្លាម។ ប៉ុន្តែបើជនជាប់ចោទមិនព្រមឱ្យជំនុំជម្រះភ្លាមទេ តុលាការបង្គាប់ឱ្យលើកសំណុំរឿងនេះទៅជំនុំជម្រះនៅសវនាការពេលក្រោយទៀត។

ម្យ៉ាងវិញទៀត នីតិវិធីនេះនឹងត្រូវបានប្រកាសមោឃភាព កាលណាដែលដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់មានអានុភាពធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជនជាប់ចោទ លើកលែងតែជនជាប់ចោទ ចូលមកបង្ហាញខ្លួនដោយស្ម័គ្រចិត្ត។[48]

### ២.៣. ទម្រង់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដើម្បីឱ្យចៅក្រមជំនុំជម្រះយល់ឃើញថា រឿងក្តីដែលព្រះរាជអាជ្ញាបានចោទប្រកាន់ពិតជាមានភាពធូនល្មមអាចនឹងចោទប្រកាន់បាន នោះព្រះរាជអាជ្ញា ត្រូវតែធ្វើដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ឡើង

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៦៥។
[47] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៩១។
[48] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៩២។

ដោយដីកានោះត្រូវតែមានទម្រង់ការច្បាស់លាស់ និងជាក់លាក់ដើម្បីងាយស្រួលដល់ចៅក្រមជំនុំជម្រះពិនិត្យ និង វិនិច្ឆ័យថាបទល្មើសដែលចោទប្រកាន់នោះពិតជាត្រឹមត្រូវតាមនីតិវិធីច្បាប់។ ម៉្យាងវិញទៀត ទម្រង់ការនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះ ក៏ជាព័ត៌មានយ៉ាងសំខាន់សម្រាប់ជនជាប់ចោទ យល់អំពីមូលហេតុនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចរបស់ជនជាប់ចោទក្នុងការបង្ហាញខ្លួនតាមការកំណត់ដោយមានចែងនៅក្នុងដីកានេះ។ ដូចនេះ ទម្រង់ការនៃដីកាកោះហៅទៅជំនុំជម្រះផ្ទាល់រួមមាន៖[49]

- **អត្តសញ្ញាណនៃជនជាប់ចោទ៖** ការកំណត់ពីអត្តសញ្ញាណជនជាប់ចោទ គឺមានសារប្រយោជន៍ដល់កិច្ចជំនុំជម្រះត្រង់ដែននៃការប្តឹងចំពោះបុគ្គល និងមានន័យគ្រប់គ្រាន់ថាជាបណ្តឹងចោទប្រកាន់ចំពោះជនល្មើស ព្រោះប្រសិនបើគ្មានការកំណត់អត្តសញ្ញាណនៃជនជាប់ចោទទេ មានន័យថាគ្មានការចោទប្រកាន់លើបទព្រហ្មទណ្ឌកើតមានឡើងនោះទេ។

- **សេចក្តីសង្ខេបអង្គហេតុ៖** ការកំណត់ពីសេចក្តីសង្ខេបអង្គហេតុ គឺមានប្រយោជន៍ដល់កិច្ចជំនុំជម្រះត្រង់ដែននៃការប្តឹងចំពោះអង្គហេតុ និងនាំឱ្យយើងដឹងថាបណ្តឹងប្តឹងអំពីអ្វី ព្រោះបើមិនកំណត់អង្គហេតុ មានន័យថា ព្រះរាជអាជ្ញាមិនបានចោទប្រកាន់លើអង្គហេតុនោះទេ ជាហេតុនាំឱ្យគ្មានបណ្តឹង។

-**ឈ្មោះបទល្មើស៖** សំដៅដល់បទល្មើសដែលព្រះរាជអាជ្ញាសម្រេចចោទប្រកាន់ចំពោះជនជាប់ចោទ។ ចំពោះបទចោទប្រកាន់ តុលាការមិនជាប់កាតព្វកិច្ចចំពោះឈ្មោះបទល្មើសទេ ដោយសារតុលាការជាប់កាតព្វកិច្ចចំពោះដែននៃការប្តឹងចំពោះអង្គហេតុ និងបុគ្គលតែប៉ុណ្ណោះ។ ដូចនេះ តុលាការអាចសម្រេចអំពីប្រភេទបទល្មើសផ្សេងដោយសេរី ចំពោះអង្គហេតុនោះលើបុគ្គលនោះ។

- **អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស៖** គឺសំដៅទៅលើបទល្មើស ដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ដោយត្រូវពឹងផ្អែកទៅលើបទប្បញ្ញត្តិនៃច្បាប់។ ក្រៅពីទម្រង់នៃដីកាខាងលើ ព្រះរាជអាជ្ញា ក៏ត្រូវចង្អុលប្រាប់ដល់ជនជាប់ចោទពីតុលាការ ព្រមទាំងទីកន្លែងចោទប្រកាន់ កាលបរិច្ឆេទ និងម៉ោងពេលនៃសាវនាការផងដែរ ព្រោះការជូនដំណឹងនេះមានភាពងាយស្រួលដោយមិនចាំបាច់ចេញដីកាកោះហៅឱ្យចូលសាវនាការទេ ដោយហេតុថាទម្រង់ការនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ បានបញ្ជាក់ប្រាប់ដល់ជនជាប់ចោទរួចអស់ហើយ។[50]

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៦។
[50] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៦៦។

## ២.៤. អានុភាពនៃដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាដីកាដែលចេញដោយព្រះរាជអាជ្ញា ក្នុងការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌ។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់មានអានុភាពដូចតទៅះ

- **ការផ្តាច់អាជ្ញាយុកាលនៃបទល្មើសព្រហ្មទណ្ឌះ** ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏ជានីតិវិធីនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ដែលជាហេតុនាំឱ្យមានការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ហើយចាប់ផ្តើមគិតថិរវេលាថ្មីនៃអាជ្ញាយុកាល។[51] ប្រសិនបើគ្មានការកំណត់បែបនេះទេ អាចមានករណីខ្លះនៅពេលបណ្តឹងបញ្ជូនទៅតុលាការតែត្រូវផុតអាជ្ញាយុកាលដែលនាំឱ្យជនល្មើសត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនទៅវិញ។ ហើយអាជ្ញាយុកាល ចាប់រាប់ដោយគិតចាប់ពីពេលប្រព្រឹត្តបទល្មើស ឬគិតចាប់ពីពេលមានការបញ្ចប់កិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរ រយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំចំពោះបទឧក្រិដ្ឋ ៥ (ប្រាំ) ឆ្នាំចំពោះបទមជ្ឈិម និង ១ (មួយ) ឆ្នាំចំពោះបទលហុ។[52]

- **ការផ្ទេរសមត្ថកិច្ចទៅតុលាការះ** ជាទូទៅតុលាការមានសមត្ថកិច្ចជំនុំជម្រះបានលុះត្រាតែមានបណ្តឹងមកខ្លួនតែប៉ុណ្ណោះ។ ក្នុងរឿងក្តីព្រហ្មទណ្ឌ សាលាដំបូងត្រូវបានទទួលពាក្យបណ្តឹងដោយដីកាបញ្ជូនទៅតុលាការជំនុំជម្រះផ្ទាល់របស់ព្រះរាជអាជ្ញា។[53] ជាគោលការណ៍តុលាការនឹងគ្មានសមត្ថកិច្ចលើរឿងក្តីនេះទេ ដរាបណាមិនមានបណ្តឹងប្រគល់មកខ្លួន ហើយកិច្ចជំនុំជម្រះដែលបើកដោយគ្មានបណ្តឹងនោះ ជាការបើកការជំនុំជម្រះដោយខុសច្បាប់ ជនដែលត្រូវច្បាប់ប្រគល់សិទ្ធិ អាចធ្វើបណ្តឹងឧទ្ធរណ៍ ករណីជាសាលក្រមរបស់សាលាដំបូង និងធ្វើបណ្តឹងសារទុក្ខករណីជាសាលដីការបស់សាលាឧទ្ធរណ៍ និងអាចប្តឹងសើរើបើសេចក្តីសម្រេចតុលាការចូលជាស្ថាពរ។ ផ្ទុយពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរឱ្យបើកកិច្ចស៊ើបសួរ តែដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ត្រូវបានប្រគល់សំណុំរឿងទៅឱ្យតុលាការធ្វើការជំនុំជម្រះតែម្តង ដោយពុំឆ្លងកាត់ដំណាក់កាលចៅក្រមស៊ើបសួរឡើយ។

- **ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងជនជាប់ចោទះ** យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មាត្រា ៣៤៨ បានកំណត់ពីដែនកំណត់ចំពោះអង្គហេតុ មានន័យថា តុលាការអាចជំនុំជម្រះបានត្រឹមអង្គហេតុដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់តែប៉ុណ្ណោះ។ តុលាការមិនអាចលើកយកអង្គហេតុទាំងឡាយណាដែលមិនបានសរសេរក្នុងដីកានោះមកជំនុំជម្រះបានទេ ទោះជាមានការកំណត់អង្គហេតុ

[51] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១១។

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១០។

[53] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា២៩១។

រួចហើយក៏ដោយ តែជួនកាលមានករណីមួយចំនួនដែលតុលាការនឹងបង្គាប់អោយបង្វិលសំណុំរឿងឱ្យព្រះរាជអាជ្ញាវិញដោយសារករណីបទមជ្ឈិម ឬបទលហុត្រូវជំនុំជម្រះដោយចៅក្រមទោល ឯករណីបទឧក្រិដ្ឋចាំបាច់ត្រូវជំនុំជម្រះជារួមក្រុម។ ដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះចេញក្នុងករណីចោទប្រកាន់លើបទល្មើសមជ្ឈិម ឬបទលហុ ហេតុនេះបើតុលាការយល់ថា ជាបទឧក្រិដ្ឋវិញនោះតុលាការនឹងបង្វិលសំណុំរឿងមកព្រះរាជអាជ្ញាវិញដើម្បីបើកកិច្ចស៊ើបសួរ ។ ចំណែកឯ ការកំណត់ពីដែននៃការប្តឹងចំពោះបុគ្គលវិញ មានន័យថាតុលាការនឹងអាចជំនុំជម្រះ ចំពោះតែជនណា ដែលបានចង្អុលឈ្មោះក្នុងដីកានេះតែប៉ុណ្ណោះ។ តុលាការមិនអាចធ្វើការជំនុំជម្រះទៅលើជនទាំងឡាយណា ដែលមិនមានការចោទប្រកាន់របស់ព្រះរាជអាជ្ញានោះឡើយ។[54] ក្នុងនោះយើងសង្កេតឃើញថា ដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏បានកំណត់ពីអត្តសញ្ញាណរបស់ជនល្មើស ដែលជាលក្ខខណ្ឌមួយក្នុងចំណោមទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដែរ។ ក្នុងករណីការចោទប្រកាន់ធ្វើឡើងដោយដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ វាគ្មានអានុភាពបង្ខំជនជាប់ចោទអោយចូលសវនាការទេ ជនជាប់ចោទមានសេរីភាពក្នុងការបង្ហាញខ្លួននៅមុខសវនាការ ។[55]

## ផ្នែកទី៣. ការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម (CI)

នីតិវិធីនៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម គឺជានីតិវិធីមួយដែលព្រះរាជអាជ្ញាបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅចំពោះមុខតុលាការជាន់ដំបូងដោយផ្ទាល់។ នីតិវិធីនៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមនេះ ជានីតិវិធីដែលមានលក្ខណៈលឿនជាងនីតិវិធីផ្សេងៗទៀត ដោយសារតែវាជម្រុញដល់ដំណើរការរឿងក្តីព្រហ្មទណ្ឌឱ្យបានឆាប់រហ័ស ជៀសវាងការកកស្ទះសំណុំរឿងនៅក្នុងស្ថាប័នតុលាការ ក៏ដូចជាដើម្បីសម្រួលដល់វិស័យយុត្តិធម៌នៅក្នុងតុលាការនៃព្រះរាជាណាចក្រកម្ពុជាផង។ ប៉ុន្តែពេលខ្លះ មានការយល់ឃើញថា ការធ្វើឱ្យឆាប់រហ័សពេក វាក៏បានធ្វើឱ្យប៉ះពាល់ទៅដល់សិទ្ធិរបស់ភាគីនៃរឿងក្តីដែរ។ ដូច្នេះហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ចំពោះនីតិវិធីបង្ហាញខ្លួនភ្លាមនេះ ដែលអាចអនុវត្តទៅបានលុះត្រាតែមានការបំពេញនូវលក្ខខណ្ឌមួយចំនួន ហើយដំណើរការប្រព្រឹត្តទៅត្រូវឱ្យស្របតាមនីតិវិធី និងឈានទៅដល់ការបង្កើតឱ្យមានអានុភាពមួយចំនួន។

### ៣.១. លក្ខខណ្ឌនៃនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

ព្រះរាជអាជ្ញា អាចជ្រើសរើសយកការចោទប្រកាន់ តាមរយៈនីតិវិធីនៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម នៅចំពោះមុខសាលាដំបូង ក្នុងករណីបើមានលក្ខខណ្ឌគ្រប់ដូចខាងក្រោម៖

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៣៤៥។
[55] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៣០២។

- **បទល្មើសជាច់ខាតត្រូវតែជាបទមជ្ឈិមជាក់ស្តែង៖** បទល្មើសនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់ដូចដែលមានចែងនៅក្នុងមាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ដូចមានចែងនៅក្នុងមាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[56] ដោយហេតុថា នីតិវិធីនៃការបង្ហាញខ្លួនភ្លាម កំណត់យកតែអត្ថន័យតាមនិយមន័យនៃបទ ឧក្រិដ្ឋ និងបទមជ្ឈិមជាក់ស្តែង គឺសំដៅលើបទល្មើសដែលកំពុងប្រព្រឹត្ត ឬ បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម ឬ ត្រូវចាត់ទុកជាបទមជ្ឈិមជាក់ស្តែងកាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក ជនដែលគេសង្ស័យត្រូវសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រកីង និងបុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬ តម្រុយច្បាស់លាស់ហើយស៊ីចង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬ បានចូលរួមប្រព្រឹត្តបទល្មើស។[57] ម្យ៉ាងវិញទៀត ទោះបីមិនស្ថិតក្នុងអត្ថន័យនៃមាត្រា ៨៦ ប៉ុន្តែមាត្រា ៨៨ បានកំណត់អំពីការចាត់ទុកដូចបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង។ ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណា ត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ។[58] ដូច្នេះក្រៅពីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់តាមនីតីវីធីនេះបានឡើយ ដោយហេតុថា នីតិវិធីមួយនេះ មិនអាចត្រូវយកអនុវត្តបានឡើយក្នុងករណីបទល្មើសនេះជាបទឧក្រិដ្ឋ ឬបទមជ្ឈិមមិនជាក់ស្តែង ឬបទលហុ។

- **បទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិចមួយឆ្នាំ និងជាអតិបរមានៃទោសប្រាំឆ្នាំ៖** បទល្មើសដែលមានការដាក់ពន្ធនាគារបែបនេះ គឺសំដៅដល់បទល្មើសមជ្ឈិម ដែលអតិបរមានៃទោសយ៉ាងតិចចំនួន ១ (មួយ) ឆ្នាំ និងយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំដែលច្បាប់បានកំណត់។[59]

- **ជនជាប់ចោទជានីតិជន៖** សំដៅដល់ជនដែលមានអាយុ ១៨ ឆ្នាំឡើងទៅ ដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌបាន។[60] ដូចនេះយើងមិនអាចអនុវត្តនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមទៅលើអនីតិជនបានទេ ដែលវាហាក់បីដូចជាការរំលោភសិទ្ធិសេរីភាព និងផលប្រយោជន៍របស់អនីតិជនដូចដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ។

[56] ឆៀង សំណាង,នីតិវិធីព្រហ្មទណ្ឌ,(ភ្នំពេញ,២០១៩),ទំព័រ ៨៤។
[57] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៨៦។
[58] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៨៨។
[59] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៧។
[60] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា៣៨ ។

- **រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន៖** មានន័យថា នៅក្នុងសំណុំរឿងត្រូវមានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់ដោយពុំមានការសង្ស័យ ដែលមានភាពធូនល្មមនឹងអាចបើកសវនាការជំនុំជម្រះបាន។ ផ្ទុយទៅវិញ ប្រសិនបើសំណុំរឿងគ្មានបន្ទុកក្នុងការចោទប្រកាន់គ្រប់គ្រាន់ទេ ព្រះរាជអាជ្ញាមិនគួរបើកការចោទប្រកាន់តាមនីតិវិធីនេះឡើយ។

## ៣.២. នីតិវិធីនៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

នៅក្នុងនីតិវិធីនៃការបង្ហាញខ្លួនភ្លាម គឺជានីតិវិធីមួយដែលមានលក្ខណៈពិសេសខុសប្លែកពីនីតិវិធីទាំងពីរខាងលើ ព្រោះថានីតិវិធីនេះត្រូវបានបញ្ញត្តិយ៉ាងច្បាស់លាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចំណែកឯនីតិវីធីផ្សេងទៀតមិនមានចែងច្បាស់លាស់នៅក្នុងច្បាប់ទេ។ ជាក់ស្តែងដោយយោងតាមបញ្ញត្តិនៃមាត្រា ៤៨ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលជានីតិវិធីនៃការបង្ហាញខ្លួនភ្លាមនេះ ត្រូវបានបែងចែកជា ២ (ពីរ) ដំណាក់កាលគឺ នីតិវិធីចាត់ការនៅចំពោះមុខព្រះរាជអាជ្ញា និង នីតិវិធីចាត់ការនៅចំពោះមុខយុត្តាធិការជំនុំជម្រះ។

### ៣.២.១. នីតិវិធីចាត់ការនៅចំពោះមុខព្រះរាជអាជ្ញា

ជាដំណាក់កាលដំបូង ជនជាប់ចោទចាំបាច់ត្រូវតែជាជនដែលត្រូវបានឃាត់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌តាមរយៈមាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បន្ទាប់មកទើបបញ្ជូនខ្លួនទៅកាន់ព្រះរាជអាជ្ញា។ ហើយនៅពេលដែលរលត់រយៈពេលនៃការឃាត់ខ្លួន ព្រះរាជអាជ្ញានឹងថ្លឹងថ្លែងថាគួរតែដោះលែងឱ្យរួចខ្លួន ឬសម្រេចឱ្យមានការបញ្ជូនខ្លួនជននោះមកចាត់ការតាមនីតិវិធី។[61] ក្នុងករណីដែលបញ្ជូនជននោះមក ព្រះរាជអាជ្ញានឹងសម្រេចថាខ្លួននឹងប្រើនីតិវិធីណាមួយសម្រាប់ចោទប្រកាន់ទៅលើជននោះ។ ប្រសិនបើព្រះរាជអាជ្ញាសម្រេចជ្រើសរើសនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ដោយមានលក្ខខណ្ឌគ្រប់គ្រាន់ នោះព្រះរាជអាជ្ញានឹងត្រូវធ្វើដូចតទៅ៖[62]

- **ពិនិត្យអត្តសញ្ញាណរបស់ជនដែលត្រូវបានបញ្ជូនមក៖** ដើម្បីកំណត់សម្គាល់ថានរណាម្នាក់ជាជនល្មើស ហើយជននោះមានអត្តសញ្ញាណដូចអ្វីដែលកំណត់ហេតុបានកត់ត្រា ឬទេ។

- **ត្រូវឱ្យដំណឹងដល់ជននោះអំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស៖** ការធ្វើបែបនេះ ព្រោះថាវាជាសិទ្ធិរបស់ជនជាប់ចោទក្នុងការដឹងឮអំពីមូលហេតុអ្វីដែលគេចោទប្រកាន់មកខ្លួន ហើយជាបទល្មើសអ្វី។[63]

[61] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១០៣។
[62] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៨។
[63] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ,២៣ មិនា ១៩៧៦, មាត្រា១៤ កថាខណ្ឌទី៣។

- **ទទួលចម្លើយរបស់បុគ្គលនោះប្រសិនបើសាមីខ្លួនចង់និយាយ៖** មានន័យថាជាការផ្តល់សិទ្ធិសេរីភាពដល់ជនជាប់ចោទក្នុងការលើអំណះអំណាងគ្រប់បែបយ៉ាង ដើម្បីការពារខ្លួន និងលើកយកព័ត៌មានគ្រប់យ៉ាងដែលខ្លួនបានដឹងទុកជាផលប្រយោជន៍ដល់សំណុំរឿង។

- **ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម៖** មានន័យថានីតិវិធីនៃការបង្ហាញខ្លួនភ្លាមអាចអនុវត្តបាន លុះត្រាតែព្រះរាជអាជ្ញាចេញកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម រួចបញ្ជូនទៅតុលាការជាន់ដំបូង ដើម្បីចាត់តាំងចៅក្រមជំនុំជម្រះក្នុងការបើកសវនាការ។ ក្នុងកំណត់ហេតុនេះចាំបាច់ត្រូវតែមានចែងនូវចំណុច ដែលព្រះរាជអាជ្ញាបានប្រាប់ជនជាប់ចោទអំពីសិទ្ធិសុំពឹងមេធាវី តាមការជ្រើសរើសរបស់ខ្លួន ឬចាត់តាំងដោយអនុលោមទៅតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ចំពោះមេធាវី ដែលត្រូវបានជ្រើសរើស ឬចាត់តាំងត្រូវទទួលដំណឹងភ្លាម និងអាចពិនិត្យសំណុំរឿង ហើយធ្វើការទាក់ទងនឹងជនជាប់ចោទបាន។ ហើយនិទ្ទេសនៃទម្រង់ការ ត្រូវតែចុះក្នុងកំណត់ហេតុ បើមិនដូច្នោះទេ នីតិវិធីត្រូវទុកជាមោឃៈ។ នៅក្នុងនីតិវិធីនេះតុលាការជាន់ដំបូង ត្រូវទទួលបានបណ្តឹងតាមកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ជាមួយគ្នានេះជនជាប់ចោទត្រូវបានបង្ខាំងទុកដោយកងកម្លាំងការពារ រហូតដល់សាមីខ្លួនចូលបង្ហាញខ្លួន នៅចំពោះមុខតុលាការ ដែលត្រូវបានបើកសវនាការនៅថ្ងៃនោះតែម្តង។[64]

### ៣.២.២. នីតិវិធីចាត់ការនៅចំពោះមុខយុត្តាធិការជំនុំជម្រះ

បន្ទាប់ពីទទួលបានបណ្តឹង តាមកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម តុលាការត្រូវធ្វើការផ្ទៀងផ្ទាត់មើល អត្តសញ្ញាណរបស់ជនជាប់ចោទឱ្យបានត្រឹមត្រូវ ច្បាស់លាស់ និងធ្វើរបាយការណ៍ដោយសង្ខេបអំពីរឿងរ៉ាវ ដែលបានធ្វើការចោទប្រកាន់ និងប្រាប់ឱ្យជនជាប់ចោទដឹងថា សាមីខ្លួនអាចមានរយៈពេលដើម្បីរៀបចំការពារខ្លួនបាន។[65] ក្នុងករណីដែលជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថា រឿងក្តីនោះមិនទាន់អាចធ្វើការជំនុំជម្រះភ្លាមៗបានទេ សំណុំរឿងនេះនឹងត្រូវលើកពេលសវនាការនៅពេលក្រោយ ដែលអាចទាមទារឱ្យធ្វើការស៊ើបអង្កេត ឬបើកការស៊ើបសួរឡើងវិញ។ ក្នុងករណីនេះតុលាការអាចសម្រេចឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន ដោយសាលក្រមដែលមានបញ្ជាក់នូវសំអាងហេតុ ស្របតាមលក្ខខណ្ឌមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ដែលបានចែងពីមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន មានជាអាទិ៍៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។
- ដើម្បីរារាំងកុំឱ្យមានការគាប់សង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាង

[64] អៀង សំណាង,នីតិវិធីព្រហ្មទណ្ឌ,(ភ្នំពេញ,២០១៩),ទំព័រ ៨៥។

[65] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៤៨។

ជនត្រូវចោទ និងអ្នកសមគំនិត។

- ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ។

- ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។

- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ។

- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។

ចំពោះដីកាឃុំខ្លួនបណ្តោះអាសន្ន មានអានុភាពតែទៅលើជនជាប់ចោទនេះប៉ុណ្ណោះ ចំណែកឯដីកាបង្គាប់ឱ្យឃុំខ្លួនមានអានុភាពជាការបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួលយក និងឱ្យឃុំខ្លួនជននោះ។ លើសពីនេះសាលក្រមលើអង្គសេចក្តី ត្រូវតែប្រកាសក្នុងរយៈពេល ដែលមិនអាចលើសពី ២ (ពីរ) សប្តាហ៍ គិតពីថ្ងៃដែលចូលទៅបង្ហាញខ្លួននៅមុខតុលាការ។ ក្រោយផុតរយៈពេល ២ (ពីរ) សប្តាហ៍ ការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ឈប់ដោយពេញច្បាប់ មានន័យថា ជនជាប់ចោទត្រូវតែដោះលែងឱ្យមានសិទ្ធិសេរីភាព ដោយហេតុថានីតិវិធីនៃការឃុំខ្លួននេះ ទាមទារឱ្យមាននូវរយៈពេលកំណត់មួយ ដើម្បីធានាថាមិនមានការបំពានណាមួយហួសហេតុដល់សេរីភាពរបស់ជននោះទេ។ ផ្ទុយទៅវិញ ប្រសិនបើតុលាការយល់ឃើញថាលក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាម ដោយមានចែងនៅក្នុងមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនត្រូវបានបំពេញទេ ឬក៏ដោយសារមានភាពសាំញ៉ាំ នៃសំណុំរឿងដែលតម្រូវឱ្យធ្វើការស្រាវជ្រាវបន្ថែម តុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ ។ ខណៈនោះជនជាប់ចោទត្រូវទៅបង្ហាញខ្លួន នៅថ្ងៃនោះតែម្តងនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នោះទេជនជាប់ចោទត្រូវតែដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង។[66]

### ៣.៣. អានុភាពនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

កាលណាព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម នោះអានុភាពនឹងកើតឡើងតាមកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាមដូចជា ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ចទៅតុលាការ និង ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងបុគ្គល។

- **ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស៖** មានន័យថា អាជ្ញាយុកាលត្រូវបានផ្តាច់ដោយគ្រប់កិច្ច នៃការចោទប្រកាន់តាមរយៈកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម របស់ព្រះរាជអាជ្ញា ដែលមានអានុភាពនាំឱ្យមានការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ហើយចាប់ផ្តើមគិតចិរវេលាថ្មីនៃអាជ្ញាយុកាល។[67]

[66] ឌី លីឡា និង ខាន់ សុខា ,នីតិវិធីព្រហ្មទណ្ឌ,(គ្មានការបរិច្ឆេទ),ទំព័រ ៥០។

[67] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១១។

- **ការផ្ទេរសមត្ថកិច្ចទៅតុលាការ៖** មានន័យថា ជាការផ្ទេរសមត្ថកិច្ចពីអយ្យការ មកយុត្តាធិការជំនុំជម្រះតាមរយៈកំណត់ហេតុស្ដីអំពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា។ ផ្ទុយទៅវិញ តុលាការនឹងគ្មានសមត្ថកិច្ចលើការជំនុំជម្រះលើរឿងក្ដីនោះទេ ដរាបណាមិនមានបណ្ដឹងប្រគល់មកខ្លួន។[68]

- **ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងបុគ្គល៖** មានន័យថា តុលាការអាចជំនុំជម្រះបានតែទៅលើអង្គហេតុ និងបុគ្គលដែលបានកំណត់ក្នុងកំណត់ហេតុស្ដីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួន ដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់តែប៉ុណ្ណោះ។[69] ដោយហេតុថា តុលាការពុំអាចធ្វើការជំនុំជម្រះទៅលើអង្គហេតុ និងបុគ្គលទាំងឡាយណាដែលពុំមានកំណត់ក្នុងកំណត់ហេតុនោះឡើយ។

[68] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា២៩១។

[69] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៣៤៨,មាត្រា៣៤៩។

# ជំពូកទី៣

# ជំពូកទី៣
# ការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា

ការតម្កល់រឿងទុកឥតចាត់ការ គឺជាសេចក្តីសម្រេចរបស់តំណាងអយ្យការ តាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ដែលមានព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញា និងអនុវត្តបណ្តឹងអាជ្ញា។ ជាទូទៅបណ្តឹងអាជ្ញាត្រូវបានអនុវត្តក្នុងនាមនៃផលប្រយោជន៍សាធារណៈ និងមានតួនាទីក្នុងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។[70] ព្រះរាជអាជ្ញាក៏មានសិទ្ធិអំណាច ក្នុងការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការបានផងដែរ ហើយមុននឹងសម្រេចព្រះរាជអាជ្ញាត្រូវ ធ្វើការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម ទៅលើអំពើដែលជាបទល្មើស និងអំពើដែលមិនមែនជាបទល្មើស។[71] ការសម្រេចចិត្តរបស់ព្រះរាជអាជ្ញាក្នុងការតម្កល់រឿងទុកឥតចាត់ការនេះ គឺមានគោលបំណងដើម្បីជៀសវាងការប្តឹងផ្តល់ដោយគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់នៅក្នុងបណ្តឹងព្រហ្មទណ្ឌ។ ហេតុដូចនេះហើយនៅគ្រប់សាលាដំបូងរាជធានី និងសាលាដំបូងខេត្តក្រុងទាំងអស់ ព្រះរាជអាជ្ញាអាចតម្កល់រឿងឥតចាត់ការទៅតាមគោលការណ៍ និងលក្ខខណ្ឌដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

## ផ្នែកទី១. មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

តាមរយៈគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ បានផ្តល់សិទ្ធអំណាចយ៉ាងធំធេង ដល់ព្រះរាជអាជ្ញា ក្នុងការតម្កល់រឿងទុកឥតចាត់ការបាន តាមរយៈការថ្លឹងថ្លែងរបស់ខ្លួន បើទោះបីជាអំពើដែលបានប្តឹង ឬបរិហារមកនោះ ជាបទល្មើសព្រហ្មទណ្ឌក៏ដោយ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា អំពើនោះគឺមិនមានភាពរីករវដល់សង្គម ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គមធ្ងន់ធ្ងរ ឬមួយជាការប្រព្រឹត្តក្នុងកាលៈទេសៈពិសេសណាមួយដែលគួរអនុគ្រោះបាន ចំណែកឯព្យសនកម្មចំពោះជនរងគ្រោះទាំងផ្នែកសីលធម៌ និងសេដ្ឋកិច្ចក៏មានភាពតិចតួច ហើយជនរងគ្រោះមិនទាំងអើពើ លើអំពើដែលបានប្រព្រឹត្តនោះផង។ ដូច្នេះ នៅក្នុងស្ថានភាពបែបនេះទោះបីព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ក៏មិនផ្តល់ផលប្រយោជន៍អ្វីនោះដែរ។ ម្យ៉ាងវិញទៀត ទោះបីជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចមានសិទ្ធិធ្វើអធិបញ្ញា ឱ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយដែលខ្លួនបានដឹងក៏ដោយ ប៉ុន្តែមិនអាចធ្វើអធិបញ្ញាឱ្យតម្កល់រឿងទុកឥតការបានឡើយ។[72]

---

[70] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៥។

[71] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី២,មាត្រា៤០។

[72] ឆៀង សំណាង,នីតិវិធីព្រហ្មទណ្ឌ,(ភ្នំពេញ,២០១៩),ទំព័រ ៧៧។

បើទោះបីជាព្រះរាជអាជ្ញាសម្រេចធ្វើការតម្កល់រឿងទុកឥតការដោយឆន្ទានុសិទ្ធក៏ដោយ ក៏ការសម្រេចមិនចោទប្រកាន់នេះ ត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋានត្រឹមត្រូវ និងសមស្របដែលមានដូចជា៖ នត្ថិភាពនៃបទល្មើស មូលហេតុគតិយុត្តិ និងការចោទប្រកាន់មិនផ្តល់ប្រយោជន៍។

**១.១. នត្ថិភាពនៃបទល្មើស**

យោងតាមគោលការណ៍នីត្យានុកូលភាពនៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះ មានចែងក្នុងបទប្បញ្ញត្តិក្រមព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។[73] មានន័យថា រាល់អំពើដែលបានបង្កើតឱ្យមានព្យសនកម្មដល់សង្គម មិនប្រាកដថាអំពើទាំងនោះ គឺជាបទល្មើសព្រហ្មទណ្ឌនោះទេ លុះត្រាតែអំពើនោះមានចែងក្នុងអត្ថបទច្បាប់ថាជាបទល្មើស ទើបការចោទប្រកាន់អាចអនុវត្តទៅបាន។ ដូចនេះ ហេតុផលដែលនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលមិនមែនជាបទល្មើស គឺអវត្តមាននៃបទល្មើស និងកង្វះធាតុផ្សំនៃបទល្មើស។

**១.១.១.អវត្តមាននៃបទល្មើស**

ខណៈពេលដែលតំណាងអយ្យការធ្វើការថ្លឹងថ្លែងទៅលើបណ្តឹង ដែលទទួលបានដោយផ្ទាល់ ឬដោយកំណត់ហេតុមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមកសព្វគ្រប់ ព្រមទាំងបើកការស៊ើបអង្កេតបឋម ឬស្រាវជ្រាវបន្ថែមហើយ តែបណ្តឹងនោះមិនមានវត្តមាននៃបទល្មើសព្រហ្មទណ្ឌទេ នោះព្រះរាជអាជ្ញានឹងសម្រេចចេញដីកាតម្កល់រឿងទុកឥតចាត់ការបាន។ អវត្តមាននៃបទល្មើស សំដៅលើពាក្យបណ្តឹងទាំងឡាយណាដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ ទោះបីជាអំពើដែលកើតមានឡើងនោះ វានាំឱ្យមានព្យសនកម្មកើតមានឡើងក៏ដោយ ព្រោះពេលខ្លះវាគ្រាន់តែជាបណ្តឹងផ្នែករដ្ឋប្បវេណី ដែលត្រូវបានប្តឹងដោយខុសសមត្ថកិច្ចតុលាការ ឬដោយការភ័ន្តច្រឡំ ឬខុសតាមរយៈការធ្វើសេចក្តីសន្និដ្ឋានដែលធ្វើឡើងដោយមន្ត្រីនគរបាលធម៌ប៉ុណ្ណោះ។

**ឧទាហរណ៍៖** លោក សុខ បានប្តឹង លោក សៅរ៍ ដោយចោទប្រកាន់ថាបានរំលោភលើសេចក្តីទុកចិត្តទៅកាន់ស្ថាប័នអយ្យការ។ តែក្រោយមកព្រះរាជអាជ្ញាបានធ្វើការស៊ើបអង្កេត ទើបរកឃើញថាបទល្មើសដែលលោក សុខ បានប្តឹងមកនោះ វាមិនមែនជាបទល្មើស រំលោភលើសេចក្តីទុកចិត្តដូចការប្តឹងនោះទេ តាមពិតអំពើនោះវាគ្រាន់តែជាការមិនគោរពកាតព្វកិច្ចតាមកិច្ចសន្យាប៉ុណ្ណោះ។

**១.១.២. កង្វះធាតុផ្សំនៃបទល្មើស**

ជាគោលការណ៍ អំពើមួយត្រូវចាត់ទុកថាជាបទល្មើសបាន លុះត្រាតែអំពើនោះមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ដែលការបំពេញនៃធាតុផ្សំទាំងនោះ គឺជាកត្តាមួយដែលជម្រុញឱ្យមានការចោទប្រកាន់លើ

[73] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា៣ ។

បុគ្គលណាម្នាក់ថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ ដែលធាតុផ្សំនៃបទល្មើសទាំងនោះមានដូចជា៖

- **ធាតុនីត្យានុកូល ឬធាតុច្បាប់៖** សំដៅដល់ធាតុផ្សំដែលទាក់ទងនឹងច្បាប់ មានន័យថាអំពើនោះត្រូវបានចាត់ទុកថាជាបទល្មើស ប្រសិនបើអំពើនោះមានចរិតគ្រោះថ្នាក់ដល់សង្គមមានកំហុស និងត្រូវបានបញ្ញត្តិក្នុងច្បាប់ព្រហ្មទណ្ឌ។ ផ្ទុយទៅវិញនៅពេលដែលច្បាប់ពុំមានបានចែងថា អំពើណាមួយជាបទល្មើសទេ នោះពុំអាចចោទប្រកាន់ ឬផ្តន្ទាទោសជនដែលបានប្រព្រឹត្តអំពើនោះបានឡើយ។

**ឧទាហរណ៍៖** អំពើទទួលផលចោរកម្ម គឺជាបទល្មើសព្រហ្មទណ្ឌដែលត្រូវបានបញ្ញត្តិទុកនៅក្នុងមាត្រា ៣៩៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៧ សំដៅដល់អំពើទទួល លាក់បំបាំង រក្សាទុក ឬបញ្ជូនវត្ថុអ្វីមួយដោយដឹងថា វត្ថុនោះបានមកពី បទក្រិដ្ឋ ឬមជ្ឈិម។ ដូច្នេះ ជនណាម្នាក់ដែលបានប្រព្រឹត្តសកម្មភាពដូចមានចែងក្នុងបទប្បញ្ញត្តិនេះនឹងត្រូវទទួលទោសពីបទ ទទួលផលចោរកម្មតាមមាត្រាខាងលើ។ ផ្ទុយទៅវិញកាលណាបើអំពើមួយដែលច្បាប់មិនចែងថាមានទោសអំពើដែលប្រព្រឹត្តនោះមិនអាចចាត់ទុកថាជាបទល្មើសបានទេ កាលណាមិនមែនជាបទល្មើស គឺមិនទទួលនូវទណ្ឌកម្មព្រហ្មទណ្ឌណាមួយឡើយ។

- **ធាតុសត្យានុម័ត ឬធាតុសម្ភារៈ៖** សំដៅដល់អំពើ ឬសកម្មភាពនៃការប្រព្រឹត្តបទល្មើសពិតប្រាកដ ឬជាការប៉ុនប៉ងដែលជាការកំណត់ទៅលើបទល្មើសមួយ ដែលស្តែងចេញតាមរយៈសកម្មភាពខាងក្រៅរបស់ជនល្មើស ហើយអំពើនោះបានបង្កឱ្យមានព្យសនកម្ម ឬបង្កគ្រោះថ្នាក់ដល់សង្គម និងកម្រិតនៃការប្រព្រឹត្តជាកត្តាកំណត់នៃការកើតនូវបច្ច័យគ្រោះថ្នាក់ដល់សង្គម និងទំហំនៃការអន្តរាយ ក៏ដូចជាទំនាក់ទំនងហេតុផលរវាងអំពើ និងបច្ច័យ។ ហើយនៅពេលអំពើនោះបានកើតឡើង នោះបណ្តាលសញ្ញាផ្សេងៗ ដែលស្តែងចេញតាមរយៈការប្រព្រឹត្ត ក៏នឹងផ្សារភ្ជាប់ជាមួយអំពើនោះ ដូចជា ឧបករណ៍ មធ្យោបាយ វិធីសាស្ត្រ ឧបាយកល ពេលវេលា ទីកន្លែង និងទិដ្ឋភាពនៃបទល្មើសជាដើម។[74] ជារួមមក អំពើ ឬសកម្មភាពរបស់ជនល្មើសជាធាតុផ្សំមួយយ៉ាងសំខាន់ដែលមិនអាចខ្វះបាន ព្រោះទាល់តែមានសកម្មភាពដែលស្តែងចេញមកខាងក្រៅជាមុនសិន ទើបអាចកំណត់ថាសកម្មភាពណាមួយជាបទល្មើសបាន ដោយសារគេមិនអាចធ្វើច្បាប់ ដាក់ទោសចំពោះការគិតក្នុងចិត្តរបស់មនុស្សបានឡើយ។ ប្រសិនបើជនណាម្នាក់គ្រាន់តែមានគំនិត តែពុំបានប្រព្រឹត្តសកម្មភាពតាមការគិតរបស់គេទេនោះនឹងគ្មានបទល្មើសកើតឡើងឡើយ លុះត្រាតែសកម្មភាពដែលនៅក្នុងចិត្តនោះ វាស្តែងចេញមកខាងក្រៅសិនទើបអាចចាត់ទុកថា ជាបទល្មើស។[75]

[74] ហ៊ី សោភា,នីតិវិធីព្រហ្មទណ្ឌ,(ភ្នំពេញ,២០១៩),ទំព័រ ៤៧។
[75] ផៀង សំណាង,នីតិព្រហ្មទណ្ឌ,(ភ្នំពេញ,២០១៩),ទំព័រ ៣០។

- **ធាតុអត្តនោម័តៈ** គឺសំដៅដល់ផ្នែកខាងក្នុងនៃបទល្មើស វាជាកិរិយាផ្លូវចិត្តរបស់ជនល្មើសចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គមដែលគេបានប្រព្រឹត្ត និង ចំពោះបច្ច័យដែលកើតមានឡើងដោយសារអំពើនោះដែលស្តែងឡើងក្រោមរូបភាពចេតនា ឬអចេតនា។[76]ជាគោលការណ៍មិនមានបទល្មើសកើតឡើងទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកជាមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពការព្វកិច្ចដោយឡែកណាមួយជាដើម។ ក្នុងករណីបែបនេះគឺត្រូវរាប់បញ្ចូលថាជាបទល្មើសដោយអចេតនាទៅវិញ។[77]

សរុបសេចក្តីមក អំពើណាមួយដែលបានប្រព្រឹត្តហើយត្រូវបានចាត់ថាជាបទល្មើស លុះត្រាតែបានបំពេញនូវធាតុផ្សំទាំងបីខាងលើ ក្នុងករណីដែលអវត្តមាននៃធាតុផ្សំនៃបទល្មើសណាមួយ តំណាងអយ្យការដែលព្រះរាជអាជ្ញាអាចធ្វើការតម្កល់រឿងទុកឥតចាត់ការបាន។

### ១.២.មូលហេតុគតិយុត្ត

យោងតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មិនបានបញ្ជាក់ឱ្យបានច្បាស់លាស់អំពីមូលហេតុដែលនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការនោះទេ គឺចែងតែនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការប៉ុណ្ណោះ។ តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាអាចសម្រេចមិនធ្វើការចោទប្រកាន់បាន ដោយផ្អែកទៅតាមមូលហេតុផ្សេងៗតាមការថ្លឹងថ្លែងដែលជាឆន្ទានុសិទ្ធិរបស់ខ្លួន ប៉ុន្តែក្រៅពីមូលហេតុទាំងនេះហើយ ព្រះរាជអាជ្ញា ក៏ត្រូវតែសម្រេចតម្កល់រឿងទុកឥតចាត់ការផងដែរ ប្រសិនបើមានមូលហេតុគតិយុត្តណាមួយដែលច្បាប់បានតម្រូវឱ្យធ្វើការតម្កល់រឿងទុកឥតចាត់ការ។ ក្នុងមូលហេតុគតិយុត្ត ដែលច្បាប់បានតម្រូវឱ្យធ្វើការតម្កល់រឿងទុកឥតចាត់ការទាំងអស់នោះមានដូចជា៖ ការផុតរលត់នៃបណ្តឹងអាជ្ញា អភ័យឯកសិទ្ធិ អនិយ័តភាពនៃនីតិវិធីការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ និង មូលហេតុផ្សេងទៀតនៃការរួចផុតនៃបណ្តឹងអាជ្ញា ។

#### ១.២.១.ការផុតរលត់នៃបណ្តឹងអាជ្ញា

ប្រជាពលរដ្ឋមួយចំនួនតែងតែមានការយល់ច្រឡំថា បណ្តឹងអាជ្ញានឹងត្រូវបញ្ចប់ ឬរលត់ នៅពេលដែលជនដែលត្រូវបានសន្មត់ថា បានប្រព្រឹត្តបទល្មើសនោះបានសងសំណងជម្ងឺចិត្តដល់ភាគីរងគ្រោះ ហើយភាគីរងគ្រោះបានដកពាក្យបណ្តឹង (បណ្តឹងរដ្ឋប្បវេណី) មកវិញ នោះបណ្តឹងអាជ្ញានឹងត្រូវរលត់។ ប៉ុន្តែវាមិនដូចអ្វីដែលយើងគ្រប់គ្នាបានគិតនោះឡើយ តាមគោលការណ៍ច្បាប់ បើទោះបីជាសំណងជម្ងឺចិត្តត្រូវបានផ្តល់ជូនភាគីរងគ្រោះហើយក៏ដោយ និងមានការសម្របសម្រួលដកពាក្យបណ្តឹងពីសំណាក់ភាគីរងគ្រោះក៏ពិតមែន ក៏

[76] ហ៊ី សោភា,នីតិវិធីព្រហ្មទណ្ឌ,(ភ្នំពេញ,២០១៩),ទំព័រ ៧៤។
[77] រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ,(ភ្នំពេញ,២០១៧),ទំព័រ ១៥។

បណ្តឹងអាជ្ញាមិនរលត់ឡើយ ពីព្រោះថាការដកបណ្តឹងរដ្ឋប្បវេណីរបស់ភាគីរងគ្រោះ វាគ្រាន់តែជាការបញ្ចប់នូវការទាមទារផ្នែកសំណងរដ្ឋប្បវេណីរបស់ភាគីរងគ្រោះតែប៉ុណ្ណោះ គឺមិនមែនជាកត្តាដែលអាចនាំឱ្យបណ្តឹងអាជ្ញាត្រូវរលត់ទេ។[78] ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានបញ្ញត្តិថា ការផុតរលត់នៃបណ្តឹងអាជ្ញាអាចបណ្តាលមកពី មរណភាពនៃជនល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និងអាជ្ញាអស់ជំនុំ។[79] ដែលកត្តាទាំងអស់នេះហើយគឺជាមូលហេតុដែលនាំឱ្យព្រះរាជអាជ្ញា អាចធ្វើការតម្កល់រឿងទុកឥតចាត់ការបាន កាលណាបណ្តឹងអាជ្ញាត្រូវបានផុតរលត់ហើយនោះ ការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌ មិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់តែម្តង។

- **មរណភាពនៃជនល្មើស៖** សំដៅលើជនល្មើស ជនសង្ស័យ ជនត្រូវចោទ ឬ ជនជាប់ចោទ ដែលកំពុងស្ថិតក្នុង បណ្តឹងអាជ្ញាមួយ ហើយជននោះបានទទួលមរណៈភាពនឹងនាំឱ្យបណ្តឹងអាជ្ញាដែលកំពុងតែមានលើជននោះត្រូវរលត់ ហើយដំណើរការទាំងឡាយនៃនីតិវិធីនឹងត្រូវបិទបញ្ចប់។[80] កាលណាជនល្មើស បានទទួលមរណភាពហើយនោះ ជាធម្មតាជននេះមិនត្រូវបានកំណត់ជាប្រធាននៃនីតិ ក្នុងការទទួលយកសិទ្ធិ និងកាតព្វកិច្ចទៀតទេ។ ម្យ៉ាងទៀតដោយផ្អែកលើគោលការណ៍ឯកកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។ មានន័យថាគ្មានបុគ្គលណាម្នាក់អាចទទួលទោសជំនួស ក្រៅតែពីជនល្មើសខ្លួនឯងនោះឡើយ ហើយបើជនល្មើសនោះបានទទួលមរណភាពហើយនោះ គឺគ្មានការទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌទៀតទេ។ មួយវិញទៀតការដាក់ទណ្ឌកម្មព្រហ្មទណ្ឌ គឺក្នុងគោលដៅអប់រំ កែប្រែ ឱ្យជនល្មើសនោះក្លាយទៅជាមនុស្សមានប្រយោជន៍សម្រាប់សង្គមឡើងវិញ និងដើម្បីបង្ហាញឱ្យជនដទៃទៀតខ្លាចរអារក្នុងការប្រព្រឹត្តបទល្មើស មិនមែនក្នុងគោលបំណងសងសឹកនោះឡើយ។ ប៉ុន្តែទោះបីជាបណ្តឹងអាជ្ញាត្រូវបានរលត់ ក៏ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំឱ្យមានការជួសជុលព្យសនកម្ម ពីសិទ្ធិវន្តនៃជនជាប់ចោទបាន ប្រសិនបើជនជាប់ចោទនេះ ទទួលមរណភាពនៅក្នុងពេលដំណើរការរឿងក្តីព្រហ្មទណ្ឌ។ ដោយហេតុថា ទោះបីជាបណ្តឹងអាជ្ញាត្រូវបានរលត់ក៏ដោយ ក៏តុលាការព្រហ្មទណ្ឌ នៅតែមានសមត្ថកិច្ចដើម្បីសម្រេចលើបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងប្រឆាំងនឹងសិទ្ធិវន្តទាំងនោះដែរ។[81]

- **ការផុតអាជ្ញាយុកាល៖** អាជ្ញាយុកាល គឺជាពេលវេលាកំណត់មួយដែលមានចែងក្នុងច្បាប់ អំពីរយៈពេលដែលអាចធ្វើ ឬ ចាប់ផ្តើមបណ្តឹងអាជ្ញាបាន។ កាលណាអាជ្ញាយុកាលនៃបទល្មើសត្រូវបានផុតរលត់ នោះ

[78] គន យឿន, ទាក់ទាងនឹងវិស័យច្បាប់,(ភ្នំពេញ,២០២១),ទំព័រ ១៥៩។
[79] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៧។
[80] គន យឿន, ទាក់ទាងនឹងវិស័យច្បាប់,(ភ្នំពេញ,២០២១),ទំព័រ ១៥៩។
[81] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា២៤។

នាំឱ្យបណ្តឹងអាជ្ញាត្រូវរលត់ ដោយមូលហេតុនៃការផុតអាជ្ញាយុកាល ជាហេតុនាំព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់អ្នកប្រព្រឹត្តបទល្មើសបានឡើយ។

យោងតាមមាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ចិរវេលាអាជ្ញាយុកាលនៃបទល្មើសដោយផ្អែកទៅតាមប្រភេទនៃបទល្មើសដូចតទៅៈ

- ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម
- ១ (មួយ) ឆ្នាំ ចំពោះបទលហុ។

ជាគោលការណ៍ អាជ្ញាយុកាលនៃបទល្មើស ត្រូវចាប់ផ្តើមគិតរាប់ពីពេលប្រព្រឹត្តបទល្មើសតទៅ។ ក៏ប៉ុន្តែបទល្មើសខ្លះមិនមានអាជ្ញាយុកាលទេ មានន័យថា ទោះបីជារយៈពេលយូរយ៉ាងណា បានកន្លងផុតទៅហើយក៏ដោយ ក៏ការចោទប្រកាន់នៅតែអាចធ្វើបានជានិច្ច។ ជាក់ស្តែងបទល្មើសដែលមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម មិនអាចផុតរលត់ដោយអាជ្ញាយុកាលឡើយ។ ព្រមជាមួយគ្នានេះ បទល្មើសប្រល័យពូជសាសន៍ បទល្មើសប្រឆាំមនុស្សជាតិ និងបទល្មើសឧក្រិដ្ឋកម្មសង្គ្រាម ក៏មិនអាចផុតអាជ្ញាយុកាលបានដែរ។[82]

- **ការលើកលែងទោសជាទូទៅៈ** គឺជាវិធានការនីតិកម្មដែលមានគោលដៅលុបចោលនូវលក្ខណៈជាបទល្មើសនៃអំពើមួយចំនួន។ តាមពិតការលើកលែងទោសជាទូទៅ គឺត្រូវស្ថិតក្នុងអំណាចរបស់អង្គការនីតិបញ្ញត្តិ ផ្អែកតាមមាត្រា៩០ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ដោយច្បាប់ស្តីពីការលើកលែងទោសជាទូទៅត្រូវបានអនុម័តក្នុងមូលហេតុមួយចំនួនដូចជា ដើម្បីកុំឱ្យមានចំនួនទណ្ឌិតក្នុងពន្ធនាគារច្រើនពេក ឬក្នុងឱកាសហេតុការណ៍សំខាន់ណាមួយក្នុងប្រទេស។ ទន្ទឹមនឹងនេះ ច្បាប់ស្តីពីការលើកលែងទោសជាទូទៅ រមែងកំណត់យ៉ាងច្បាស់លាស់ ពីកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើសដែលត្រូវលើកលែង ឬពីប្រភេទនៃបទល្មើសត្រូវលើកលែងទោស ឬក៏ពីទោសប្រកាសប្រភេទណាមួយ ដែលនឹងត្រូវទទួលបាននូវការលើកលែង។ ហើយការលើកលែងទោសជាទូទៅ មានអានុភាពលុបចោលទាំងស្រុងនូវទណ្ឌកម្មដែលពាក់ព័ន្ធទាំងអស់។

**ឧទាហរណ៍ៈ** ទណ្ឌិតដែលត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពី ៣ខែ ដល់ ៣ឆ្នាំ នឹងត្រូវទទួលបានការលើកលែងទោសជាទូទៅ។

នៅក្នុងករណីដែលមានការលើកលែងទោសជាទូទៅរួចហើយ ទោសមិនអាចយកមកអនុវត្តបានទេ ហើយទោសដែលកំពុងអនុវត្តត្រូវបានបញ្ចប់។ ក៏ប៉ុន្តែចំពោះប្រាក់ពិន័យ និង ប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ មិនអាចទារសំណងពីរដ្ឋវិញបានទេ។ លើសពីនេះទៅទៀត យោងតាមមាត្រា ១៥១ នៃក្រមព្រហ្មទណ្ឌ

[82] រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ,(ភ្នំពេញ,២០១៧),ទំព័រ ១៩០។

ការលើកលែងទោសជាទូទៅ មិនមែនជាឧបសគ្គដល់ការអនុវត្តសិទ្ធិរបស់ជនរងគ្រោះ ក្នុងការទាមទារដើម្បីទទួលបានសំណងសម្រាប់ជួសជុសការខូចខាតឡើយ លើកលែងតែករណីដែលច្បាប់ស្តីពីការលើកលែងទោសជាទូទៅបានចែងផ្ទុយពីនេះទៅវិញ។[83]

- **និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ៖** បណ្តឹងអាជ្ញាមួយត្រូវបានធ្វើឡើងតាមរយៈនៃការចោទប្រកាន់របស់អយ្យការក្នុងបទល្មើសណាមួយ ប៉ុន្តែដោយហេតុថា បទល្មើសដែលត្រូវបានចោទប្រកាន់នោះត្រូវបាននិរាករណ៍ដោយមានច្បាប់ព្រហ្មទណ្ឌថ្មី ហេតុនេះ បណ្តឹងអាជ្ញាដែលធ្វើឡើងដោយឈរលើមូលដ្ឋាននៃបទល្មើសដែលមានចែងក្នុងច្បាប់ចាស់នឹងត្រូវរលត់ ។[84] មានន័យថា បទបញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម។ អំពើដែលបានប្រព្រឹត្តនៅមុនបទបញ្ញត្តិនេះចូលជាធរមាន គឺមិនអាចត្រូវចោទប្រកាន់បានទៀតនោះឡើយ ហើយរាល់ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះត្រូវតែបញ្ចប់។[85]

- **អាជ្ញាអស់ជំនុំ៖** តាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។[86] មានន័យថា កាលណាអង្គហេតុនៃបទល្មើសមួយ ត្រូវបានកើតឡើង ហើយត្រូវបានធ្វើការចោទប្រកាន់ដោយអយ្យការ និងមានការជំនុំជម្រះសេចក្តីរហូតមានសាលក្រម ឬ សាលដីកាស្ថាពរហើយ អង្គហេតុនោះមិនត្រូវបានលើកយកមកធ្វើការចោទប្រកាន់ជាថ្មីទៀតនោះទេ។

**១.២.២.អភ័យឯកសិទ្ធិ**

អភ័យឯកសិទ្ធិ គឺជាសិទ្ធិពិសេសមួយ ដែលប្រើសម្រាប់ការពារទៅលើបុគ្គលដែលមានលក្ខណៈពិសេសក្នុងការរួចផុតពីការចោទប្រកាន់នៃស្ថាប័នអយ្យការ។ដោយយោងទៅតាមច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ត្រង់មាត្រា៨០ បានចែងថា តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា។ តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសម្តែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិកសភាណាមួយអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពី រដ្ឋសភា ឬគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែងតែប៉ុណ្ណោះ។ រាល់អភ័យឯកសិទ្ធិរដ្ឋសភា

[83] នុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ,(ភ្នំពេញ,២០១៧),ទំព័រ ១៤៦។

[84] គន យឿន, ទាក់ទាងនឹងវិស័យច្បាប់,(ភ្នំពេញ,២០២១),ទំព័រ ១៦០។

[85] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៩។

[86] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ១២។

អភ័យឯកសិទ្ធិព្រឹទ្ធសភា អភ័យឯកសិទ្ធិការទូត ដែលបុគ្គលទាំងនេះត្រូវបានការពារដោយច្បាប់ចំពោះមុខងាររបស់ខ្លួន ក្នុងការបំពេញតួនាទីរបស់ខ្លួន ទោះបីជារកឃើញថាជាបទល្មើសក៏ដោយ តែមិនអាចធ្វើការចោទប្រកាន់បាននោះទេ។ លើសពីនេះ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែងអំពីអភ័យឯកសិទ្ធិគ្រួសារផងដែរ ដែលអភ័យឯកសិទ្ធិគ្រួសារនេះ គឺសំដៅទៅលើភាពមិនអាចផ្តន្ទាទោសព្រហ្មទណ្ឌបានចំពោះជនដែលបានប្រព្រឹត្តបទល្មើសលួច (អំពើលួចទ្រព្យសម្បត្តិ) បើជននោះលួចទ្រព្យសម្បត្តិរបស់បុព្វញាតិ ឬ បច្ឆាញាតិ និងទ្រព្យសម្បត្តិរបស់សហព័ទ្ធខ្លួន។[87] តាមរយៈសទ្ទានុក្រម នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានឱ្យនិយមន័យនៃពាក្យ " បុព្វញាតិ " ថា ជាជនដែលស្ថិតក្នុងថ្នាក់ញាតិខ្ពស់ជាងខ្លួន ពោលគឺ ជីដូនជីតា ឪពុកម្តាយ មាមីង ឬ ន័យសាមញ្ញត្រូវបានហៅថា អ្នកជំនាន់មុន ។ ដោយឡែកសម្រាប់ពាក្យថា " បច្ឆាញាតិ" គឺជន ឬពួកជន ដែលកើតពីជនមួយពួកទៀត ពោលគឺ កូន ចៅ ក្មួយ ឬ ហៅថា អ្នកជំនាន់ក្រោយ។ រីឯពាក្យថា " សហព័ទ្ធ " គឺសំដៅទៅលើ ប្តី ឬ ប្រពន្ធ ឬទាំងប្តីទាំងប្រពន្ធ ដែលទទួលបានឋានៈជាសហព័ទ្ធនេះក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។

ដូច្នេះប្រសិនបើមានករណីលួចទ្រព្យសម្បត្តិ នៅក្នុងសង្គមគ្រួសារ ដែលប្រព្រឹត្តឡើងដោយបុព្វញាតិ ឬបច្ឆាញាតិ ក៏ដូចជាសហព័ទ្ធពិតមែន នោះមាត្រា ៣៥៥ នៃក្រមព្រហ្មទណ្ឌ មានអានុភាពអនុវត្តចំពោះករណីនេះ ដែលអាចឱ្យអ្នកប្រព្រឹត្តនោះ រួចផុតពីការផ្តន្ទាទោស ចំពោះបទល្មើសលួចទ្រព្យសម្បត្តិបាន។ អភ័យឯកសិទ្ធិគ្រួសារនេះ មានគោលបំណងដើម្បីបញ្ចៀសនូវរាល់ផលវិបាកទាំងឡាយ ដែលអាចកើតចេញពីរឿងក្តីព្រហ្មទណ្ឌនៅក្នុងរង្វង់គ្រួសារ។ គួរបញ្ជាក់ផងដែរ អភ័យឯកសិទ្ធិនេះអាចអនុវត្តបានចំពោះតែបទល្មើសលួចតែប៉ុណ្ណោះ ដោយមិនគ្របដណ្តប់លើស្ថានទម្ងន់ទោសទេ។

**ឧទាហរណ៍៖** លោក សំ បានលួចឡានដែលជាកម្មសិទ្ធិរបស់លោក ដារ៉ា ដែលត្រូវជាជីតារបស់ខ្លួនទៅលក់ដើម្បីយកទៅសងបំណុលដែលជំពាក់គេ។ ក្នុងករណីខាងលើនេះ តុលាការមិនអាចផ្តន្ទាទោស លោក សំ បានឡើយ ពីព្រោះ លោក សំ ត្រូវជាចៅ (បច្ឆាញាតិ) របស់លោក ដារ៉ា ដែលត្រូវបានផ្តល់អភ័យឯកសិទ្ធិតាមរយៈមាត្រា ៣៥៥ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

### ១.២.៣. អនិយ័តភាពនៃនីតិវិធី

អនិយ័តភាពនៃនីតិវិធី គឺសំដៅដល់ភាពមិនស្របច្បាប់នៃនីតិវិធី ក្នុងដំណើរប្រតិបត្តិការរបស់ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត ឬការស្រាវជ្រាវបន្ថែមរបស់មន្ត្រីនគរបាលយុត្តិធម៌។ មានន័យថា ប្រតិបត្តិការនេះហាក់ដូចជាមិនស្របច្បាប់នីតិវិធី និងមិនបានលទ្ធផល ឬគ្មានប្រយោជន៍ នោះព្រះរាជអាជ្ញា

[87] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៣៥៥។

អាចសម្រេចតម្កល់រឿងទុកឥតចាត់ការដោយមូលហេតុអនិយ័តនៃនីតិវិធីនេះបាន។ ចំពោះមន្ត្រីនគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការ ហើយមន្ត្រីនគរបាលយុត្តិធម៌ ក៏មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ដោយកំណត់ពីអត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងការប្រមូលភស្តុតាងនៃបទល្មើសផងដែរ។[88] ដោយយោងតាមមាត្រា ១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានចែងអំពីមោឃភាពនៃការមិនគោរពតាមវិធានបញ្ញត្តិ និងទម្រង់នៃកំណត់ហេតុស្តីពីការឃាត់ខ្លួន ដែលមានលក្ខខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នេះទេនឹងនាំឱ្យមានមោឃភាពនៃនីតិវិធី។

**ឧទាហរណ៍១៖** មន្ត្រីនគរបាលយុត្តិធម៌ គាត់ឆែកឆេរដោយបំពាន ដោយសារគាត់បានទៅឆែកឆេរការិយាល័យមេធាវី ឬអាគារសារព័ត៌មានដោយឯកឯង។ ក្នុងករណីបែបនេះ ការឆែកឆេរត្រូវចាត់ទុកជាមោឃៈបានន័យថា អ្វីដែលទទួលបាននៅក្នុងនីតិវិធីនោះ គឺមិនអាចយកជាបានការឡើយ។[89]

**ឧទាហរណ៍២៖** ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការឃាត់ខ្លួនជនល្មើសខុសអត្តសញ្ញាណនៅក្នុងដំណាក់កាលស៊ើបអង្កេតបឋម ដែលអ្នកដែលបានប្រព្រឹត្តបទល្មើសពិតប្រាកដគឺជា លោក សុខ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌បែរជាទៅឃាត់ខ្លួន លោក សំ ទៅវិញ ហើយព្រមទាំងធ្វើកំណត់ហេតុខុសសារតារបស់ជនល្មើសទៀត រួចក៏បញ្ជូនទៅឱ្យព្រះរាជអាជ្ញា ដែលនេះគឺជាការអនុវត្តខុសនីតិវិធីនាំឱ្យព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការដោយមូលហេតុអនិយ័តភាពនៃនីតិវិធីបាន។

#### ១.២.៤. ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ

ជាគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ កាលណាបុគ្គលណាម្នាក់ បានប្រព្រឹត្តបទល្មើសណាមួយ បុគ្គលនោះនឹងទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនដែលបានប្រព្រឹត្តប៉ុណ្ណោះ គឺមិនអាចមានជនណាម្នាក់មកទទួលខុសត្រូវចំពោះទោសកំហុសជំនួសអំពើល្មើសរបស់អ្នកដទៃបាននោះទេ។ ការទទួលទណ្ឌកម្មនេះ គឺជាវិធានការណ៍មួយសម្រាប់ជាការឆ្លើយតបនឹងអំពើអសកម្មនានា ដែលបានកើតឡើងនៅក្នុងសង្គម ដែលសកម្មភាពនេះច្បាប់ឱ្យឈ្មោះថា បទល្មើស ដោយអានុភាពនៃអំពើនេះបង្កឱ្យមានភាពចលាចលក្នុងសង្គម។ ដូចនេះបុគ្គលដែលប្រព្រឹត្តអំពើណាមួយដែលច្បាប់ចាត់ទុកជាបទល្មើសនឹងត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌធ្ងន់ ឬស្រាល អាស្រ័យទៅលើស្ថានភាពនៃការប្រព្រឹត្តបទល្មើសរបស់ជននោះបានធ្វើជាក់ស្តែងតាមករណីនីមួយៗ ដោយពិនិត្យទៅលើសកម្មភាពនៃការប្រព្រឹត្ត និងទំហំព្យសនកម្មដែលទទួលរង។ ប៉ុន្តែនៅក្នុងករណីខ្លះ ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ អាចបណ្តាលមកពីមូលហេតុណាមួយ ដែលច្បាប់ព្រហ្ម

---

[88] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ៥៦។

[89] យោងតាមប្រសាសន៍របស់ **ឯកឧត្តម កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧។

ទណ្ឌចាត់ទុកថាជាមូលហេតុត្រឹមត្រូវ ដូច្នេះទោះបីបុគ្គលនោះបានប្រព្រឹត្តបទល្មើស ដែលត្រូវបានចោទប្រកាន់ក៏ដោយ ក៏ច្បាប់មិនតម្រូវឱ្យអ្នកប្រព្រឹត្តអំពើនោះ ទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

យោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មូលហេតុដែលនាំឱ្យមិនមានការទទួលខុសត្រូវព្រហ្មទណ្ឌ ឬការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ មានដូចជា៖ វិបល្លាសស្មារតី ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ ការការពារស្របច្បាប់ សច្ចធារណ៍នៃការការពារស្របច្បាប់ ស្ថានភាពចាំបាច់ អានុភាពនៃកម្លាំង ឬការបង្ខំ និងអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ។

- **វិបល្លាសស្មារតី៖** វិបល្លាសស្មារតី សំដៅទៅលើជនដែលមានវិបត្តិផ្នែកបញ្ញាស្មារតី វិកលចរិតសតិមិនល្អ ដែលពុំអាចដឹងខុសត្រូវលើទង្វើរបស់ខ្លួនបានដូចមនុស្សធម្មតា ក្នុងរយៈពេលមិនកំណត់ ឬក្នុងមួយរយៈពេលខ្លី ដូច្នេះកាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើសនៅពេលដែលជននោះ កើតវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់នូវសមត្ថភាពយល់ដឹងរបស់ខ្លួន ជននោះមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ។[90] ផ្ទុយទៅវិញ បើជននោះកើតវិបល្លាសស្មារតី ដែលគ្រាន់តែកាត់បន្ថយនូវការដឹងខុសដឹងត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។[91] ការកំណត់ថាជននេះកើតវិបល្លាសស្មារតី ឬគ្រាន់តែអន់បន្ថយនូវការយល់ដឹងខុសត្រូវនោះ ត្រូវមានភស្តុតាងបញ្ជាក់យ៉ាងច្បាស់លាស់ពីគ្រូពេទ្យជំនាញ ដើម្បីឱ្យតុលាការធ្វើការពិនិត្យ និងពិចារណាពីបញ្ហានេះក្នុងការកំណត់ទោស។ ចំពោះជនដែលកើតវិបល្លាសស្មារតីដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ ហើយបានប្រព្រឹត្តបទល្មើស ជននោះមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។[92]

**ឧទាហរណ៍៖** បុគ្គលម្នាក់បានប្រើប្រាស់គ្រឿងញៀន ឬ ថ្នាំសម្រើបមួយចំនួន បណ្ដាលឱ្យមានការពិបាកក្នុងការទប់ស្កាត់កាមតណ្ហារបស់ខ្លួន ហើយក៏បានទៅចាប់រំលោភសេពសន្ថវៈនារីម្នាក់ ដែលនៅក្បែរនោះ។ ក្នុងករណីបែបនេះ ជនល្មើសមិនអាចលើកសំអាងហេតុថា មកពីគាត់បានប្រើប្រាស់គ្រឿងញៀន ឬថ្នាំសម្រើប ទើបធ្វើឱ្យគាត់មិនអាចគ្រប់គ្រងខ្លួនឯងបាន ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាននោះទេ។

- **ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ៖** បុគ្គលណាដែលបានប្រព្រឹត្តអំពើដែលបានបញ្ញត្តិ ឬអនុញ្ញាតដោយច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ។ បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសតាមបញ្ជារបស់អជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនោះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។[93]

[90] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩,កថាខណ្ឌទី១, មាត្រា ៣១។
[91] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩, កថាខណ្ឌទី២, មាត្រា ៣១។
[92] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩, កថាខណ្ឌទី៣, មាត្រា ៣១។
[93] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ៣២។

ក្នុងន័យនេះបុគ្គលដែលបានធ្វើសកម្មភាពណាមួយមិនមែនដោយឆន្ទៈរបស់ខ្លួនឡើយ ប៉ុន្តែធ្វើឡើងតាមច្បាប់ ឬ ការអនុញ្ញាតពីច្បាប់ សកម្មភាព ឬ ក៏អំពើដែលបុគ្គលនោះបានធ្វើមិនចាត់ទុកថា ជននោះបានប្រព្រឹត្តបទល្មើសឡើយ។ កាលណាមិនមែនជាបទល្មើស គឺមិនទទួលនូវទណ្ឌកម្មព្រហ្មទណ្ឌណាមួយឡើយ ព្រោះមិនមែនជាបទល្មើស។

អាជ្ញាធរស្របច្បាប់ គឺសំដៅដល់មន្ត្រីសាធារណៈរបស់រដ្ឋ មានតុលាការ និងមន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីកងរាជអាវុធហត្ថ ព្រមទាំងមន្ត្រីសាធារណៈដទៃទៀតដែលមានភារកិច្ច រក្សាការពារ និងទប់ស្កាត់ បង្ក្រាបបទល្មើស ដែលបានកើតមានឡើងក្នុងសង្គម ដើម្បីធានាឱ្យបាននៅសន្តិភាពសម្រាប់សង្គមជាតិទាំងមូល។[94]

**ឧទាហរណ៍៖** គ្រប់ជនទាំងអស់ ដែលបានឃើញជនល្មើសបានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង គឺមានសិទ្ធិចាប់ខ្លួន ហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ ដែលនៅជិតបំផុត មានន័យថា ការចាប់ខ្លួននេះមិនអាចចាត់ទុកថាជាការរំលោភលើសិទ្ធិបុគ្គល ដូចដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ឡើយ។[95]

- **ការការពារស្របច្បាប់៖** ច្បាប់បានអនុញ្ញាតឱ្យបុគ្គលណាដែលប្រព្រឹត្តបទល្មើស ក្នុងសភាពការការពារស្របច្បាប់ មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ ប៉ុន្តែការការពារស្របច្បាប់នោះត្រូវមានលក្ខខណ្ឌដូចជា៖[96]

- បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវ ដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ដែលប្រឈមមុខនឹងការឈ្លានពានមួយមិនត្រឹមត្រូវ
- បទល្មើស និងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង
- គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។

**ឧទាហរណ៍៖** លោក សុខ បានប្រើប្រាស់គ្រឿងញៀនរាល់ថ្ងៃ ហើយបានយកកាំបិតទៅកាប់ក្បាលម្តាយរបស់ខ្លួន ដោយស្របពេលនោះ លោក សៅ ដែលត្រូវជាប្អូនប្រុសរបស់ លោក សុខ បានឃើញសកម្មភាពនោះ ក៏បានស្ទុះទៅយកដំបងនៅក្បែរខ្លួនវាយលោក សុខ មួយដំបងត្រូវចំក្បាលបណ្តាលឱ្យដួលទៅនឹងដីតែម្តង ក្នុងបំណងការពារម្តាយរបស់ខ្លួន ។ ករណីនេះ លោក សៅ មិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ព្រោះទង្វើនេះជាស្ថានភាពចាំបាច់ដើម្បីការពារអ្នកដទៃ ដែលតបតទៅនឹងអំពើឈ្លានពានមិនត្រឹមត្រូវក្នុងពេលដំណាលគ្នានៃអំពើ ហើយមធ្យោបាយការពារខ្លួនដែលយកមកប្រើប្រាស់មានភាពសមាមាត្រគ្នា។

[94] ធៀង សំណាង,នីតិព្រហ្មទណ្ឌ,(ភ្នំពេញ,២០១៩),ទំព័រ ១០១។

[95] កៅ សីហា,នគរបាលយុត្តិធម៌,(ភ្នំពេញ,២០១២),ទំព័រ ៤៧។

[96] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៣៣។

- **សច្ចធារណ៍នៃការការពារស្របច្បាប់៖** ការសន្មតថាជាការការពារស្របច្បាប់នៅក្នុងករណីដែលបទល្មើសត្រូវបានប្រព្រឹត្តដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយសារកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ។ បទល្មើសបានប្រព្រឹត្តដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា។ សច្ចធារណ៍នៃការការពារស្របច្បាប់ពុំមានលក្ខណៈដាច់ខាតទេ។[97] មានន័យថា ក្នុងករណីដែលមានភស្តុតាងផ្ទុយពីការលើកឡើងនូវសច្ចធារណ៍នេះ សច្ចធារណ៍ដែលជាការសន្មតនេះវានឹងត្រូវបានរលាយ ពោលគឺមិនអាចយកមកអនុវត្តបានឡើយ ដោយសារតែនីត្យានុកូលភាពនៃភស្តុតាងផ្ទុយនោះ។[98]

**ឧទាហរណ៍៖** លោក សំ ជាមន្ត្រីនគរបាលម្នាក់។ នៅយប់មួយប្រហែលម៉ោង ១២ រំលងអធ្រាត្រ ផ្ទះរបស់គាត់ត្រូវបានជនមិនស្គាល់មុខមានគ្នាចំនួន ៥ នាក់ ប្រដាប់ដោយកាំភ្លើងខ្លីមួយដើម បានធ្វើសកម្មភាពចូលប្លន់ផ្ទះរបស់គាត់។ ពេលធ្វើសកម្មភាពប្លន់ ពួកចោរបានបាញ់គំរាម ហើយយកកាំភ្លើងភ្ជុង លោក សំ ដែលជាម្ចាស់ផ្ទះ ជៀសវាងគាត់តដៃវិញ។ ដោយសង្កេតឃើញពួកចោរមានការធ្វេសប្រហែស លោក សំ បានដណ្តើមកាំភ្លើង ហើយបានវាយពួកចោរ បណ្តាលឱ្យចោរម្នាក់រងរបួសតែមិនធ្ងន់ធ្ងរទេ។ ឃើញសភាពការណ៍មិនស្រួលចោរដទៃទៀត បានរត់គេចខ្លួនអស់ នៅសល់តែចោរម្នាក់ដែលរងរបួស ក៏ត្រូវបាន លោក សំ បញ្ជូនទៅប៉ុស្តិ៍នគរបាលដើម្បីចាត់ការបន្ត។

- **ស្ថានភាពចាំបាច់៖** ស្ថានភាពចាំបាច់ គឺជាស្ថានភាពរបស់បុគ្គលម្នាក់ដែលឈានទៅដល់ការប្រព្រឹត្តបទល្មើសណាមួយ ដោយសារតែបុគ្គលនោះមានបំណងចង់ជួយស្តារនូវផលប្រយោជន៍មួយផ្សេងទៀតដែលត្រូវបានគំរាមកំហែងដោយគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន។ ស្ថានភាពចាំបាច់ត្រូវបានចាត់ទុកថាជាយុត្តិកម្មនៃបទល្មើស តាមមាត្រា៣៥ នៃក្រមព្រហ្មទណ្ឌ ដែលបានចែងថា៖ បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ កាលណាបទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និងគ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់។

ដើម្បីឱ្យស្ថានភាពមួយក្លាយទៅស្ថានភាពចាំបាច់ដែលជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ជនដែលបានប្រព្រឹត្តបទល្មើស មានករណីកិច្ចត្រូវតែបង្ហាញភស្តុតាង ពីលក្ខខណ្ឌតម្រូវសម្រាប់បង្កើតជាស្ថានភាពចាំបាច់។ ជាដំបូងត្រូវតែបង្ហាញភស្តុតាងអំពីអត្ថិភាពនៃគ្រោះថ្នាក់កំពុងមាន ឬដែលនឹងកើតមាន

[97] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៣៤។

[98] ឆៀង សំណាង,នីតិព្រហ្មទណ្ឌ,(ភ្នំពេញ,២០១៩),ទំព័រ ១០៦។

ដែលជាមូលហេតុចាំបាច់ នាំឱ្យមានការការពារកើតឡើង ហើយបន្ទាប់មក ត្រូវបញ្ជាក់ឱ្យឃើញថា ការការពារនេះពិតជាមានសមាមាត្រជាមួយនឹងទម្ងន់នៃគ្រោះថ្នាក់ប្រាកដមែន។[99]

**ឧទាហរណ៍៖** ចោរមួយក្រុមបានវាយបំបែកសោរផ្ទះរបស់ លោក សុខ ដើម្បីចូលប្លន់ទ្រព្យសម្បត្តិរបស់គាត់ភ្លាមៗនោះ លោក សុខ ក៏បានយកកាំបិតកាប់ទៅលើចោរនោះ ដើម្បីការពារអាយុជីវិតក្រុមគ្រួសារ និងទ្រព្យសម្បត្តិរបស់គាត់ពីការឈ្លានពានរបស់ក្រុមចោរនោះ។ ដូច្នេះ លោក សុខ ពុំត្រូវបានទទួលទោសព្រហ្មទណ្ឌនោះទេ ។

- **អនុភាពនៃកម្លាំង ឬការបង្ខំ៖** សំដៅទៅដល់បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអនុភាពនៃកម្លាំង ឬការបង្ខំ ដែលបុគ្គលនេះមិនអាចទប់ទល់បាននោះ មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ។ កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ។ កម្លាំង និង ការបង្ខំនេះ ត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន។[100] មានន័យថា ការប្រព្រឹត្តបទល្មើសក្នុងករណីនេះ មិនមែនកើតចេញពីឆន្ទៈរបស់បុគ្គលនោះឡើយ ពោលគឺខ្លួនស្ថិតនៅក្នុងស្ថានមួយ ដែលមិនអាចតតាំងបានដោយសារតែអានុភាពនៃកម្លាំង ឬការបង្ខំណាមួយដែលខ្លួនមិនអាចមានលទ្ធភាព ដើម្បីអាចទប់ទល់បាន។ ម្យ៉ាងទៀតកម្លាំង និងការបង្ខំបុគ្គលនោះ មិនអាចមើលឃើញជាមុន និងមិនអាចជៀសវាងបាន ដូច្នេះ ក៏បានប្រព្រឹត្តបទល្មើស។[101]

**ឧទាហរណ៍៖** កម្លាំងធម្មជាតិរន្ទះបាញ់កង់រថយន្ត បណ្តាលឱ្យអ្នកបើកបររថយន្តម្នាក់ ពុំអាចទប់ចង្កូតរថយន្តបាន ហើយក៏បានជ្រុលរថយន្តទៅកិនលើអ្នកថ្មើរជើងម្នាក់ បណ្តាលឱ្យស្លាប់បាត់បង់ជីវិតនៅនឹងកន្លែងតែម្តង។

- **អ្នកប្រព្រឹត្តជាអនីតិជន៖** អនីតិជន គឺជាជនដែលច្បាប់មិនទាន់ឱ្យទទួលខុសត្រូវលើកអំពើដែលខ្លួនបានប្រព្រឹត្ត និងជាជនដែលច្បាប់កំណត់ឱ្យទទួលខុសត្រូវលើអំពើរបស់ខ្លួនដោយមានកម្រិត។[102] ជាគោលការណ៍ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើយទៅ[103] ដូចនេះនៅពេលដែលជនល្មើសមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ រាល់បទល្មើសព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្ត តុលាការនឹងអាចផ្តន្ទាទោសផ្នែកព្រហ្មទណ្ឌបាន ដែលទោសទាំងនោះមានទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ប៉ុន្តែក្នុងក្រមព្រហ្មទណ្ឌ ក៏បានចែងផងដែរថា អនីតិជនមានអាយុចន្លោះ

[99] រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, សៀវភៅសិក្សានីតិព្រហ្មទណ្ឌទូទៅ,(ភ្នំពេញ,២០២២),ទំព័រ ៣៥៩។

[100] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៣៦។

[101] អៀង សំណាង,នីតិព្រហ្មទណ្ឌ,(ភ្នំពេញ,២០១៩),ទំព័រ ១០៩។

[102] ទីស្តីការគណៈរដ្ឋមន្ត្រី, សទ្ទានុក្រមច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ ឆ្នាំ ២០០១១,ទំព័រ ៦៩។

[103] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៣៨។

ពី ១៤ (ដប់បួន) ឆ្នាំ ទៅដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ តុលាការអាចវិនិច្ឆ័យទោសទៅតាមកាលៈទេសៈនៃបទល្មើសដែលបានប្រព្រឹត្ត ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះ។[104] ក្នុងករណីដែលចៅក្រមសម្រេចចោទប្រកាន់។ ក្រមព្រហ្មទណ្ឌមាត្រា ១៦០ បានកំណត់ថា ទោសដែលត្រូវចោទប្រកាន់ទៅលើបទល្មើសនោះ ត្រូវកាត់បន្ថយពាក់កណ្ដាលពីទោសធម្មតា ឬអប្បបរមានៃទោសនោះលើសពី ១ (មួយ) ថ្ងៃ តែបើអប្បបរមានៃទោសនោះត្រូវដាក់ពន្ធនាគារអស់មួយជីវិត ត្រូវកាត់បន្ថយមកត្រឹម ២០ (ម្ភៃ) ឆ្នាំ។ បើយោងទៅតាមគោលការណ៍ អនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។[105] ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការបាន និងប្រគល់អនីតិជនឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីដែលអនីតិជននោះមានអាយុក្រោម ១៤ (ដប់បួន)ឆ្នាំ គិតត្រឹមថ្ងៃសង្ស័យចូលរួមប្រព្រឹត្តបទល្មើស។[106] ទោះបីជាព្រះរាជអាជ្ញារកឃើញពីអត្ថិភាពនៃបទល្មើសនោះក៏ដោយ។

ដូចនេះក្នុងក្រមព្រហ្មទណ្ឌបានបញ្ញត្តិយ៉ាងពិសេស អំពីមូលហេតុនៃការមិនទទួលខុសត្រូវ ព្រមទាំងស្ថានសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌបែបនេះឡើង ក្នុងគោលបំណងការពារដល់បុគ្គល ដែលកើតវិបល្លាសស្មារតី បាត់បង់ការយល់ដឹងរបស់ខ្លួន ក្នុងអំឡុងពេលប្រព្រឹត្តបទល្មើស តាមការទទួលបញ្ជាពីអាជ្ញាធរស្របច្បាប់ និងការការពារខ្លួន ការពារអ្នកដទៃ ឬការការពារទ្រព្យសម្បត្តិ ដែលកំពុងប្រឈមនឹងការឈ្លានពានខុសច្បាប់។ ដោយឡែក ក្រៅពីមូលហេតុខាងលើនេះ អនីតិជនអាយុក្រោម ១៤ ឆ្នាំ ក៏មិនត្រូវបានឱ្យទទួលទោសព្រហ្មទណ្ឌនោះទេ ប៉ុន្តែអំពើដែលអនីតិជនបានប្រព្រឹត្ត ឪពុក ម្ដាយ ឬអាណាព្យាបាលរបស់អនីតិជននោះ គឺជាអ្នកទទួលខុសត្រូវនូវសំណងរដ្ឋប្បវេណីទៅលើជនរងគ្រោះ ។

### ១.២.៥. មូលហេតុផ្សេងទៀតនៃការរួចផុតនៃបណ្ដឹងអាជ្ញា

ការតម្កល់រឿងទុកឥតចាត់ការអាចធ្វើឡើងបានដោយផ្អែកទៅលើមូលហេតុផ្សេងទៀត ការរលត់បណ្ដឹងអាជ្ញា ដោយមូលហេតុនេះផងដែរ ត្រូវបានដោះស្រាយតាមរូបភាពផ្សេងទៀត ក្នុងករណីដែលពាក្យបណ្ដឹងជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ពីបទព្រហ្មទណ្ឌ។ ដើម្បីប្រើជាមូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ គឺទាមទារចាំបាច់នូវការកំណត់ច្បាប់ដោយឡែកណាមួយ ដែលបានចែងដោយជាក់លាក់ថា ក្នុងស្ថានភាពណាមួយដែលបណ្ដឹងអាជ្ញានឹងផុតរលត់។[107]

---

[104] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ៣៩។

[105] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩, មាត្រា ១៦០។

[106] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦,មាត្រា ២៧។

[107] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ៨។

- **ការសម្របសម្រួលជាមួយរដ្ឋ៖** ជាគោលការណ៍ ការសម្របសម្រួលមិនអាចធ្វើទៅបានឡើយ ចំពោះបទល្មើសព្រហ្មទណ្ឌ។ ប៉ុន្តែក្នុងករណីមានច្បាប់ពិសេសចែងពីការសម្របសម្រួលជាមួយរដ្ឋ គឺអាចអនុញ្ញាតឱ្យរំលត់បណ្តឹងអាជ្ញាបានផងដែរ។ ជាទូទៅ ការសម្របសម្រួលនេះទៀតសោត អាចធ្វើទៅបានលុះត្រាតែអំពើនោះ មិនធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈ ហើយជនដែលបានប្រព្រឹត្តព្រមទទួលស្គាល់កំហុស និងសន្យាកែប្រែកំហុស។ លើសពីនេះ ប្រសិនបើការសម្របសម្រួលនាំឱ្យមានការរំលត់បណ្តឹងអាជ្ញា នោះការសម្របសម្រួលនោះ ក៏មិនមែនជាមូលហេតុនៃការរលត់បណ្តឹងរដ្ឋប្បវេណីឡើយ មានន័យថា ជនរងគ្រោះនៅតែអាចដាក់ពាក្យប្តឹងក្នុងរឿងរដ្ឋប្បវេណីបាន ដើម្បីទាមទារឱ្យជនល្មើសជួសជុលសំណងនៃការខូចខាត និងសំណងជំងឺចិត្តជាដើម។[108]

**ឧទាហរណ៍៖** ចំពោះបទល្មើសដែលជាអំពើហិង្សាប៉ះពាល់ខាងផ្លូវចិត្ត ឬផ្លូវជីវភាពសេដ្ឋកិច្ច និងបទល្មើសមជ្ឈិមស្រាល ឬបទលហុ ការផ្សះផ្សា ឬការសម្របសម្រួលអាចធ្វើទៅបាន តាមការយល់ព្រមពីភាគីទាំងសងខាង។[109]

- **ការដកពាក្យប្តឹង៖** ជាទូទៅ ការដកពាក្យប្តឹងដោយជនរងគ្រោះ ពុំអាចធ្វើឱ្យអាជ្ញាយុកាលនៃបណ្តឹងអាជ្ញារលត់ទេ។ បើទោះបីជាជនរងគ្រោះព្រមដកពាក្យប្តឹង ឬព្រមទទួលសំណងនៃការខូចខាតក៏ដោយ ក៏ព្រះរាជអាជ្ញានៅតែមានសិទ្ធសម្រេចក្នុងការចោទប្រកាន់ទៅលើបទល្មើសនោះបានដដែល។ ប៉ុន្តែចំពោះបទល្មើសមួយចំនួន ការដកពាក្យប្តឹងរបស់អ្នកទទួលរងការខូចខាត នាំឱ្យមានការរលត់បណ្តឹងអាជ្ញាផងដែរ ដោយមូលហេតុនៃការដកពាក្យប្តឹង នៅក្នុងករណីដែលពាក្យប្តឹងនោះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ។[110] ជាក់ស្តែងក្នុងច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦ បានចែងថា បុរស ឬស្ត្រី ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ហើយទៅរួមសេវនកិច្ចជាមួយបុរស ឬស្ត្រីដទៃទៀតចាត់ទុកថាជាបទផិត។[111] ក្នុងករណីនេះព្រះរាជអាជ្ញាអាចសម្រេចមិនធ្វើបណ្តឹងអាជ្ញាបាន ប្រសិនបើមានបណ្តឹងរបស់សហព័ទ្ធណាមួយស្នើសុំកុំឱ្យចោទប្រកាន់ទៅលើសហព័ទ្ធម្ខាងទៀត។[112] បន្ថែមពីនេះ ការជេរប្រមាថ ឬការបរិហារកេរ្តិ៍ មិនអាចចោទប្រកាន់បានទេ បើសិនជាគ្មានការដាក់ពាក្យបណ្តឹងពីសំណាក់ជនរងគ្រោះ ប្រសិនបើពាក្យបណ្តឹងដែលបានដាក់ហើយ ត្រូវ

[108] រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត,នីតិវិធីព្រហ្មទណ្ឌ,(ភ្នំពេញ,២០១៣-២០១៤),ទំព័រ ៦។

[109] ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ,លេខ នស/រកម/១០០៥/០៣១, ២៤ តុលា ២០០៥, មាត្រា២៦។

[110] រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត,នីតិវិធីព្រហ្មទណ្ឌ,(ភ្នំពេញ,២០១៣-២០១៤),ទំព័រ ៧។

[111] ច្បាប់ស្តីពីឯកពន្ធភាព,លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦, មាត្រា៧។

[112] ច្បាប់ស្តីពីឯកពន្ធភាព,លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦, មាត្រា៨។

ដកវិញដោយជនរងគ្រោះ នោះបណ្តឹងអាជ្ញានឹងត្រូវរលត់ដូចគ្នា។ មួយវិញទៀត ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ ផងដែរក៏បានចែងថា ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជន ដោយបទល្មើសនោះជាបទមជ្ឈិមស្រាល ឬបទលហុ។ ក្នុងករណីដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងជាថ្មីម្តងទៀត ដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ តុលាការត្រូវតែធ្វើការចោទប្រកាន់ជនមុខសញ្ញារូបនោះតាមនីតិវិធីព្រហ្មទណ្ឌ ទោះបីជាមានការស្នើសុំពីជនរងគ្រោះម្តងទៀតក៏ដោយ។[113]

- **ការបង់ប្រាក់ពិន័យសុប ឬប្រាក់ពិន័យសម្របសម្រួល៖** ជាគោលការណ៍បទល្មើសព្រហ្មទណ្ឌ ការសម្របសម្រួលរវាងជនល្មើស និងជនរងគ្រោះ ក្នុងការព្រមទទួលសំណង ដើម្បីជួសជុលនូវព្យសនកម្ម ជនល្មើសមិនអាចរួចផុតពីការទទួលខុសត្រូវបានឡើយ គ្រាន់តែជាការរួចផុតពីបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ។ ប៉ុន្តែមានបទល្មើសមួយចំនួនអាចបញ្ចប់បានដោយមិនចាំបាច់ធ្វើបណ្តឹងអាជ្ញា ឬចោទប្រកាន់ គឺគ្រាន់តែបង់ប្រាក់ពិន័យសុប ឬប្រាក់ពិន័យសម្របសម្រួលតែប៉ុណ្ណោះ។[114] ជាក់ស្តែង ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ឆ្នាំ ២០១៥ បានចែងថា បទល្មើសចរាចរណ៍ដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក។ មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក អាចសម្រុះសម្រួលក្នុងករណីមានគ្រោះថ្នាក់ ដែលបណ្តាលឱ្យសងតែសំណងខូចខាត។[115] បន្ថែមពីនេះ អំពើល្មើសដែលត្រូវទទួលរងពិន័យអន្តរកាណ៍ ហើយជនពាក់ព័ន្ធមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍តាមការកំណត់ មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ត្រូវបញ្ជូនកំណត់ហេតុព្រមទាំងវត្ថុតាងទៅអយ្យការអមសាលាដំបូង។[116]មួយវិញទៀតចំពោះករណីបទល្មើសព្រៃឈើ រដ្ឋបាលព្រៃឈើមានសិទ្ធិពិន័យជាអន្តរការណ៍ក្នុងករណីដែលជនល្មើសព្រមសារភាពនូវទោសកំហុសរបស់ខ្លួន និងព្រមបង់ប្រាក់ពិន័យទៅតាមទោសប្បញ្ញត្តិ។[117] រួមទាំងបទល្មើសគយ ដែលរដ្ឋបាលគយមានសិទ្ធិសម្រុះសម្រួល និងប្រើប្រាស់ចំពោះតែការពិន័យជាប្រាក់តែប៉ុណ្ណោះ។ តែការសម្រុះសម្រួលនេះ អាចធ្វើទៅបាននៅមុនពេលមានសាលក្រមរបស់តុលាការមានសមត្ថកិច្ច។[118]

---

[113] ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ,លេខ នស/រកម/១០០៥/០៣១, ២៤ តុលា ២០០៥, មាត្រា៣៦។

[114] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៨។

[115] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក,លេខ នស/រកម/០១១៥/០១១,០៦ មករា ២០១៥,មាត្រា៦៥។

[116] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក,លេខ នស/រកម/០១១៥/០១១,០៦ មករា ២០១៥,មាត្រា៨៧។

[117] ច្បាប់ស្តីពីព្រៃឈើ,លេខ នស/រកម/០៨០២/០១៦,៣០ សីហា ២០០២,មាត្រា៩១។

[118] ច្បាប់ស្តីពីគយ,លេខ នស/រកម/០៧០៧/០១៧,២០ កក្កដា ២០០៧,មាត្រា៧៧។

ជារួមមក ចំពោះបទល្មើសដែលផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ អាចឱ្យអ្នកប្រព្រឹត្តរួចផុតពីបណ្តឹងអាជ្ញា តាមរយៈការបង់ប្រាក់ពិន័យអន្តរការណ៍នេះតែម្តង។

**១.៣. ការចោទប្រកាន់មិនផ្តល់ប្រយោជន៍**

ការចោទប្រកាន់មិនផ្តល់ប្រយោជន៍ គឺសំដៅដល់ការថ្លឹងថ្លែងរបស់ព្រះរាជអាជ្ញា ឬតំណាងអយ្យការទៅលើ ស្ថានភាពណាមួយដែលពាក់ព័ន្ធបទល្មើស ចារី សហចារី ជនរងគ្រោះ ជាអាទិ៍ ហើយក៏បានរកឃើញថារាល់បទល្មើសទាំងអស់នោះ ប្រសិនបើធ្វើការចោទប្រកាន់ វាហាក់បីដូចជាមិនបានផ្តល់ផលប្រយោជន៍អ្វីសោះដល់សង្គមជាតិ។ ប៉ុន្តែទោះបីជាអំពើដែលប្រព្រឹត្តនោះ គឺជាបទល្មើសក្តីក៏ព្រះរាជអាជ្ញាអាចធ្វើការពិចារណាថ្លឹងថ្លែងថាគួរតែធ្វើការចោទប្រកាន់ ឬធ្វើការតម្កល់រឿងទុកឥតចាត់ការ ដោយអាស្រ័យទៅលើស្ថានភាព និងកាលៈទេសៈនានានៃបទល្មើស ឬជនល្មើស។ ជាទូទៅកម្មវត្ថុនៃការចោទ គឺជាការទាមទាឱ្យជនល្មើសមកទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌ មិនតែប៉ុណ្ណោះក៏ចាំបាច់ផងដែរសម្រាប់ការធានាដល់សិទ្ធិជនរងគ្រោះក្នុងបទល្មើសនោះ ដើម្បីទទួលបាននូវសំណងព្យសនកម្ម ពីអំពើល្មើសរបស់ជនល្មើសមកលើខ្លួន។ ម្យ៉ាងទៀតការចោទប្រកាន់នោះអាចមិនផ្ទុយពីគោលបំណងនៃបណ្តឹងអាជ្ញាផងដែរ។ មូលហេតុដែលនាំឱ្យការចោទប្រកាន់របស់តំណាងអយ្យការ ឬព្រះរាជអាជ្ញាមិនផ្តល់ប្រយោជន៍នោះ អាចបណ្តាលមកពីកត្តាមួយចំនួនដូចជា៖

- **កត្តាចំណាត់ការ៖** សំដៅដល់ស្ថានភាពមួយ ដែលការចោទប្រកាន់មិនបានផ្តល់ផលប្រយោជន៍ដោយសារចំណាត់ការនៃនីតិវិធី។ ចំណាត់ការនៃនីតិវិធី អាចជាកាលៈទេសៈមួយដែលកិច្ចស៊ើបអង្កេតមិនបានផល ដែលអាចមកពីមូលហេតុនៃការអូសបន្លាយពេលយូរក្នុងការស៊ើបអង្កេតជាអាទិ៍។

- **ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង៖** សំដៅដល់ស្ថានភាព ដែលជនរងគ្រោះខ្លួនឯង បានបោះបង់ចោលពាក្យបណ្តឹង ឬការដែលមិនអើពើចំពោះអំពើល្មើសមកលើខ្លួន ឬការខកខាននៅក្នុងនីតិវិធី។

- **កត្តាចារី៖** សំដៅដល់ស្ថានភាពមួយដែលអ្នកប្រព្រឹត្ត ឬចារី ស្ថិតក្នុងស្ថានភាពចាំបាច់ណាមួយ។ ស្ថានភាពទាំងនោះអាចជា ស្ថានភាពដែលចារីមានអាកប្បកិរិយា និងទទួលស្គាល់កំហុសដែលខ្លួនបានប្រព្រឹត្ត ឬ អាចជាស្ថានភាពបញ្ហាបន្ទុកគ្រួសារ។

- **ព្យសនកម្ម៖** សំដៅដល់ស្ថានភាពដែលអំពើល្មើសនោះ បានហុចផល ដែលជាព្យសនកម្មមានលក្ខណៈតិចតួច ឬអាចជាភាពដែលព្យសនកម្មបានកើតចេញពីអំពើល្មើស ប៉ុន្តែព្យសនកម្មត្រូវបានប៉ះប៉ូវ។

- **អំពើល្មើសដែលបង្កព្យសនកម្មតិចតួច៖** ក្រោយពីព្រះរាជអាជ្ញាទទួលបាននូវបណ្តឹង ព្រះរាជអាជ្ញាត្រូវថ្លឹងថ្លែងអំពីអំពើនោះ ដើម្បីសម្រេចថា ចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ។ ការថ្លឹងថ្លែង

របស់ព្រះរាជអាជ្ញានោះ ត្រូវថ្លឹងថ្លែងទៅលើចរិកគ្រោះថ្នាក់ និង ព្យសនកម្មរបស់អំពើនោះ ដែលប៉ះពាល់ទៅដល់ជនរងគ្រោះ ក៏ដូចជាសង្គមជាតិទាំងមូល។ កម្មវត្ថុនៃការចោទប្រកាន់គឺមានគោលបំណងស្វែងរកការពិតនៃបទល្មើស និងចង្អុលបង្ហាញជនល្មើស ដើម្បីយកមកផ្តន្ទាទោស។

**ឧទាហរណ៍៖** លោក សុខា បានបានលួចផ្លែស្វាយរបស់ លោក ហេង មួយផ្លែ។ បើយើងក្រឡេកមើលក្រមព្រហ្មទណ្ឌ មាត្រា ៣៥៣ ឃើញថា សកម្មភាពលោក សុខា ត្រូវបានចាត់ទុកជាបទល្មើសលួច ព្រោះវាជាការដកហូតដោយទុច្ចរិតនូវព្រទ្យសម្បត្តិរបស់អ្នកដទៃ។ ប៉ុន្តែដោយហេតុថា អំពើនេះវាជាអំពើល្មើសមួយដែលមានព្យសនកម្មតូចតាច មិនមានផលប៉ះពាល់អ្វីធ្ងន់ធ្ងរសោះដល់សង្គម ហើយពិសេសនោះ ជនរង់គ្រោះមិនទាំងអើពើលើអំពើដែលជននោះបានប្រព្រឹត្តផង ។

ដូចនេះ ការចោទប្រកាន់មិនផ្តល់ប្រយោជន៍ សំដៅដល់ការចោទប្រកាន់ដែលធ្វើឡើងនាំឱ្យខាតពេលវេលា មិនបានផ្តល់ប្រយោជន៍អ្វីដល់ជនរងគ្រោះ ឬដើមបណ្តឹង និងមិនផ្តល់ប្រយោជន៍អ្វីដល់សង្គម ហើយហាក់មិនអាចសម្រេចនូវកម្មវត្ថុនៃការចោទប្រកាន់។ ហេតុដូច្នេះហើយ វានឹងក្លាយជាកម្មវត្ថុនៃការពិចារណាលើការមិនចោទប្រកាន់របស់ព្រះរាជអាជ្ញា ដែលនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការ។

## ផ្នែកទី២. នីតិវិធី ទម្រង់ការ និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

ក្នុងករណីដែលតំណាងអយ្យការ ឬព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ចំពោះអង្គហេតុណាមួយដោយផ្អែកទៅតាមមូលហេតុដែលបានបកស្រាយខាងលើ ដោយធ្វើឡើងទៅតាមនីតិវិធីមួយច្បាស់លាស់ត្រឹមត្រូវតាមទម្រង់ការនៃដីកា ដើម្បីឱ្យដីកាសម្រេចនោះមានអានុភាពក្នុងការអនុវត្ត។

### ២.១. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

ក្រោយពីទទួលបានពាក្យបណ្តឹងសាមញ្ញ ឬបណ្តឹងបរិហារដោយផ្ទាល់ ឬតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញាត្រូវថ្លឹងថ្លែងអំពីចំណាត់ការនៃបណ្តឹងនោះ។ ក្នុងករណីដែលព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវចេញដីកាមួយហៅថា ដីកាតម្កល់រឿងទុកឥតចាត់ការ។ ដើម្បីឱ្យដីកានេះមានអានុភាពអនុវត្តន៍ លុះត្រាតែការចេញដីកាត្រូវបានធ្វើឡើងតាមនីតិវិធីដែលច្បាប់បានកំណត់។

កាលណាបណ្តឹងណាមួយត្រូវបានតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់អ្នកប្តឹងអំពីសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២(ពីរ) ខែ គិតចាប់ពីថ្ងៃចុះពាក្យបណ្តឹងនៅក្នុងបញ្ជី។[119] មានន័យថា កាលណាព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ព្រះរាជ

[119] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ៤១។

អាជ្ញា ត្រូវផ្តល់ដំណឹងអំពីការសម្រេចទៅអ្នកប្តឹងឱ្យបានឆាប់បំផុត ដោយមិនឱ្យលើសពីរយៈពេល ២ (ពីរ) ខែទេ។ ហើយការជូនដំណឹងអំពីការសម្រេចគឺ មានគោលបំណងគោរពនូវសិទ្ធិរបស់អ្នកប្តឹង ដើម្បីឱ្យបានដឹងអំពីសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា និងធានាឱ្យបាននូវសិទ្ធិប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចនោះ។ ក្នុងករណីដែលអ្នកប្តឹងមិនសុខចិត្ត អាចប្តឹងតវ៉ាអំពីសេចក្តីសម្រេចនេះទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលជានាយឋានានុក្រមរបស់ព្រះរាជអាជ្ញា។[120] ចំពោះរយៈពេលនៃការផ្តល់ដំណឹង គឺយ៉ាងយូរបំផុត ២ (ពីរ) ខែ គិតចាប់ពីថ្ងៃចុះពាក្យបណ្តឹងក្នុងបញ្ជី ដែលបញ្ជីនោះជាបញ្ជីរបស់អយ្យការសម្រាប់ចុះបណ្តឹងនៅតាមតុលាការជាន់ដំបូងនីមួយៗ ហើយស្ថិតនៅក្រោមការកាន់កាប់របស់លេខាធិការរបស់អយ្យការ និងក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញាផ្ទាល់។[121]

### ២.២. ទម្រង់ការនៃដីកាតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ ស្តែងឡើងតាមរយៈដីកាតម្កល់រឿងទុកឥតចាត់ការ។ ហើយទម្រង់នៃការតម្កល់រឿងទុកឥតចាត់ការ សំដៅដល់ធាតុទាំងឡាយដែលចាំបាច់តម្រូវឱ្យមានក្នុងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ដើម្បីឱ្យដីកានេះមានភាពត្រឹមត្រូវ និងមានអានុភាពអនុវត្តន៍ទៅបាន។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ មិនបានចែងពីទម្រង់ការនៃដីកាតម្កល់រឿងទុកឥតចាត់ការឱ្យបានច្បាស់លាស់នោះទេ គ្រាន់តែបានចែងថា ការតម្កល់រឿងទុកឥតចាត់ការ ត្រូវតែមានសំអាងហេតុ និងសំអាងច្បាប់។[122] ចំពោះសំអាងហេតុ សំដៅដល់ការលើកយកទឡ្ហីករណ៍នៃហេតុការណ៍ ឬស្ថានភាពទាំងឡាយណាដែលពាក់ព័ន្ធមកធ្វើជាអំណះអំណាង ដែលជាមូលហេតុនាំឱ្យមានការសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ចំណែកឯសំអាងច្បាប់ សំដៅដល់ការលើកយកនូវអត្ថបទច្បាប់ដែលគាំទ្រដល់អង្គហេតុ និងមូលដ្ឋាននៃអំណះអំណាង ដែលនាំឱ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ។

ដូចនេះ ដីកាតម្កល់រឿងទុកឥតចាត់ការ ដាច់ខាតត្រូវតែមានការបញ្ជាក់ពីសំអាងហេតុ និងសំអាងច្បាប់ ដែលជាលក្ខខណ្ឌចាំបាច់ដោយមិនអាចខ្វះបាន។

**ឧទាហរណ៍៖** "**សំអាងហេតុ**" បុរស **ក** បានសម្លាប់ស្ត្រីម្នាក់ ដែលជាប្រពន្ធរបស់ខ្លួនដោយសារភ្លើងប្រច័ណ្ឌ បន្ទាប់មកបុរស **ក** ក៏ធ្វើអត្តឃាតខ្លួនឯង។ "**សំអាងច្បាប់**" ដោយយោងតាមមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មរណភាពនៃជនល្មើស ជាមូលហេតុនៃការរលត់បណ្តឹងអាជ្ញា។

[120] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី៤, មាត្រា ៤១។

[121] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ៥០។

[122] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី២,មាត្រា ៤១។

### ២.៣. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ការតម្កល់រឿងទុកឥតចាត់ការ គ្មានអាជ្ញាអស់ជំនុំទេ។[123] មានន័យថា ប្រសិនបើព្រះរាជអាជ្ញាសម្រេចមិនធ្វើការចោទប្រកាន់ មិនមែនបានសេចក្តីថាជននោះរួចផុតពីការចោទប្រកាន់ជាស្ថាពរនោះទេ ក្នុងករណីដែលព្រះរាជអាជ្ញាស្វែងរក ឬទទួលនូវភស្តុតាងថ្មីសម្រាប់ធ្វើការដាក់បន្ទុក ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់សារជាថ្មីម្តងទៀតបាន លើកលែងតែបណ្តឹងអាជ្ញាត្រូវរលត់។ ការកំណត់អាជ្ញាអស់ជំនុំមិនអាចស្តែងបានឡើយ ព្រោះវាជាការផ្តោតតែលើការសម្រេចដោយឆន្ទានុសិទ្ធរបស់ព្រះរាជអាជ្ញា ដែលបានធានាដល់សិទ្ធិរបស់ជនរងគ្រោះនៃអំពើល្មើស ដើម្បីឱ្យមានការសើរើឡើងវិញចំពោះការសម្រេចសេចក្តីរបស់ព្រះរាជអាជ្ញា នៅពេលដែលព្រះរាជអាជ្ញាធ្វើការសម្រេចដោយមានការខុសឆ្គង ឬ មានចន្លោះប្រហោងត្រង់ចំនុចណាមួយជាយថាហេតុ។

## ផ្នែកទី៣. យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ

យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ គឺសំដៅដល់នីតិវិធីទាំងឡាយណា ដែលធ្វើឡើងក្នុងគោលបំណងនាំឱ្យមានការចោទប្រកាន់ឡើងវិញ នៅពេលដែលមានការតម្កល់រឿងទុកឥតចាត់ការ។ ដោយហេតុថា ការតម្កល់រឿងទុកឥតចាត់ការ គឺមានលក្ខណៈមិនដាច់ខាតនោះទេ ពោលគឺក្រោយពីមានការតម្កល់រឿងទុកឥតចាត់ការហើយ ជនល្មើសអាចនឹងត្រូវបានចោទប្រកាន់ឡើងវិញម្តងទៀតបាន លើកលែងតែមានការរលត់បណ្តឹងអាជ្ញា។ ការសម្រេចមិនចោទប្រកាន់របស់ព្រះរាជអាជ្ញា អាចជាការថ្លឹងថ្លែងប្រកបទៅដោយភាពត្រឹមត្រូវ ប៉ុន្តែវាក៏អាចជាការខុសឆ្គងផងដែរលើការសម្រេចមិនចោទប្រកាន់ខាងបទព្រហ្មទណ្ឌ របស់ព្រះរាជអាជ្ញា។ ដូចនេះដើម្បីធានាថាទោះបីជាមានការតម្កល់រឿងទុកឥតចាត់ការយ៉ាងណាក៏ដោយ ក៏វានៅតែអាចយកមកដោះស្រាយឡើងវិញបានផងដែរ ដោយប្រើយន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការមួយនេះ។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថា យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការមានដូចជា៖

- ការសើរើសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា
- បណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- អំណាចអធិបញ្ជាដោយឋានានុក្រមនៃអង្គការអយ្យការ និង
- ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

[123] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី២,វាក្យខណ្ឌទី២,មាត្រា ៤១។

### ៣.១. ការសើរើសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា

ប្រសិនបើព្រះរាជអាជ្ញាបានសម្រេចតម្កល់រឿងទុកឥតចាត់ការ ហើយពុំមានការតវ៉ាតាមរយៈយន្តការណាមួយ ដែលធ្វើឡើងចំពោះសេចក្តីសម្រេចនេះទេ សំណុំរឿងព្រហ្មទណ្ឌនោះនឹងត្រូវបញ្ចប់។ ប៉ុន្តែការតម្កល់រឿងទុកឥតចាត់ការពុំនាំឱ្យមាននូវអានុភាពអាជ្ញាអស់ជំនុំកើតឡើងនោះទេ[124] ហើយតាមរយៈបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទោះបីជាមានការសម្រេចតម្កល់រឿងទុកឥតចាត់ការក៏ដោយ ក៏ព្រះរាជអាជ្ញាអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញបានដែរ តែការសើរើកែប្រែនេះ អាចធ្វើក្នុងខណៈដែលបណ្តឹងអាជ្ញាមិនទាន់ផុតរលត់អាជ្ញាយុកាលប៉ុណ្ណោះ។[125] មូលហេតុដែលច្បាប់បានអនុញ្ញាតឱ្យព្រះរាជអាជ្ញា អាចធ្វើការចោទប្រកាន់ឡើងវិញបាន ដោយហេតុថាការសម្រេចតម្កល់រឿងទុកឥតចាត់ការអាចនឹងមានភាពខុសឆ្គង ឬមានភាពខ្វះចន្លោះក្នុងប្រការណាមួយដែលនាំឱ្យមានការសម្រេចសេចក្តី មានភាពមិនត្រឹមត្រូវទៅតាមនីតិវិធីច្បាប់។ ម្យ៉ាងវិញទៀត កាលដែលព្រះរាជអាជ្ញាសម្រេចចោទប្រកាន់សារជាថ្មីបាន អាចដោយហេតុថាមានអង្គហេតុថ្មីត្រូវបានរកឃើញ ឬមានភស្តុតាងណាមួយបានលេចឡើង បង្កើតឱ្យអំពើល្មើសនោះក្លាយទៅជាបទល្មើសព្រហ្មទណ្ឌពេញលេញ ដែលអាចនាំឱ្យធ្វើការចោទប្រកាន់បាន។

ដូចនេះការបើកផ្លូវឱ្យព្រះរាជអាជ្ញា អាចធ្វើការសើរើកែប្រែសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ខ្លួនឡើងវិញនេះ គឺជានីតិវិធីមួយដែលត្រូវបានផ្តល់ឱ្យព្រះរាជអាជ្ញា ក្នុងការបំពេញតួនាទីរបស់ខ្លួនឱ្យបានត្រឹមត្រូវ ហើយដើម្បីការពារផលប្រយោជន៍របស់ជនរងគ្រោះ និងមិនអនុញ្ញាតឱ្យជនល្មើសរួចផុតពីការចោទប្រកាន់នូវអំពើល្មើសដែលខ្លួនបានប្រព្រឹត្តនោះ។ ម្យ៉ាងទៀតការដែលច្បាប់អនុញ្ញាតឱ្យព្រះរាជអាជ្ញា ធ្វើការកែប្រែនូវសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ខ្លួនបែបនេះ ក៏ជាវិធានមួយដែលធ្វើឱ្យតំណាងអយ្យការបំពេញនូវតួនាទីរបស់ខ្លួនឱ្យបានត្រឹមត្រូវ តាមរយៈការកែប្រែនូវសេចក្តីសម្រេច ដែលមានការខុសឆ្គង ឬខ្វះចន្លោះនោះឡើងវិញ។

### ៣.២. បណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិថា នៅពេលដែលពាក្យប្តឹងស្ថិតនៅដោយគ្មានចម្លើយ ឬត្រូវបានសម្រេចតម្កល់រឿងទុកឥតចាត់ការដោយព្រះរាជអាជ្ញា ជនរងគ្រោះអាចប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន។[126] មានន័យថា ក្រោយពីពេលដែលព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ហើយជនរងគ្រោះមានការមិនសុខចិត្តទៅនឹងសេចក្តីសម្រេចនេះ សាមីខ្លួនជនរងគ្រោះផ្ទាល់ អាចដាក់ពាក្យបណ្តឹងទៅកាន់

[124] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី២, មាត្រា ៤១។

[125] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី៣, មាត្រា ៤១។

[126] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី២, មាត្រា ៦១។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន[127] ដោយហេតុថាអគ្គព្រះរាជអាជ្ញា គឺជានាយឋានានុក្រមរបស់ព្រះរាជអាជ្ញា។[128] ម្យ៉ាងទៀតអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវបានកំណត់នូវតួនាទីក្នុងការឃ្លាំមើលការអនុវត្តច្បាប់ក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន[129] ហើយដោយសារតែតួនាទីនេះហើយ ទើបច្បាប់សម្រេចទទួលយកអគ្គព្រះរាជអាជ្ញាជាអ្នកទទួលបណ្ដឹងពីជនរងគ្រោះ និងជាអ្នកសម្រេចសេចក្ដីលើបណ្ដឹងនោះ។ ហើយការធ្វើបណ្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទៀតសោត ត្រូវធ្វើឡើងក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការ ដែលការតវ៉ានេះត្រូវធ្វើឡើងតាមរយៈបណ្ដឹងសាមញ្ញ នៅអង្គការអយ្យការដែលជាប់ពាក់ព័ន្ធ។[130] ក្រោយពីអង្គការអយ្យការពាក់ព័ន្ធបានទទួលបណ្ដឹងសាមញ្ញនោះហើយនឹងបញ្ជូនសំណុំរឿងនោះភ្លាមទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្នុងគោលបំណងដើម្បីសម្រេច និងចេញអធិបញ្ញា។ ការសម្រេចរបស់អគ្គព្រះរាជអាជ្ញាលើបណ្ដឹងតវ៉ានោះមាន ២ (ពីរ) ករណីដូចជា៖ ការបដិសេធនឹងសេចក្ដីសម្រេច និងការយល់ស្របតាមសេចក្ដីសម្រេច។[131]

- **ការបដិសេធនឹងសេចក្ដីសម្រេច៖** ប្រសិនបើបណ្ដឹងនេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នឹងចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូង ឱ្យធ្វើការចោទប្រកាន់តាមការសន្និដ្ឋានរបស់ខ្លួន។ ការធ្វើអធិបញ្ញាចាំបាច់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់ដាច់ខាត គាត់គ្មានសិទ្ធិអំណាចសម្រេចដោយខ្លួនឯងដូចពីមុននោះទេ។

- **ការយល់ស្របតាមសេចក្ដីសម្រេច៖** ប្រសិនបើបណ្ដឹងនេះ គឺមិនមានមូលហេតុត្រឹមត្រូវទេ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចតម្កល់សេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការដដែល ហើយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវជូនដំណឹងអំពីការតម្កល់សេចក្ដីសម្រេចនេះ ទៅឱ្យអ្នកប្ដឹងតវ៉ានោះបានដឹងពីការសម្រេចនេះ ហើយអ្នកប្ដឹងមិនអនុញ្ញាតឱ្យធ្វើបណ្ដឹងតវ៉ាទៀតទេ។ ការជូនដំណឹងនេះ ដើម្បីជាឱកាសក្នុងការប្រើនីតិវិធីផ្សេងៗទៀត ដូចជាការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ ។

[127] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី៤, មាត្រា ៤១។
[128] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី២, មាត្រា ២៩។
[129] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី១, មាត្រា ៣៤។
[130] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី៥, មាត្រា ៤១។
[131] អៀង សំណាង,នីតិវិធីព្រហ្មទណ្ឌ,(ភ្នំពេញ,២០១៩),ទំព័រ ៨០។

### ៣.៣. អំណាចអធិបញ្ជាដោយឋានានុក្រមនៃអង្គការអយ្យការ

អំណាចអធិបញ្ជា គឺជាបញ្ជាតាមឋានានុក្រមពីថ្នាក់លើមកឱ្យថ្នាក់ក្រោមដើម្បីឱ្យធ្វើអ្វីមួយ។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ អំណាចអធិបញ្ជាសំដៅដល់ការបញ្ជាតាមឋានានុក្រម ឱ្យចៅក្រមអយ្យការ ធ្វើការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ ដែលស្ថានភាពមួយចំនួនអាចប៉ះពាល់ដល់សេរីភាពរបស់ជនដែលទទួលរងនូវការចោទប្រកាន់ និងជះឥទ្ធិពលដល់ការកសាងនីតិរដ្ឋ។ ដោយសមាសភាពនៃអង្គការអយ្យការ ក្នុងការធ្វើអធិបញ្ជាមានឋានានុក្រមដូចជា៖ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង។

#### ៣.៣.១.រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាមុខនាទីមួយដែលតំណាង ឬជាសេនាធិការដល់រាជរដ្ឋាភិបាលក្នុងការពង្រឹងវិស័យច្បាប់របស់សង្គមជាតិទាំងមូល។ ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវរាយការណ៍ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[132] ដូចនេះ ច្បាប់បានផ្តល់អំណាចដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចធ្វើសកម្មភាពក្រោមទម្រង់ជាការប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូងអំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ជាតាមការណែនាំជាលាយលក្ខណ៍អក្សរ ដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលគាត់យល់ឃើញថាជាការគួរ ។[133]

#### ៣.៣.២. អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានតួនាទីឃ្លាំមើលការអនុវត្តច្បាប់ នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍។[134] អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានអំណាចលើចៅក្រមអយ្យការទាំងអស់ ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ អគ្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ជាឱ្យចោទប្រកាន់ ឬក៏ចាត់ឱ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ឃើញថាជាការគួរ។[135] ដូចនេះមានន័យថា អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើអធិបញ្ជាឱ្យព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ធ្វើការចោទប្រកាន់នៅពេលដែលមានការតម្កល់រឿងទុកឥតចាត់ការ។

[132] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី៣, មាត្រា ៣៤។

[133] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី១, មាត្រា ២៩។

[134] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៣៤។

[135] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី២,មាត្រា២៩។

### ៣.៣.៣. ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា មានអំណាចទៅលើចៅក្រមអយ្យការដែលនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។[136] ព្រះរាជអាជ្ញា អាចធ្វើអធិបញ្ញាឱ្យចៅក្រមអយ្យការធ្វើការចោទប្រកាន់ ឬចាត់ឱ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានតាមដែលខ្លួនយល់ឃើញថាជាការគួរ។[137] ព្រះរាជអាជ្ញានៅទីនេះ គឺសំដៅដល់ព្រះរាជអាជ្ញាអមសាលាដំបូង ដោយហេតុថាព្រះរាជអាជ្ញាអមតុលាការកំពូល ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មិនមានអំណាចលើចៅក្រមអយ្យការណាមួយក្នុងការប្រើអំណាចអធិបញ្ញាបាននោះទេ។ ដូចនេះមានន័យថា ព្រះរាជអាជ្ញាអមសាលាដំបូង អាចធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញារង ដែលស្ថិតនៅសមត្ថកិច្ចដែនដី ឬនៅអមសាលាដំបូងរបស់ខ្លួន ធ្វើការចោទប្រកាន់នៅពេលដែលមានការតម្កល់រឿងទុកឥតចាត់ការបានធ្វើឡើង។

### ៣.៣.៤. ព្រះរាជអាជ្ញារង

ព្រះរាជអាជ្ញារង គឺជាចៅក្រមអយ្យការនៅអមសាលាដំបូងរាជធានី-ខេត្ត ដែលមានឋានានុក្រមក្រោយគេ។ ព្រះរាជអាជ្ញារងស្ថិតនៅក្រោមអំណាចព្រះរាជអាជ្ញា ប៉ុន្តែអាចប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមាន ក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស។[138] ដូចនេះ នៅពេលដែលមានការធ្វើអធិបញ្ញាចំពោះរឿងដែលខ្លួនបានតម្កល់រឿងទុកឥតចាត់ការព្រះរាជអាជ្ញារងត្រូវតែគោរពតាមអធិបញ្ញានោះ។

គួរកត់សម្គាល់ផងដែរថា ការធ្វើអធិបញ្ញា ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ហើយអំណាចអធិបញ្ញា គឺជាការបញ្ជាឱ្យមានការចោទប្រកាន់ មិនមែនជាការបញ្ជាឱ្យមានការតម្កល់រឿងទុកឥតចាត់ការនូវរឿងក្តីព្រហ្មទណ្ឌណាមួយឡើយ។[139] ចៅក្រមអយ្យការគ្រប់រូប ត្រូវគោរពអធិបញ្ញាថ្នាក់លើរបស់ខ្លួនតាមឋានានុក្រម ប៉ុន្តែនៅពេលសវនាការចៅក្រមអយ្យការធ្វើការកត់សម្គាល់ផ្ទាល់មាត់ដោយសេរីតាមការដែលខ្លួនយល់ឃើញថា ស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន ហើយក៏គ្មានការចោទប្រកាន់ខាងវិន័យត្រូវបានធ្វើឡើងចំពោះចៅក្រមអយ្យការ ដោយសារតែវាចារបស់ខ្លួនដែលបានបញ្ចេញនៅពេលសវនាការនោះឡើយ។[140]

ដូច្នេះប្រសិនបើមានការតម្កល់រឿងទុកឥតចាត់ការត្រូវបានធ្វើឡើង ជនរងគ្រោះអាចជ្រើសយកជម្រើសនេះ ដោយធ្វើការប្តឹងទៅនាយឋានានុក្រមនៃអង្គការអយ្យការខាងលើ ដើម្បីឱ្យធ្វើអធិបញ្ញាដែលនាំឱ្យមានការ

[136] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី៣,មាត្រា២៩។

[137] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី៤,មាត្រា២៩។

[138] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៣៨។

[139] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា២៩។

[140] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៣០។

ចោទប្រកាន់ឡើងវិញ ប្រសិនបើពួកគាត់យល់ថារឿងនោះគួរចោទប្រកាន់។

### ៣.៤. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ក្រៅពីជម្រើសនៃការដាក់ពាក្យប្តឹង ឬពាក្យបរិហារទៅមន្ត្រីនគរបាលយុត្តិធម៌ ឬទៅព្រះរាជអាជ្ញាផ្ទាល់ ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្តឹងជូនចៅក្រមស៊ើបសួរមានសមត្ថកិច្ច ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។[141]ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរអំពីបណ្តឹងអាជ្ញា ដែលគេហៅថាការដាក់បណ្តឹងអាជ្ញាឱ្យមានចលនា ដោយជនរងគ្រោះ[142] ដែលអាចនាំឱ្យមានការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ និងប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ។ បន្ទាប់មកចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់នូវការដាក់ពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា បន្ទាប់មកក្រោយពីបានឃើញពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ អាចធ្វើប្រឆាំងនឹងអញ្ញាតជន ទោះបីជាបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចោទទៅលើឈ្មោះបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ។[143] យ៉ាងណាមិញ ព្រះរាជអាជ្ញា ក៏អាចសុំដល់ចៅក្រមស៊ើបសួរមិនឱ្យស៊ើបសួរបានក្នុងករណីដែលបណ្តឹងអាជ្ញា ត្រូវបានផុតរលត់ដោយមូលហេតុណាមួយដូចដែលមានចែងក្នុង មាត្រា ៧ និង មាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ឬ ប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។[144] បន្ថែមពីនេះ បើទោះបីជាមានការសុំមិនឱ្យស៊ើបសួរពីព្រះរាជអាជ្ញាក៏ដោយ ក៏ចៅក្រមស៊ើបសួរនៅតែស្ថិតក្នុងភាពឯករាជ្យ ពោលគឺចៅក្រមស៊ើបសួរអាចសម្រេចបើកការស៊ើបសួរ និងសម្រេចមិនបើកការស៊ើបសួរ។ ក្នុងករណី ដែលចៅក្រមស៊ើបសួរសម្រេចមិនបើកការស៊ើបសួរ តាមការស្នើសុំរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយជូនដំណឹងនេះជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឱ្យគាត់ធ្វើបណ្តឹងឧទ្ធរណ៍ចំពោះដីកានេះ ប្រសិនបើគាត់មិនសុខចិត្ត។[145] ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរសម្រេចបើកការស៊ើបសួរវិញ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា ដើម្បីឱ្យព្រះរាជអាជ្ញាប្រើប្រាស់សិទ្ធិរបស់គាត់ ក្នុងការប្តឹងឧទ្ធរណ៍ចំពោះ

[141] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ១៣៨។

[142] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ៥។

[143] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី២,មាត្រា ១៣៩។

[144] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី៣,មាត្រា ១៣៩។

[145] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី៤,មាត្រា ១៣៩។

ដីកានេះក្នុងករណីចាំបាច់។[146] ចំពោះការសម្រេចឱ្យបើកការស៊ើបសួរចំពោះពាក្យបណ្ដឹងដែលមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរ ក៏អាចបង្គាប់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីបង់ប្រាក់តម្កល់ទុកសម្រាប់ដំណើរការនីតិវិធីនៃការបើកការស៊ើបសួរ។

[146] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,កថាខណ្ឌទី៥,មាត្រា ១៣៩។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ និងធ្វើការបកស្រាយខ្លឹមសារប្រធានបទសារណាខាងលើរួចមក យើងអាចសន្និដ្ឋានបានថា ស្ថាប័នអយ្យការអមសាលាដំបូង ពិតជាបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការការពារផលប្រយោជន៍សាធារណៈ ក៏ដូចជាសណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅក្នុងសង្គម។ ក្នុងនោះផងដែរ ព្រះរាជអាជ្ញា ដែលជាតំណាងឱ្យអយ្យការអមសាលាដំបូង មានសិទ្ធិ អំណាច និងតួនាទីយ៉ាងសំខាន់ ក្នុងក្របខណ្ឌនៃវិស័យយុត្តិធម៌នៅកម្ពុជា តាមរយៈការធ្វើចំណាត់ការលើបណ្តឹងព្រហ្មទណ្ឌ។ ហើយសិទ្ធិ អំណាច និងតួនាទីនេះ ត្រូវបានផ្តល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ដែលព្រះរាជអាជ្ញាមានជម្រើសក្នុងការសម្រេចធ្វើការចោទប្រកាន់ ឬ សម្រេចមិនធ្វើការចោទប្រកាន់ ដែលជាឆន្ទានុសិទ្ធិរបស់ខ្លួនដោយផ្អែកតាមបទប្បញ្ញត្តិ ឬច្បាប់ជាធរមាន។

ចំពោះការសម្រេចចោទប្រកាន់ ឬមិនចោទប្រកាន់របស់ព្រះរាជអាជ្ញា មានអានុភាពធំធេងខ្លាំងណាស់ដល់ផលប្រយោជន៍ភាគីនៃរឿងក្តី ដែលទាមទារឱ្យមានលក្ខណៈច្បាស់លាស់ និង ភាពឆាប់រហ័ស ដើម្បីធានាបាននូវភាពយុត្តិធម៌ជូនដល់ជនរងគ្រោះ និងសង្គមជាតិទាំងមូល។ ដោយហេតុថាការចោទប្រកាន់ មានអានុភាពធ្វើឱ្យជនណាម្នាក់ ឬច្រើននាក់ឱ្យស្ថិតនៅក្រោមការពិនិត្យអំពីបទល្មើស ដែលក្នុងស្ថានភាពនោះនាំឱ្យបុគ្គលអ្នកប្រព្រឹត្ត ក្លាយជាជនល្មើស ហើយអាចឈានទៅដល់ការដកហូតសិទ្ធិសេរីភាពជាប្រជាពលរដ្ឋ ដោយមានទោសត្រូវបង់ប្រាក់ពិន័យ និងជាប់ពន្ធនាគារទៀតផង។ ហេតុនេះ គ្រប់ដំណាក់កាលនៃនីតិវិធីនៃការចោទប្រកាន់ត្រូវតែមានភាពច្បាស់លាស់ ដើម្បីស្វែងរកយុត្តិធម៌យ៉ាងពិតប្រាកដជូនដល់ជនរងគ្រោះ និងជនជាប់ចោទ ព្រមទាំងការពារនូវផលប្រយោជន៍សាធារណៈ និងបញ្ឈប់រាល់ភាពអសកម្មទាំងឡាយក្នុងសង្គម។ ផ្ទុយទៅវិញ ប្រសិនបើការចោទប្រកាន់នោះធ្វើឡើងដោយមិនមានភាពច្បាស់លាស់ វាអាចនឹងផ្តល់ផលប៉ះពាល់ដល់ភាគីនៃរឿងក្តី ជាពិសេសជនត្រូវចោទអាចនឹងត្រូវទទួលផលប៉ះពាល់ ដូចជាខាតបង់ទាំងថវិកា ពេលវេលាបាត់បង់កិត្តិយស កេរ្តិ៍ឈ្មោះ ប្រសិនបើមានការឃុំខ្លួន ឬអាចទទួលរងនូវភាពអយុត្តិធម៌ ដែលបណ្តាលមកពីការមិនបានស៊ើបអង្កេតឱ្យបានច្បាស់លាស់ពីសំណាក់តំណាងអយ្យការ។ ចំណែកឯជនរងគ្រោះវិញ ក៏អាចនឹងទទួលរងនូវផលប៉ះពាល់ផងដែរ ក្នុងករណីដែលការចោទប្រកាន់នោះ មិនបានស្រាវជ្រាវច្បាស់លាស់គ្រប់គ្រាន់ ហើយសម្រេចសេចក្តីដោយមិនបានត្រឹមត្រូវ ដែលនាំឱ្យជនរងគ្រោះទទួលរងនូវភាពអយុត្តិធម៌ និងមិនអាចទទួលបាននូវការប៉ះប៉ូវសំណងជំងឺចិត្តជាដើម។ ដូចនេះដើម្បីធានាឱ្យបាននូវភាពច្បាស់លាស់ ការការពារសិទ្ធិ និងបញ្ចៀសនូវភាពអយុត្តិធម៌ដល់ភាគីនៃរឿងក្តី ការចោទប្រកាន់ដែលធ្វើឡើង តាមរយៈនីតិវិធីបើកការស៊ើបសួរ ជាជម្រើសដ៏ល្អបំផុត ព្រោះនីតិវិធីនេះ មានការចូលរួមពីសំណាក់ចៅក្រមស៊ើបសួរ ដែលជា

តួអង្គមួយឯករាជ្យ ហើយក៏មានតួនាទីក្នុងការស្វែងរកការពិតនៃបទល្មើស ដោយមិនលំអៀង ពោលគឺស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុក។ ម្យ៉ាងវិញទៀត បើទោះបីជានីតិវិធីនីមួយៗនៃការចោទប្រកាន់ សុទ្ធតែតម្រូវឱ្យមានភាពច្បាស់ក៏ពិតមែន ប៉ុន្តែមិនអាចធ្វើឡើងដោយមានការយឺតយ៉ាវ និងអូសបន្លាយពេលវេលាយូរបានឡើយ ដែលបណ្តាលឱ្យខាតបង់ផលប្រយោជន៍របស់ភាគីនៃរឿងក្តីបាន ព្រោះថា ភាពយុត្តិធម៌ដែលមានភាពយឺតយ៉ាវគឺស្មើនឹងភាពអយុត្តិធម៌។ ដូចនេះ នៅពេលដែលព្រះរាជអាជ្ញាមានភាពច្បាស់លាស់ពីពិរុទ្ធភាពរបស់ជនសង្ស័យហើយ គឺមិនចាំបាច់បើការស៊ើបសួរទៀតឡើយដែលនាំឱ្យខាត់បង់ពេលវេលា ដោយព្រះរាជអាជ្ញា អាចសម្រេចបញ្ជូនជនសង្ស័យនោះទៅជំនុំជម្រះតែម្តង តាមរយៈនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ដែលនីតិវិធីនេះមានភាពឆាប់រហ័ស និងមានលក្ខណៈខ្លីជាងនីតិវិធីនៃការបើកការស៊ើបសួរ។ ហើយការប្រើប្រាស់នីតិវិធីទាំងពីរនេះ មិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់ជនរងគ្រោះ ដើម្បីទទួលបានភាពយុត្តិធម៌បានឆាប់រហ័សនោះទេ ព្រមទាំងទទួលបាននូវសំណង់ខូចខាតទាំងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវសម្ភារៈបានទាន់ពេលវេលា ថែមទាំងបានផ្តល់ផលប្រយោជន៍ដល់តុលាការ ក្នុងការជួយកាត់បន្ថយនូវការកកស្ទះនូវសំណុំរឿង ក៏ដូចជាការកាត់បន្ថយបន្ទុករបស់ចៅក្រមស៊ើបសួរនៅតាមសាលាដំបូងរាជធានី-ខេត្ត។

ដោយឡែកក្រៅពីការចោទប្រកាន់ចំពោះបទល្មើស ព្រះរាជអាជ្ញាក៏មានសិទ្ធិអំណាចក្នុងការសម្រេចមិនចោទប្រកាន់ ឬការតម្កល់រឿងទុកឥតចាត់ការបានដែរ បើទោះបីជាអំពើដែលបានប្រព្រឹត្តនោះជាបទល្មើសក៏ដោយ ព្រោះថាការចោទប្រកាន់ចំពោះអំពើខ្លះ អាចធ្វើឱ្យប៉ះពាល់ ឬខាតបង់ទាំងថវិកាជាតិ និងពេលវេលាឥតប្រយោជន៍។ ដូចនេះព្រះរាជអាជ្ញាអាចធ្វើការថ្លឹងថ្លែង និងពិចារណាលើការសម្រេចមិនចោទប្រកាន់ ឬការតម្កល់រឿងទុកឥតការបាន ប្រសិនបើបានបំពេញនូវលក្ខខណ្ឌ និងមូលហេតុមួយចំនួនដែលបណ្តាលឱ្យមានការតម្កល់រឿងទុកឥតការដូចជា៖ នត្ថិភាពនៃបទល្មើស ការរលត់បណ្តឹងអាជ្ញា ការចោទប្រកាន់មិនផ្តល់ប្រយោជន៍ និងមូលហេតុគតិយុត្តផ្សេងទៀត។ ហើយការសម្រេចតម្កល់រឿងទុកឥតចាត់ការនេះទៀតសោត គឺបានផ្តល់នូវផលប្រយោជន៍ជាច្រើនដូចជា៖ រដ្ឋអាចកាត់បន្ថយការចំណាយទាំងពេលវេលា និងថវិកា ហើយភាគីដែលជាជនល្មើសអាចមានលទ្ធភាពគ្រប់គ្រាន់ដើម្បីកែប្រែខ្លួន និងរួមរស់ជាមួយសង្គមវិញ ជាពិសេសអនីតិជន និងជនដែលកំពុងជាប់កាតព្វកិច្ចក្នុងការចិញ្ចឹមបីបាច់គ្រួសារ។ ចំពោះតុលាការវិញ គឺជួយកាត់បន្ថយសំណុំរឿងដែលកកស្ទះ ផ្តល់ប្រសិទ្ធិភាពក្នុងការស៊ើបសួរ និងជំនុំជម្រះ ព្រមទាំងមានពេលវេលាគ្រប់គ្រាន់សម្រាប់បំពេញកិច្ចការរបស់ខ្លួន។ ប៉ុន្តែទន្ទឹមនឹងការផ្តល់ប្រយោជន៍ជាច្រើន ក៏បង្កប់នូវគុណវិបត្តិផងដែរ ក្នុងករណីដែលព្រះរាជអាជ្ញាមានការធ្វេសប្រហែស មិនបានស្រាវជ្រាវឱ្យបានល្អិតល្អន់ ហើយសម្រេចសេចក្តីមិនបានត្រឹមត្រូវ ជាពិសេសបញ្ហាអំពើពុករលួយ នោះជនដែលបានប្រព្រឹត្តអំពើល្មើសច្បាប់នឹងត្រូវបានរួចខ្លួន

ដែលជាហេតុនាំឱ្យជនរងគ្រោះទទួលរងនូវភាពអយុត្តិធម៌។

សរុបសេចក្តីមក ក្នុងនាមជាម្ចាស់បណ្តឹងអាជ្ញា ជាអ្នកការពារផលប្រយោជន៍សាធារណៈ ក៏ដូចជាធានាបាននូវភាពយុត្តិធម៌ជូនដល់ជនរងគ្រោះ និងសង្គមជាតិទាំងមូល ព្រះរាជអាជ្ញាត្រូវតែបំពេញកិច្ចការរបស់ខ្លួនដោយយកចិត្តទុកដាក់ មានការប្រុងប្រយ័ត្នខ្ពស់ នៅពេលដែលធ្វើការសម្រេចចោទប្រកាន់ ឬការតម្កល់រឿងទុកឥតចាត់ការ ដោយអនុលោមយ៉ាងខ្ជាប់ខ្ជួនស្របតាមស្មារតី និងនីតិវិធីនៃច្បាប់។ បន្ថែមពីនេះ ព្រះរាជអាជ្ញាត្រូវតែអនុវត្តវិជ្ជាជីវៈរបស់ខ្លួនឱ្យបានត្រឹមត្រូវ សុក្រឹត្យ យុត្តិធម៌ ដោយផ្អែកលើគោលការណ៍សុគតិធម៌ទាំងប្រាំគឺ រិយសម្បយុត្ត សុចរិតយុត្តិធម៌ បញ្ញត្តិគារវោ សមទណ្ឌោ និងបញ្ញាវុធវិនិច្ឆ័យ ព្រមទាំងជៀសវាងឱ្យបាននូវអគតិធម៌ទាំងបួនមាន៖ ឆន្ទាគតិ ទោសាគតិ ភយាគតិ និងមោហាគតិ។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវលើប្រធានបទយ៉ាងយកចិត្តទុកដាក់ ក៏ដូចជាការធ្វើសេចក្ដីសន្និដ្ឋានរួចមក យើងខ្ញុំយល់ឃើញថា ស្ថាប័នអយ្យការ គឺពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ឱ្យមានភាពល្អប្រសើរ ត្រឹមត្រូវ តម្លាភាព និងប្រកបដោយភាពយុត្តិធម៌។ ក៏ប៉ុន្តែ ក្នុងនោះផងដែរ ក៏ឃើញមាននូវចំណុចវិជ្ជមាន និងអវិជ្ជមានមួយចំនួនដែលពាក់ព័ន្ធទៅនឹងការអនុវត្តជាក់ស្ដែងចំពោះចំណាត់ការលើរឿងក្ដីនានា ដែលជាហេតុនាំឱ្យមានភាពចន្លោះប្រហោង និងយឺតយ៉ាវក្នុងការបំពេញការងារ និងជាពិសេសការស្វែងរកភាពយុត្តិធម៌ដល់ភាគីនៃរឿងក្ដី។ ដូច្នេះដើម្បីជាការចូលរួមចំណែកក្នុងការលើកស្ទួយវិស័យយុត្តិធម៌នៅកម្ពុជាឱ្យកាន់តែល្អប្រសើរឡើង មានគុណភាព យើងខ្ញុំជានិស្សិតសរសេរសារណា សូមចូលរួមជាគំនិតយោបល់ខ្លះៗ ដើម្បីបានផ្ដល់ជាអនុសាសន៍បន្ថែមទៅលើចំណុចខ្វះខាតមួយចំនួនដូចជា៖

- ស្ថាប័នអយ្យការគួរតែជ្រើសរើសចំនួនព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងបន្ថែម ដើម្បីជៀសវាងការកកស្ទះសំណុំរឿង ដោយសារសំណុំរឿងមានច្រើន តែចំនួនព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងដែលបម្រើការងារនៅតាមស្ថាប័នតុលាការមានចំនួនតិចមិនគ្រប់គ្រាន់។

- ក្រសួងយុត្តិធម៌គួរតែពន្លឿនពីនីតិវិធីធ្វើលក្ខន្តិកៈក្រឡាបញ្ជី ដោយកំណត់ពីមុខងារតួនាទីរបស់ក្រឡាបញ្ជីបានច្បាស់លាស់ដើម្បីជួយសម្រួលដល់កិច្ចការចៅក្រម និងព្រះរាជអាជ្ញាឱ្យត្រឹមត្រូវតាមច្បាប់ និងជាពិសេសដោយសារតែ ក្រឡាបញ្ជីនូវមានចំនួនខ្វះខាត ដូចនេះគួរតែមានការបណ្ដុះបណ្ដាល ឬជ្រើសរើសក្រឡាបញ្ជីបន្ថែម។

- ព្រះរាជអាជ្ញាគួរតែមានទំនួលខុសត្រូវលើការងាររបស់ខ្លួនឯង ដោយសារតែការអនុវត្តជាក់ស្ដែងគឺក្រឡាបញ្ជីជាអ្នករ៉ាប់រងការមើល និងចាត់ចែងសំណុំរឿង ហើយព្រះរាជអាជ្ញាពេលខ្លះគ្រាន់តែផ្ដល់យោបល់និងណែនាំបន្តិចបន្តួចតែប៉ុណ្ណោះ លើនិយ័តភាពនីតិវិធី។

- ចំពោះការចោទប្រកាន់របស់ព្រះរាជអាជ្ញា ទៅលើបទល្មើសតូចតាចណាមួយ ដែលកើតចេញពីហិង្សានៅក្នុងគ្រួសារ ដែលមានលក្ខណៈស្រាលបំផុត ព្រះរាជអាជ្ញាក៏គួរតែធ្វើការតម្កល់រឿងទុកឥតចាត់ការ តែការអនុវត្តជាក់ស្ដែង គឺព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ទាំងដែលបទល្មើសទាំងអស់នោះមានព្យសនកម្មតិចតួច និងស្រាលបំផុត។

- ចំពោះការចោទប្រកាន់ ត្រូវតែផ្អែកលើមូលដ្ឋាន និងភស្ដុតាងសមរម្យ ដែលអាចជឿជាក់បានថាភស្ដុតាងទទួលបាននោះ ស្របតាមនីតិវិធីច្បាប់ មិនមែនកើតចេញពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សជាអាទិ៍ ការធ្វើទារុណកម្ម ទណ្ឌកម្ម អំពើឃោរឃៅ អមនុស្សធម៌ ឬអំពើបន្ថោកបន្ទាបផ្សេងៗ។

- មន្ត្រីអនុវត្តច្បាប់ត្រូវតែបំពេញកាតព្វកិច្ចរបស់ខ្លួនប្រកបដោយអនាគតិទាំង ៤ ដើម្បីថែរក្សាការពារ និងលើកកំពស់ជំនឿទុកចិត្តពីសាធារណៈជន ពោលគឺធ្វើការសម្រេចសេចក្តីដោយមិនលំអៀង ដោយឈរលើគោលការណ៍ច្បាប់ មិនទទួលការគាប់សង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬប្រយោលពីបុគ្គលណាម្នាក់ឡើយ។

- ធ្វើការបណ្តុះបណ្តាលចំណេះដឹងនៅក្រមនីតិវិធីព្រហ្មទណ្ឌ ទៅដល់មន្ត្រីទាំងឡាយឱ្យមានចំណេះដឹងទូលំទូលាយក្នុងការអនុត្តច្បាប់ឱ្យមានប្រសិទ្ធភាព ជាពិសេសផ្តល់នូវពុទ្ធិដល់មន្ត្រីដែលមានតួនាទីយ៉ាងសំខាន់ក្នុងកិច្ចដំណើរការរឿងក្តីព្រហ្មទណ្ឌ ឱ្យបានយល់ដឹងពីតួនាទី ភារកិច្ចរបស់ខ្លួនក្នុងការអនុវត្តឱ្យបានត្រឹមត្រូវទៅតាមច្បាប់កំណត់ដូចដែលមានចែងក្នុងក្រមនេះ។

- លើកទឹកចិត្តដល់មន្ត្រីដែលមានតួនាទី និងភារកិច្ចក្នុងប្រព័ន្ធយុត្តិធម៌ តាមរយៈការដំឡើងប្រាក់បៀវត្ស ឱ្យបានសមរម្យ ផ្តល់សេវាថែទាំសុខភាព និងសេវាផ្សេងៗទៀត ដែលជាប្រយោជន៍សម្រាប់ពួកគាត់ ដើម្បីជៀសវាងកុំឱ្យមានសកម្មភាពអំពើពុករលួយកើតមានឡើងក្នុងប្រព័ន្ធតុលាការ ដោយហេតុថាការទទួលបានប្រាក់បៀវត្សតិចតួចក៏អាចជាកត្តាមួយនាំឱ្យប៉ះពាល់ដល់កម្រិតជីវភាពរបស់មន្ត្រីដែរ។ ដូចនេះ ដើម្បីធានាបាននូវភាពយុត្តិធម៌ដល់មនុស្សគ្រប់គ្នាក្នុងសង្គម និងកាត់បន្ថយអំពើពុករលួយការដំឡើងប្រាក់បៀវត្ស គឺពិតជាសំខាន់ខ្លាំងណាស់ក្នុងប្រព័ន្ធតុលាការ។

- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវតែពិនិត្យ តាមដានឱ្យបានល្អិតល្អន់ គ្រប់ជ្រុងជ្រោយអំពីសកម្មភាពរបស់អយ្យការគ្រប់ជាន់ថ្នាក់ និងត្រូវអនុវត្តនីតិវិធីពិន័យភ្លាមៗចំពោះតំណាងអយ្យការណាដែលប្រព្រឹត្តខុសនូវកំហុសធ្ងន់ធ្ងរ ដែលអាចប៉ះពាល់ដល់វិស័យយុត្តិធម៌។

# ឯកសារយោង

# ឯកសារយោង

## I. លិខិតបទដ្ឋានគតិយុត្តជាតិ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាស់ឱ្យប្រើថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

២. នីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

៣.ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧ ។

៤.ច្បាប់ស្តីពីការរៀបចំអង្គការតុលាការនៃព្រះរាជាណាចក្រកម្ពុជា

លេខ នស/រកម/០៧១៤/០១៥,១៦ កក្កដា ២០១៤។

៥.ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា

លេខ នស/រកម/០៧១៤/០១៦ ,១៦កក្កដា ២០១៤ ។

៦. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន នៃព្រះរាជាណាចក្រកម្ពុជា

លេខ នស/រកម/ ០៧១៦/០០៩, ១៤ កក្កដា ២០១៦។

៧. ច្បាប់ស្តីពីឯកពន្ធភាព លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦ ។

៨. ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ

លេខ នស/រកម/១០០៥/០៣១, ២៤ តុលា ២០០៥។

៩. ច្បាប់ស្តីពីគយ លេខ នស/រកម/០៧០៧/០១៧, ២០ កក្កដា ២០០៧។

១០. ច្បាប់ស្តីពីព្រៃឈើ លេខ នស/រកម/០៨០២/០១៦, ៣០ សីហា ២០០២។

១១. ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក លេខ នស/រកម/០១១៥/០១១, ០៦ មករា ២០១៥។

## II. លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

១. គោលការណ៍ស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី ស្តីពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស នាទីក្រុង ហាវ៉ាណា នៃប្រទេសគុយបា នៅថ្ងៃទី ២៧ ខែ សីហា ដល់ ថ្ងៃទី ០៧ ខែ កញ្ញា ១៩៩០។

២. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ, ២៣ មិនា ១៩៧៦។

## III. ឯកសារជាសៀវភៅ

១. លោកសាស្រ្តាចារ្យ **កៅ សីហា** សៀវភៅ នគរបាលយុត្តិធម៌ ឆ្នាំ ២០១២។

២. លោកស្រី **ឌី លីឡា** និង លោក **ខាន់ សុខា** សៀវភៅ នីតិវិធីព្រហ្មទណ្ឌ។

៣. លោកសាស្រ្តាចារ្យ **រុន ពណ្ណារិទ្ធ** និង លោកស្រីសាស្រ្តាចារ្យ **ចាំង ស៊ីណាត** សៀវភៅសិក្សាជំនួយស្មារតី នីតិព្រហ្មទណ្ឌ និង នីតិគ្រួសារ ឆ្នាំ ២០១៧។

៤.លោកសាស្ត្រាចារ្យ **វុន ពណ្ណារិទ្ធ** និង លោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** សៀវភៅសិក្សា នីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ ២០២២។

៥. លោកសាស្ត្រាចារ្យ **ហ៊ី សោភា** ឯកសារមេរៀន នីតិវិធីព្រហ្មទណ្ឌ។

៦. លោក **ហ៊ីង ធីឫទ្ធិ** អធិប្បាយច្បាប់ ក្រឡាបញ្ជី តុលាការ និង អយ្យការ ក្នុងរឿងក្តីព្រហ្មទណ្ឌ ឆ្នាំ ២០០៤។

៧. លោក **ឥនយឿន** សៀវភៅ មូលដ្ឋានច្បាប់ និង ស្ថាប័នច្បាប់ ឆ្នាំ ២០១៨។

៨. លោក **អៀង សំណាង** សៀវភៅ នីតិព្រហ្មទណ្ឌ ឆ្នាំ ២០១៩។

៩. លោក **អៀង សំណាង** សៀវភៅ សំណួរ ចម្លើយ នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០១៨។

១០. លោក **អៀង សំណាង** សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០១៩។។

១១. លោក **ឥនយឿន** សៀវភៅ សំណួរ ចម្លើយ ទាក់ទងនិងវិស័យច្បាប់ ឆ្នាំ ២០២១។

## IV.អំពីវចនានុក្រម និង សទ្ធានុក្រម

១. វចនានុក្រមខ្មែរ ដោយសម្តេចព្រះសង្ឃរាជ ជួន ណាត ដែលបោះពុម្ពផ្សាយដោយសាសនបណ្ឌិត្យភ្នំពេញ ឆ្នាំ ១៩៦៧។

២. សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ **"វចនានុក្រមច្បាប់ តាមបទដ្ឋានគតិយុត្តខ្មែរ"** ឆ្នាំ២០១៨។

៣. ទីស្តីការគណៈរដ្ឋមន្ត្រី, សទ្ទានុក្រមច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ ឆ្នាំ ២០១១។

## V. ឯកសារតាម Internet

១. https://ciclg.com/cn/article/248 អត្ថបទស្រាវជ្រាវអំពី គោលការណ៍នៃការចោទប្រកាន់។

២. https://www.facebook.com/1482208281916621/posts/1711073712363409/ អត្ថបទស្តីពី ការតម្កល់រឿងទុកឥតចាត់ការ។

# ឧបសម្ព័ន្ធ

## តារាងឧបសម្ព័ន្ធ

| | |
|---|---|
| **ឧបសម្ព័ន្ធ១** | ពាក្យបណ្ដឹង |
| **ឧបសម្ព័ន្ធ២** | ដីកាកោះ |
| **ឧបសម្ព័ន្ធ៣** | ដីកាបង្គាប់ឱ្យចូលខ្លួន |
| **ឧបសម្ព័ន្ធ៤** | ដីកាបង្គាប់ឱ្យចាប់ខ្លួន |
| **ឧបសម្ព័ន្ធ៥** | ការឆែកឆេរលំនៅដ្ឋាន |
| **ឧបសម្ព័ន្ធ៦** | កំណត់ហេតុទទួលយកវត្ថុចាប់យក |
| **ឧបសម្ព័ន្ធ៧** | កំណត់ហេតុសួរចម្លើយ |
| **ឧបសម្ព័ន្ធ៨** | ដីកាបញ្ជាឱ្យចូលខ្លួន |
| **ឧបសម្ព័ន្ធ៩** | កំណត់ហេតុបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម |
| **ឧបសម្ព័ន្ធ១០** | ដីកាសន្និដ្ឋានស្ដាពរ |
| **ឧបសម្ព័ន្ធ១១** | ដីកាតម្កល់រឿងទុកឥតចាត់ការ |
| **ឧបសម្ព័ន្ធ១២** | លិខិតជូនដំណឹង |
| **ឧបសម្ព័ន្ធ១៣** | សេចក្តីសុំប្តឹងតវ៉ា |
| **ឧបសម្ព័ន្ធ១៤** | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ |
| **ឧបសម្ព័ន្ធ១៥** | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម |
| **ឧបសម្ព័ន្ធ១៦** | ដីកាសន្និដ្ឋានសុំឱ្យឃុំខ្លួនបណ្ដោះអាសន្ន |
| **ឧបសម្ព័ន្ធ១៧** | ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ |
| **ឧបសម្ព័ន្ធ១៨** | ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ |
| **ឧបសម្ព័ន្ធ១៩** | ដីកាផ្ទេរសមត្ថកិច្ច |
| **ឧបសម្ព័ន្ធ២០** | ដីកាបង្គាប់ឱ្យឃុំខ្លួន |
| **ឧបសម្ព័ន្ធ២១** | ដីកាបង្គាប់ឱ្យដោះលែង |
| **ឧបសម្ព័ន្ធ២២** | ដីកាបង្គាប់ឱ្យឈប់ចាប់ខ្លួន |
| **ឧបសម្ព័ន្ធ២៣** | ដីកាសម្រេច |

**ឧបសម្ព័ន្ធ១**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌
ទទួលពាក្យបណ្តឹង
ចូល លេខ 164 ម៉ោង 10⁰⁰
មកដល់ ថ្ងៃទី 27/5/2019

អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
ចូល លេខ 3150
ថ្ងៃទី 24 ខែ 05 ឆ្នាំ 2019
ម៉ោង 15:45 នាទី

**ពាក្យបណ្តឹង**

ខ្ញុំបាទឈ្មោះ ឆ្នាំកំណើត១៩៧២ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ផ្លូវលេខ ភូមិ៥ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**សូមគោរពជូន**

**លោកព្រះរាជអាជ្ញា អមសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ៖** ប្តឹងឈ្មោះ គេខប្រុស មុនរបរ

ពីបទល្មើសព្រហ្មទណ្ឌដូចជា៖

១/- បង្កើតសំណុំរឿងអនុវត្តលេខ ១៤៣ ចុះថ្ងៃទី២០.០៥.២០០៥ ក្លែងក្លាយ រៀបចំគម្រោងការទុច្ចរិត ដើម្បីធ្វើស៊ី ឬ ចង់បានផ្ទះ(ផ្ទះលេខ៦២E₀ E₁ E₂ ផ្លូវលេខ៥៩៨ ភូមិ៥ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ) របស់ខ្ញុំបាទ ។

២/- អន្តរាគមន៍ដោយខុសច្បាប់ ទៅលើមន្រ្តីសាធារណៈ តាមរយៈការចេញលិខិតរបស់អាជ្ញាសាលា (ស៊ុន លៀងហេង) លេខ ០៧ ចុះថ្ងៃទី២៦.០៤.២០១៩ ។

៣/- បទរំលោភបំពានច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា ដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា , ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

សូមទាមទារសំណង ជំងឺចិត្តព្រមទាំងសេវាកម្មផ្នែកច្បាប់ចំនួន USD១០០០០០០ (មួយលានដុល្លារអាមេរិក) ។

__យោង__ ៖ - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតរបស់អាជ្ញាសាលា (ស៊ុន លៀងហេង) លេខ០៧ ចុះថ្ងៃទី២៦.០៤.២០១៩ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ សូមជម្រាបជូន **លោកព្រះរាជអាជ្ញា** មេត្តាជ្រាបថា៖ នៅថ្ងៃទី២៦.០៤.២០១៩ អាជ្ញាសាលាឈ្មោះ ស៊ុន លៀងហេង បានចេញលិខិតរបស់ខ្លួន

០៧ ចុះថ្ងៃទី២៦.០៤.២០១៩ ជម្រាបមកលោកអភិបាល នៃគណៈអភិបាលខណ្ឌទួលគោក ដើម្បីបំពេញការងារ តាមគម្រោងការ ដ៏ទុច្ចរិតរបស់គាត់ ដែលមានចេតនា ចង់ធ្វើស៊ី ឬ បន្លំ ឬ ចង់បាន ដោយរំលោភបំពានច្បាប់ មករឹបអូសផ្ទះ(ផ្ទះលេខ៦២$E_0$ $E_1$ $E_2$ផ្លូវលេខ៥៩៨ ភូមិ៥ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ) របស់ខ្ញុំបាទ ដូចមានរៀបរាប់ក្នុងលិខិតរបស់លោក ។ ចេតនាដ៏ទុច្ចរិតនេះ គឺជាបទល្មើសព្រហ្មទណ្ឌ ដូចមានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទយ៉ាងធ្ងន់ធ្ងរបំផុត ហើយធ្វើឱ្យជះឥទ្ធិពលដ៏អាក្រក់ដល់សាលាដំបូងរាជធានីភ្នំពេញថែមទៀតផង ។ ហេតុនេះ សូម **លោកព្រះរាជអាជ្ញា** មេត្តាសម្រេច ចោទប្រកាន់ លើឈ្មោះ

បញ្ជូនទៅតុលាការផ្តន្ទាទោសតាមផ្លូវច្បាប់ និងសងសំណងជំងឺចិត្ត ព្រមទាំងសេវាកម្មផ្លូវច្បាប់ ជូនខ្ញុំបាទ ចំនួន USD១០០០០០០(មួយលានដុល្លារអាមេរិក) ហើយចំពោះសំណងដែលខ្ញុំបាទទទួលបាននោះ ខ្ញុំបាទនឹងប្រគល់ជូនកាកបាទក្រហមកម្ពុជា ចំនួន ៥០%(ហាសិបភាគរយ) និងមន្ទីរពេទ្យគន្ធបុប្ផា ចំនួន៥០%(ហាសិបភាគរយ) ដើម្បីរួបចំណែកជួយប្រទេសជាតិ ក្រោមការដឹកនាំ ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។**

សូម **លោកព្រះរាជអាជ្ញា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩

**ស្នាមមេដៃស្តាំ**

<u>ចម្លងជូន៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គងរាជអាវុធហត្ថលើផ្ទៃប្រទេស
- ក្រសួងយុត្តិធម៌
- ក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- អង្គភាពប្រឆាំងអំពើពុករលួយ
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

## ឧបសម្ព័ន្ធ២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ..............
ចុះថ្ងៃទី ......... ខែ ......... ឆ្នាំ .........

**<u>ដីកាកោះ</u>**

**យើង ........................ តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ**

អញ្ជើញឈ្មោះ ..........................................................................................................

ទីលំនៅសព្វថ្ងៃ .......................... ផ្លូវ ...................... ភូមិ ............................... សង្កាត់ ..........................

ខណ្ឌ ............................................... រាជធានីភ្នំពេញ។

អោយចូលទៅកាន់ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

នៅថ្ងៃទី .................. ខែ .................. ឆ្នាំ ................. វេលាម៉ោង ..........................................

ដើម្បី ..........................................................................................................................

ពីដំណើររឿង ..................................................................................................................

..................................................................................................................................

សាមីខ្លួន ត្រូវអញ្ជើញតាមដីកាកោះនេះ អោយបានទាន់ពេលវេលា និងយក លិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

រាជធានីភ្នំពេញ , ថ្ងៃទី ......... ខែ .......... ឆ្នាំ

តំណាងអយ្យការ

**ឧបសម្ព័ន្ធ៣**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ៖ ៣៨៨ "ឈ" ព្រ.ទ

## ដីកាបង្គាប់ឲ្យចូលខ្លួន

(មាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

យើង **លាង សំណាត់** ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១១២៥ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣០៤១ អ.យ.ប ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ ។

បើកការស៊ើបសួរលើឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ កើតថ្ងៃទី ខែ ឆ្នាំ១៩៨០ ជាតិខ្មែរ ពីបទ៖ បរិហារកេរ្តិ៍ជាសាធារណៈ , ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៣០៥ មាត្រា ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ ។

បង្គាប់មកឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ កើតថ្ងៃទី ខែ ឆ្នាំ១៩៨០ ជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្នស្នាក់នៅផ្ទះជួល សង្កាត់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ (អាសយដ្ឋានចុងក្រោយ) ។

ឲ្យចូលខ្លួនមកកាន់សាលាដំបូងរាជធានីភ្នំពេញ **បន្ទប់"ឈ" ជាន់ទី៤ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក ។**

ដើម្បី៖ មកសាកសួរយកចម្លើយ

ពីដំណើររឿង៖ បរិហារកេរ្តិ៍ជាសាធារណៈ , ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍

សាមីខ្លួនត្រូវយកលិខិតផ្សេងៗដែលទាក់ទងនិងរឿងខាងលើនេះមកជាមួយផង ប្រសិនបើមាន ។

ក្នុងករណីមិនចូលខ្លួនតាមការកំណត់ខាងលើនេះទេ យើងនឹងចេញដីកាបង្គាប់ឲ្យនាំខ្លួន ។

ថ្ងៃអង្គារ ០២រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ , ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨

ចៅក្រមស៊ើបសួរ

លាង_សំណាត់

អាសយដ្ឋាន: អគារលេខ ២៥, ២៦ និង ២៧ ផ្លូវលេខ ២១៧ សង្កាត់វាលវង់ ខណ្ឌ ៧ មករា, ភ្នំពេញ
Adress: #25, 26 and 27, Street 217, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia.
ទូរសារ-ទូរស័ព្ទ: (៨៥៥)-២៣ ៨៨ ៥០ ៨០
Fax-Phone : (855) - 23 88 50 80

**ឧបសម្ព័ន្ធ៤**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខៈ ០៦ .អ.យ.ង

**ដីកាបង្គាប់អោយចាប់ខ្លួន**

**យើង ឯក ឆេងឃុត ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញមាត្រា៤៨៦, ៥២៣, ៥៣០, ៥៣៣ និងមាត្រា១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៨៦"ត" ចុះថ្ងៃទី ១៨-១០-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសាលដីកាលេខ១៩ក្រ៤អចុះថ្ងៃទី០៨ ខែ០២ ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍"រាជធានីភ្នំពេញ" ។

-បានឃើញសាលដីកាលេខ៦២ក្រ៤អ ចុះថ្ងៃទី២១ ខែ០៦ ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍"រាជធានីភ្នំពេញ" ។

-បានឃើញសាលដីកាលេខ៣០០ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ របស់តុលាការកំពូល ។

-បានឃើញពាក្យសុំអនុវត្តដោយបង្ខំលើរូបរាងកាយ របស់មេធាវី ទី គឹមស្រ៊ាន តំណាងអោយលោក ឡើន សុវណ្ណ ចុះថ្ងៃទី១៦ ខែ ធ្នូ ឆ្នាំ ២០១៣ ។

-បានឃើញសំណុំរឿងអនុវត្តលេខ ២៨៦ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៣ ។

**ក្រោយពីបានពិនិត្យសព្វគ្រប់ឃើញថា**

-ឈ្មោះ ជា តារា ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើត ភូមិ ស្រែរូង ឃុំ ភ្នំកុង ស្រុក អង្គរជ័យ ខេត្ត កំពត ទីលំនៅសព្វថ្ងៃផ្ទះលេខ ២០៣ ផ្លូវលេខមៅសេទុង សង្កាត់ ទួលស្វាយព្រៃ២ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ ស្វស ជា "រ" ម្តាយឈ្មោះ សុខ ទូច "រ" ប្រពន្ធឈ្មោះ ជា ស្រីពៅ "រ" មានកូន ៧នាក់ ជានីតិជន ។

-ទណ្ឌិតរូបនេះ ត្រូវបានតុលាការសម្រេចៈ

១-ផ្តន្ទាទោសឈ្មោះជា តារា ភេទប្រុស អាយុ៥៥ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ចំនួន ៨ខែ (ប្រាំបីខែ) ពីបទៈ បរិហារបង្អាច់កេរ្តិ៍ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាល ពីថ្ងៃទី ០៦ខែ សីហា ឆ្នាំ ២០១០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ៣១១-៣១២ នៃក្រមព្រហ្មទណ្ឌ ។

-ទណ្ឌិតរូបនេះ មានចេតនា គេចវេស ពីការផ្តន្ទាទោស តាមអំណាចសាល ដីកា របស់តុលាការកំពូល ។

-ឈ្មោះ ជា តារា ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើត ភូមិ ស្រែរូង ឃុំ ភ្នំកុង ស្រុក អង្គរជ័យ ខេត្ត កំពត ទីលំនៅសព្វថ្ងៃផ្ទះលេខ ២០៣ ផ្លូវលេខមៅសេទុង សង្កាត់ ទួលស្វាយព្រៃ២ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ ស្វស ជា "រ" ម្តាយឈ្មោះ សុខ ទូច "រ" ប្រពន្ធឈ្មោះ ជា ស្រីពៅ "រ" មានកូន ៧នាក់ ជានីតិជន ។

យកមកផ្តន្ទាទោស តាមអំណាចសាល ដីកា របស់តុលាការកំពូល លេខ៣០០ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៣

**ជ. ព្រះរាជអាជ្ញា**

ឯក ឆេងឃុត
ព្រះរាជអាជ្ញារង

**ឧបសម្ព័ន្ធ៥**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
ដំបូងរាជធានីភ្នំពេញ
.................... អ.យ

## ដីកាឆែកឆេរលំនៅដ្ឋាន

យើង .................... តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

-បានឃើញ ..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

### យល់ឃើញថា :

ដើម្បីរុករកវត្ថុតាង និងបង្ក្រាបបទល្មើសទាក់ទិនករណីខាងលើ ..............................

..........................................................................................

.................................................................. ធ្វើការឆែកឆេរលំនៅដ្ឋានខាងលើ ។

### ហេតុដូច្នេះសំរេច :

-ឆែកឆេរលំនៅដ្ឋានផ្ទះលេខ .............. ផ្លូវ .............. ភូមិ .................... សង្កាត់ .................... ខណ្ឌ .................... រាជធានីភ្នំពេញ។

រាជធានីភ្នំពេញ , ថ្ងៃទី ......... ខែ ......... ឆ្នាំ

តំណាងអយ្យការ

**ឧបសម្ព័ន្ធ៦**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
លេខ:..............................អយណ

## កំណត់ហេតុទទួលវត្ថុចាប់យក

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែឧសភា ថ្ងៃទីសាមសិប វេលាម៉ោងដប់បួន និងសូន្យនាទី ។

យើង [redacted] ក្រឡាបញ្ជីនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញជា អ្នកទទួល ។

លោក [redacted] ជាមន្ត្រីនគរបាលយុត្តិធម៌ ខណ្ឌចំការមន ជាអ្នកប្រគល់។

បានពិនិត្យភិនភាគវត្ថុតាង ដែលទាក់ទងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ............ ចុះថ្ងៃទី...... ខែ..............ឆ្នាំ២០១៦ ឃើញមានដូចខាងក្រោម :

-ប្រដាប់ផ្ទុកទិន្នន័យរូបភាព (Flash) ចំនួន ០១ ។

យើងធ្វើកំណត់ហេតុនេះទុកជាភស្តុតាងដើម្បីសំអាងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ............... ចុះថ្ងៃទី........ខែ................ឆ្នាំ២០១៦ តាមផ្លូវច្បាប់តទៅ ។

បញ្ចប់កំណត់ហេតុនេះនៅវេលាម៉ោងដប់បួន និងដប់ប្រាំនាទី នាថ្ងៃ ខែ ឆ្នាំ ដូចខាងលើ។

ជនសង្ស័យ អ្នកប្រគល់ អ្នកទទួល

**បានឃើញ**

រាជធានីភ្នំពេញ ,ថ្ងៃទី........ខែ...........ឆ្នាំ ២០១៦

**ជ.ព្រះរាជអាជ្ញា**

**ឧបសម្ព័ន្ធ៧**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ ...........
ចុះថ្ងៃទី....... ខែ............ ឆ្នាំ២០១៦

# <u>កំណត់ហេតុសួរចម្លើយ</u>

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែមិថុនា ថ្ងៃទីពីរ វេលាម៉ោងដប់បួន និងសូន្យនាទី។

យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

ដោយមានលោក [redacted] ជាក្រឡាបញ្ជីអមផងបានសួរកត់យកចម្លើយឈ្មោះ **កកកកកក** ជាដើមបណ្តឹង។

**សួរ-ឆ្លើយ** : នាងខ្ញុំឈ្មោះ **កកកកកក** អាយុ ៤១ ឆ្នាំ មុខរបរ មេផ្ទះ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ភូមិកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្នផ្ទះលេខ ៤៨១ ផ្លូវលេខវ៉ាដា ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ **ខខខខខ** (ស) ម្តាយឈ្មោះ **គគគគគគ** (ស) ប្តីឈ្មោះ **ឃឃឃឃ** (រ) មានកូនចំនួន ០២នាក់ ជានីតិជន ទោសពីមុនគ្មាន។

**សួរ-ឆ្លើយ** : កាលពីថ្ងៃខែមិនចាំ ក្នុងឆ្នាំ២០១៥ វេលាម៉ោងប្រហែល ១១ ថ្ងៃត្រង់ ឈ្មោះ **ឃឃឃឃ** ជាប្តី ឈ្មោះ **ងងងង** និងឈ្មោះ **ចចចចច** ជាឪពុកម្តាយក្មេក ឈ្មោះ **ឆឆឆឆ** និងឈ្មោះ **ជជជជ** ត្រូវជាបងថ្លៃ បានព្រួតគ្នាប្រើអំពើហិង្សាវាយដំលើនាងខ្ញុំ បណ្តាលឲ្យមានរបួសយ៉ាងធ្ងន់ធ្ងរ និងគម្រាមកំហែងមកលើរូបនាងខ្ញុំជាញឹកញាប់ ថែមទាំងបក្សពួកខាងលើបណ្តេញនាងខ្ញុំចេញពីផ្ទះ ដែលកំពុងរស់នៅសព្វថ្ងៃ។ ឈ្មោះ **ឆឆឆឆ** និងឈ្មោះ **ជជជជ** បានលួងលោមនាងខ្ញុំថា ទៅធ្វើការដកដំឡូងនៅពេជនិល ដោយបានប្រាក់មួយថ្ងៃ ៣០,០០០ រៀល។ នៅពេលទៅដល់ពេជនិល ពួកគាត់បានដាក់ច្រវ៉ាក់ជើងនាងខ្ញុំ ដោយចោទថានាងខ្ញុំឆ្កួត ហើយយកគ្រូមកស្រោចទឹក និងធ្វើទារុណកម្មរាល់ថ្ងៃ ទោះនាងខ្ញុំអង្វរយ៉ាងណា ក៏គេមិនព្រមដោះច្រវ៉ាក់ដែរ។ ក្រោយមកបងប្រុសនិងបងស្រីរបស់នាងខ្ញុំ មកនាងខ្ញុំត្រលប់មកផ្ទះវិញ។

**សួរ-ឆ្លើយ** : សព្វថ្ងៃបក្សពួកខាងលើ បានបណ្តេញនាងខ្ញុំចេញពីផ្ទះ ដោយផ្ទះខាងលើជាទ្រព្យសម្បត្តិរបស់នាងខ្ញុំដែរ។

**សួរ-ឆ្លើយ** : ភស្តុតាងមាន រូបថតចំនួន ១០សន្លឹក ដែលបង្ហាញពីស្លាកស្នាមរបួស និងការបង្ខាំងទុក។

**សំណូមពរ** : សុំឲ្យតុលាការផ្តន្ទាទោសឈ្មោះ **ឃឃឃឃ**, ឈ្មោះ **ងងងង**, ឈ្មោះ **ចចចចច**, ឈ្មោះ **ឆឆឆឆ**, និងឈ្មោះ **ជជជជ** តាមច្បាប់ និងសុំទាមទារសំណងជំងឺចិត្ត ១០,០០០ ដុល្លារអាមេរិក។

ឈប់សួរសាមីខ្លួន បានអានឆ្លើយថាត្រឹមត្រូវ ហើយសុខចិត្ត ផ្តិតមេដៃជាមួយយើង។

**អ្នកឆ្លើយ** **ក្រឡាបញ្ជី** **ព្រះរាជអាជ្ញារង**

**ឧបសម្ព័ន្ធ៨**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

យ្យការអម

ដំបូងរាជធានីភ្នំពេញ

.................... អ.យ

## ដីកាបញ្ជាឱ្យចូលខ្លួន[1]

យើង .................... តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ ..........................................................................................................

.......................................................................................................................... ។

-បានឃើញមាត្រា ៣៧[២] , ៩៤[៣] និងមាត្រា ១១៤[៤] នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ : នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

បញ្ជា

នាម-គោត្តនាម .............................. ហៅ .................... ភេទ ☐ប្រុស-☐ស្រី អាយុ ........ ឆ្នាំ

ជាតិ .................... របររកស៊ី ..........................................................................

ទីកន្លែងកំណើត ............... ឃុំ-សង្កាត់ ............... ស្រុក-ខណ្ឌ ............... ខេត្ត-រាជធានី ...............

ទីលំនៅបច្ចុប្បន្ន ..................................................................................................

ទោសពីមុន .......... ឪពុកឈ្មោះ .................... "☐រ-☐ស" ម្តាយឈ្មោះ .................... "☐រ-☐ស"

ប្តី ឬ ប្រពន្ធឈ្មោះ .................... "☐រ-☐ស" មានកូន .......... ឬ ☐នៅលីវ - ☐អនីតិជន ឬ ☐នីតិជន ។

ឱ្យចូលបង្ហាញខ្លួននៅ ..........................................................................................

ឱ្យបានមុនថ្ងៃទី .............................. នៅវេលាម៉ោងធ្វើការ ដើម្បីសាកសួរលើបណ្តឹងព្រហ្មទណ្ឌ ពីបទ :

.......................................................................................................................... ។

រាជធានីភ្នំពេញ , ថ្ងៃទី ......... ខែ ......... ឆ្នាំ

តំណាងអយ្យការ

---

១ ដីកានេះអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួនបាន

២ អំណាចរបស់ព្រះរាជអាជ្ញា

៣ ករណីស៊ើបអង្កេតជាក់ស្តែង

៤ ករណីស៊ើបអង្កេតបឋម

## ឧបសម្ព័ន្ធ៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

យ្យការអម
បូងរាជធានីភ្នំពេញ
ព្រហ្មទណ្ឌលេខ ..........
...... ខែ ........ ឆ្នាំ ........
................ អ.យ

### កំណត់ហេតុស្ដីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម[1]

ឆ្នាំពីរពាន់ .............. ខែ ............ ថ្ងៃទី .................... វេលាម៉ោង ................................ ។

**យើង ................ តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ**

បានឃើញសំណុំរឿងលេខ ........................ ចុះថ្ងៃទី ............ ខែ ............ ឆ្នាំ ............ របស់ ................................................................................................................ ។

បុគ្គលដែលនៅចំពោះមុខយើង បានផ្ដល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម :

១- នាម-គោត្តនាម ........................ ហៅ .................. ភេទ ☐ប្រុស-☐ស្រី អាយុ ....... ឆ្នាំ
ជាតិ .................. របររកស៊ី ................................................................
ទីកន្លែងកំណើត .............. ឃុំ-សង្កាត់ .............. ស្រុក-ខណ្ឌ .............. ខេត្ត-ក្រុង ..............
ទីលំនៅបច្ចុប្បន្ន ................................................................................
ទោសពីមុន .......... ឪពុកឈ្មោះ .................. "☐រ-☐ស" ម្ដាយឈ្មោះ .................. "☐រ-☐ស"
ប្ដី ឬ ប្រពន្ធឈ្មោះ .................. "☐រ-☐ស" មានកូន ............ ឬ ☐នៅលីវ - ☐អនីតិជន ឬ ☐នីតិជន ។

យើងប្រាប់ដល់បុគ្គលនេះនូវអង្គហេតុដែលខ្លួនត្រូវបានចោទប្រកាន់មានដូចតទៅ : ....................
................................................................................................................
................................................................................................................
................................................................................................................
................................................................................................................
................................................................................................................
................................................................................................................
................................................................................................................
................................................................................................................
................................................................................................................
................................................................................................................
................................................................................................................

អង្គហេតុនេះជាបទល្មើស ……………………………………

ប្រព្រឹត្តនៅ ……………………………………

កាលពីថ្ងៃទី ………… ខែ ………… ឆ្នាំ ………… តាមបញ្ញត្តិមាត្រា ……………………

នៃច្បាប់ …………………………………… ។

យើងបានទទួលចម្លើយពីជននេះដូចតទៅ : ……………………………………

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

យើងបានប្រាប់ដល់ជននេះថា : ខ្លួនមានសិទ្ធិសុំពឹងមេធាវី តាមការជ្រើសរើសរបស់ខ្លួន ឬស្នើសុំឱ្យមានការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់ ។

ជននេះបានឆ្លើយថា :

- ☐ ខ្ញុំជ្រើស លោក/លោកស្រីមេធាវី .............................................................................. ។
- ☐ ខ្ញុំសូមស្នើសុំឱ្យមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។
- ☐ ខ្ញុំមិនត្រូវការមេធាវីទេក្នុងពេលនេះ ។

យើងបានបញ្ជាក់ថា :

- ☐ លោក/លោកស្រីមេធាវី ................................................ អាចពិនិត្យសំណុំរឿងនិងទាក់ទងជាមួយជនជាប់ចោទ ។
- ☐ យោងលើសំណើសុំ ឱ្យមានការចាត់តាំងមេធាវី ស្របតាមបញ្ញត្តិច្បាប់ ស្តីពីលក្ខន្តិកៈមេធាវីតំណាងគណៈមេធាវីត្រូវបានជូនដំណឹងភ្លាម ។
- ☐ លោក/លោកស្រីមេធាវី ................................................................................ អវត្តមាន ។

បានឃើញមាត្រា ៤៧ មាត្រា ៤៨ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## <u>សម្រេច :</u>

បញ្ជូនជនជាប់ចោទឈ្មោះ ..............................................................................................
ទៅតុលាការដើម្បីធ្វើការជំនុំជម្រះ តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ចំពោះអង្គហេតុ និងបទល្មើសដូចខាងលើ ។

ក្រោយពីបានអាន ជនជាប់ចោទបានចុះហត្ថលេខាជាមួយយើង ។

| | |
|---|---|
| **ជនជាប់ចោទ** | **តំណាងអយ្យការ** |

**ឧបសម្ព័ន្ធ១០**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

យ្យការអម

ដំបូងរាជធានីភ្នំពេញ

ព្រហ្មទណ្ឌលេខ ..........

..... ខែ ......... ឆ្នាំ ..........

.................. អ.យ

## ដីកាសន្និដ្ឋានស្ថាពរ

យើង .................. តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ .................. ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ .......... ។

-បានឃើញសំណុំរឿងស៊ើបសួរលេខ __________ ចុះថ្ងៃទី _____ ខែ _____ ឆ្នាំ ______ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាបញ្ជូនឱ្យឆ្លើយដើម្បីបញ្ចប់ការស៊ើបសួរលេខ ______________ ចុះថ្ងៃទី ______ ខែ ______ ឆ្នាំ _______ ។

-បានឃើញដីបញ្ជូនរឿងទៅពិនិត្យលេខ ____________ ចុះថ្ងៃទី _____ ខែ _____ ឆ្នាំ _______ របស់ចៅក្រមស៊ើបសួរ ។

### ក្រោយពីបានពិនិត្យឯកសារខាងលើ

ឃើញថា :

១. នាម-គោត្តនាម ________________ ហៅ ____________ ភេទ ☐ប្រុស-☐ស្រី អាយុ _____ ឆ្នាំ

ជាតិ ____________ របររកស៊ី ______________________________

ទីកន្លែងកំណើត __________ ឃុំ-សង្កាត់ __________ ស្រុក-ខណ្ឌ __________ ខេត្ត-ក្រុង __________

ទីលំនៅបច្ចុប្បន្ន ______________________________

ទោសពីមុន ______ ឪពុកឈ្មោះ ____________ "☐រ-☐ស" ម្ដាយឈ្មោះ ____________ "☐រ-☐ស"

ប្ដី ឬ ប្រពន្ធឈ្មោះ ____________ "☐រ-☐ស" មានកូន ________ ឬ ☐នៅលីវ - ☐អនីតិជន ឬ ☐នីតិជន ។

២. នាម-គោត្តនាម ________________ ហៅ ____________ ភេទ ☐ប្រុស-☐ស្រី អាយុ _____ ឆ្នាំ

ជាតិ ____________ របររកស៊ី ______________________________

ទីកន្លែងកំណើត __________ ឃុំ-សង្កាត់ __________ ស្រុក-ខណ្ឌ __________ ខេត្ត-ក្រុង __________

ទីលំនៅបច្ចុប្បន្ន ______________________________

ទោសពីមុន ______ ឪពុកឈ្មោះ ____________ "☐រ-☐ស" ម្ដាយឈ្មោះ ____________ "☐រ-☐ស"

ប្ដី ឬ ប្រពន្ធឈ្មោះ ____________ "☐រ-☐ស" មានកូន ________ ឬ ☐នៅលីវ - ☐អនីតិជន ឬ ☐នីតិជន ។

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ______________________________

ប្រព្រឹត្តនៅ ______________________________

កាលពីថ្ងៃទី ______ ខែ ______ ឆ្នាំ ______ តាមបញ្ញត្តិមាត្រា ______________________________

នៃច្បាប់ ______________________________ ។

ឃើញថា[១] :

[១] រៀបរាប់សង្ខេបអង្គហេតុ និងរាល់ចំណាត់ការនៃនីតិវិធីតាមលំដាប់
(ឧទាហរណ៍ អង្គហេតុដែលបានកើតឡើង ចំណាត់ការរបស់មន្ត្រីនគរបាលយុត្តិធម៌ អយ្យការ ចៅក្រមស៊ើបសួរ)

យល់ឃើញថា[២] : ________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

## ហេតុដូច្នេះ

ប្តឹងសុំឱ្យចៅក្រមស៊ើបសួរ សម្រេច :

☐ បញ្ជូនជនត្រូវចោទឈ្មោះ ________________________ ទៅជំនុំជម្រះ។

☐ លើកលែងចោទប្រកាន់ឈ្មោះ ________________________

រាជធានីភ្នំពេញ , ថ្ងៃទី ......... ខែ .......... ឆ្នាំ

តំណាងអយ្យការ

________________

[២] សំអាងហេតុ សំអាងច្បាប់

**ឧបសម្ព័ន្ធ១១**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងរាជធានីភ្នំពេញ

លេខ : .................... អ.យ

**<u>ដីកាតម្កល់រឿងទុកឥតចាត់ការ</u>**

យើង .................... តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញសំណុំរឿងលេខ .................... ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ .......... របស់អយ្យការអមសាលាដំបូង រាជធានីភ្នំពេញ និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា ។

ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា :

១. អវត្តមានបទល្មើស

១.១. ☐ អវត្តមានបទល្មើស

២. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

២.១. ☐ ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣. មូលហេតុគតិយុត្ត

៣.១. ☐ ការដកពាក្យបណ្តឹង

៣.២. ☐ ការលើកលែងទោសជាទូទៅ

៣.៣. ☐ មរណភាពជនល្មើស

៣.៤. ☐ ផុតអាជ្ញាយុកាល

៣.៥. ☐ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

៣.៦. ☐ អាជ្ញាអស់ជំនុំ

៣.៧. ☐ ការសម្របសម្រួលជាមួយរដ្ឋ

៣.៨. ☐ ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល

៣.៩. ☐ អភ័យឯកសិទ្ធិ

៣.១០. ☐ អនិយ័តភាពនៃនីតិវិធី

៣.១១. ☐ ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

៤. ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍

៤.១. ☐ ការស្វែងរកមិនបានផល

៤.២. ☐ ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង[2]

៤.៣. ☐ ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

---

[1] ដូចជាមូលហេតុវិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

[2] ដើមបណ្តឹងរដ្ឋប្បវេណី

៤.៤. ☐ ការខកខានរបស់ដើមបណ្តឹង

៤.៥. ☐ អាកប្បកិរិយារបស់ជនរងគ្រោះ

៤.៦. ☐ ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

៤.៧. ☐ និយ័តកម្មដោយឯកឯង[៣]

៤.៨. ☐ ព្យសនកម្ម ឬ ការរំខានតិចតួចបង្កដោយបទល្មើស

៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា

៥.១. ☐ ការជួសជុលការខូចខាតដោយ / ដល់អនីតិជន

៥.២. ☐ សន្ទានកម្ម[៤]

៥.៣. ☐ អធិបញ្ញាផ្តល់ការព្យាបាល

៥.៤. ☐ ជនរងគ្រោះ / ដើមបណ្តឹងបោះបង់បណ្តឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា

៥.៥. ☐ និយ័តកម្មតាមសំណើរបស់ព្រះរាជអាជ្ញា

៥.៦. ☐ ការរំលឹកពីអត្ថបទច្បាប់ / ការព្រមាន[៥]

៥.៧. ☐ ការកំណត់ទិសដៅចំពោះចេតនាសម្ព័ន្ធនៃសុខភាពនៃសង្គម ឬ វិជ្ជាជីវៈ

៥.៨. ☐ ការសម្រុះសម្រួលព្រហ្មទណ្ឌ[៦]

៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗទៀត

៦.១. ☐ ការចោទប្រកាន់ ឬ ទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

៧. ជនល្មើសមិនត្រូវបានស្គាល់

៧.១. ☐ ជនល្មើសមិនត្រូវបានស្គាល់

៨. ជំនួយការអប់រំ

៨.១. ☐ ការផ្តល់ជំនួយការអប់រំជំនួសការចោទប្រកាន់

ការសង្កេតផ្សេងៗ :

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

---

៣ សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និងស្តារស្ថានភាពឡើងវិញ

៤ ករណីចែងដោយច្បាប់

៥ ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើសតាមកំណត់ច្បាប់ និងធ្វើការព្រមានឱ្យឈប់ប្រព្រឹត្ត

៦ ករណីចែងដោយច្បាប់

រាជធានីភ្នំពេញ , ថ្ងៃទី ......... ខែ .......... ឆ្នាំ

តំណាងអយ្យការ

**ឧបសម្ព័ន្ធ១២**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ អយណ

**<u>លិខិតជូនដំណឹង</u>**

យើង [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ជម្រាមមកលោក **កកកក** អាយុ ៦២ ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ មានទីលំនៅផ្ទះលេខ ១២ ផ្លូវ ៣៧២ ភូមិ ៤ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ត្បិតសំណុំរឿងព្រហ្មទណ្ឌលេខ ................ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ ករណីគ្រោះថ្នាក់ចរាចរណ៍ នៅចំណុចផ្លូវ ២០៥ កែងផ្លូវ ៣៧៤ សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ នោះយើងបានសម្រេចតម្កល់រឿងទុកឥតចាត់ការ តាមដីកាសម្រេចលេខ ................ អយណ ចុះថ្ងៃទី.......... ខែមេសា ឆ្នាំ២០១៦ រួចហើយ ។

រាជធានីភ្នំពេញ , ថ្ងៃទី ខែមេសា ឆ្នាំ២០១៦

